# យុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតពីអំពើហិង្សាដោយទឹកអាស៊ីតនៅកម្ពុជា «បើសិនជាខ្ញុំមានលុយនាំងជុំ តុលាការប្រហែលជាអនុវត្តតាមច្បាប់ហើយផ្តន្ទាទោសឱ្យនាងជាប់ពន្ធនាគារ»[១]

ហ្សារ៉ុន ប៊ីហ្សែរ (Sharon Beijer)[២]


១. សេចក្តីផ្តើម.........................................................................

២. អំពើហិង្សាដោយទឹកអាស៊ីត - សាវតារសង្ខេប...................................

២.១. ផលប៉ះពាល់ផ្នែកវេជ្ជសាស្ត្រ..................................................

២.២. ផលប៉ះពាល់មិនមែនវេជ្ជសាស្ត្រ..............................................

២.៣. ការចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាល...............................

៣. អំពើហិង្សាដោយទឹកអាស៊ីតនៅកម្ពុជា - កត្តាបង្កចំនួនបួន...........................

៣.១. ទិន្នន័យ.........................................................................

៣.២. ការទិញទឹកអាស៊ីត និងផលប៉ះពាល់.....................

៣.៣. និទណ្ឌភាព.....................................................................

៣.៤. ការយល់ឃើញរបស់សាធារណជន.........................................

៤. ប្រព័ន្ធច្បាប់កម្ពុជា៖ ក្តីសង្ឃឹមក្នុងការសម្រេចបានយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើហិង្សាដោយទឹកអាស៊ីត.............................................................................

៤.១. ដំណើរការច្បាប់នៅកម្ពុជា...................................................


---

[១] ជនរងគ្រោះដោយទឹកអាស៊ីត ។ នៅក្នុងអត្ថបទនេះ អ្នកដែលបានរស់រានពីការលោកទឹកអាស៊ីតត្រូវបានសម្គាល់ដោយឈ្មោះជាអក្សរកាត់របស់ពួកគេ ក្នុងគោលបំណងគោរពលើភាពជាឯកជន និងមូលហេតុសុវត្ថិភាព ។

[២] អ្នកនិពន្ធធ្លាប់បំពេញការងារនៅអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត ។ អ្នកនិពន្ធបានពឹងផ្អែកលើបទពិសោធន៍ ទិន្នន័យ និងការស្រាវជ្រាវ ដែលប្រមូល និងផ្តល់ឲ្យដោយអង្គការ ។ ប៉ុន្តែ គំនិតដែលបានបញ្ចេញក្នុងអត្ថបទនេះ ជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ ដែលមិនបានបង្ហាញពីការយល់ឃើញរបស់អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីតនោះឡើយ ។

**៤.២. ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីតខ្លាំង (២០១២)..........................**
៤.២.១. អនុក្រឹត្យស្តីពីបែបបទ និងលក្ខខណ្ឌនៃការគ្រប់គ្រងអាស៊ីតខ្លាំង...........
**៤.៣. ឧបសគ្គទូទៅដែលរារាំងជនរងគ្រោះពីការទទួលបានយុត្តិធម៌.............**
៤.៣.១. កង្វះឯករាជភាពនៃតុលាការកម្ពុជា...........................................
៤.៣.២. ការរើសអើង និងការយល់ឃើញ..............................................
**៤.៤.ការយល់ឃើញរបស់អ្នករស់រានមានជីវិតពីអំពើហិង្សាដោយទឹកអាស៊ីត..**
៤.៤.១. ការភ័យខ្លាច និងការមិនទុកចិត្តប្រព័ន្ធច្បាប់................................
៤.៤.២. កង្វះការជម្រះក្តី.............................................................
៤.៤.៣. កម្រិតផ្តន្ទាទោសទាប........................................................
៤.៤.៤. កង្វះការអនុវត្ត................................................................
**៤.៥. ឥទ្ធិពលច្បាប់ស្តីពីអាស៊ីតមកលើអ្នករស់រានមានជីវិត......................**
**៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍.................................................**

## ១. សេចក្តីផ្តើម

ថ្ងៃទី៥ ខែសីហា បីខែបន្ទាប់ពីការលែងលះគ្នារបស់អតីតប្តីប្រពន្ធមួយគូ និងបន្ទាប់ពីការស្នើសុំផ្ទួនៗ ដើម្បីទាមទារយកគាត់មកវិញ រួមជាមួយនឹងការគំរាមកំហែងថាគេនឹងយកកូនរបស់គាត់ទៅ ប.ស អាយុ៤៩ឆ្នាំ កំពុងតែរង់ចាំអតីតប្រពន្ធរបស់គាត់ ឈ្មោះ ណ.ស ចេញពីផ្ទះមិត្តភក្តិនាង។ នៅពេល ណ.ស ចេញពីផ្ទះរបស់មិត្តភក្តិ ប.ស ក៏បានជះទឹកអាស៊ីតទៅលើ ណ.ស ដែលជាអតីតប្រពន្ធធ្វើឲ្យរលាករលេះលើផ្ទៃមុខ ក ដើមទ្រូង ខ្នង ស្មា និងភ្នែកខាងស្តាំរបស់នាង។ នាងនឹងត្រូវរស់នៅជាមួយស្លាម សម្គាកនៃការវាយប្រហារនេះអស់មួយជីវិត។ មួយថ្ងៃក្រោយមក ប.ស ក៏ត្រូវបានចាប់ឃុំខ្លួនបណ្តោះអាសន្នរហូតដល់ពេលជំនុំជម្រះក្តី។ នៅខែមករា ឆ្នាំ២០១៣ សាលាដំបូងរាជធានីភ្នំពេញបានកាត់ក្តីឲ្យ ប.ស ជាប់ពន្ធនាគារចំនួន៥ឆ្នាំ ថែមទាំងត្រូវបង់ប្រាក់ពិន័យចំនួន១០លានរៀល (២៥០០ដុល្លារអាមេរិក) ជូនរដ្ឋសម្រាប់ការប្រើអំពើហិង្សាដោយទឹកអាស៊ីត ដោយចេតនា។ ការដាក់ទោស ប.ស គឺជាទម្ងន់ទោសធ្ងន់បំផុតដែលត្រូវបានចោទប្រកាន់ ពោលគឺបទ "អំពើហិង្សាដោយចេតនា" ដោយយោងតាមមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីតខ្លាំង ឬហៅថា (ច្បាប់អាស៊ីត)។

នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ច្បាប់ស្តីពីអាស៊ីតបានចូលជាធរមាន ។[៣] ច្បាប់នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដោះស្រាយបញ្ហាដែលកើតឡើងជារឿយៗ ការវាយប្រហារដោយទឹកអាស៊ីត ដែលជះឥទ្ធិពលអន្តរាយដល់មនុស្សជាច្រើននៅកម្ពុជា ។ ការវាយប្រហារដោយទឹកអាស៊ីតជាអំពើហិង្សាគ្រោងទុក ដែលបានធ្វើឲ្យជនរងគ្រោះមានសម្លាកទាំងផ្នែក ផ្លូវកាយ ផ្លូវចិត្ត និងសតិអារម្មណ៍ ។[៤] ជាទូទៅ ការវាយប្រហារដោយទឹកអាស៊ីតមិនបានសម្លាប់ ជនរងគ្រោះនោះទេ ។ ប៉ុន្តែ វាធ្វើឲ្យជនរងគ្រោះទទួលរងរបួសធ្ងន់ធ្ងរ និងឈឺចាប់លើរូបរាងកាយ ប៉ះពាល់ដល់ជីវភាពជនរងគ្រោះគេចវេះពីសង្គម និងធ្លាក់ទឹកចិត្ត ។[៥]

ការវិនិច្ឆ័យទោស ប.ស អាចចាត់ទុកថាជាការវិនិច្ឆ័យទោសមួយដែលគួរឲ្យចាប់អារម្មណ៍ដោយផ្អែកលើហេតុផលមួយចំនួន ។ ទីមួយ ការដែលថាជនល្មើសត្រូវបានចាប់ខ្លួន ដែលជាករណីពិសេសមួយទៅហើយ ។ រយៈពេលនៃដំណើរការទាំងមូលដែលគិតចាប់ពីការវាយប្រហារ រហូតទៅដល់ការចេញសាលក្រមបានធ្វើឡើងក្នុងរយៈពេលខ្លី ។ ចុងក្រោយ រឿងក្តីនេះជារឿងក្តីដំបូងបំផុត ដែលជនសង្ស័យត្រូវបានចោទប្រកាន់ និងកាត់ទោសដោយប្រើប្រាស់ច្បាប់ថ្មីនេះ ។

នៅកម្ពុជា អ្នករស់មានមានជីវិតពីអំពើហិង្សាដោយទឹកអាស៊ីតជាទូទៅ ពុំបានទទួលការជំនុំជម្រះក្តីនិងការផ្តន្ទាទោសជនល្មើសឲ្យជាប់ពន្ធនាគារភ្លាមៗ ទេ ។ ស្ទើរតែគ្រប់ករណីទាំងអស់ ជនសង្ស័យមិនត្រូវបានចាប់ខ្លួននោះទេ ។ ជនរងគ្រោះបានបន្សល់នូវស្លាកស្នាមទាំងលើរាងកាយ និងសតិអារម្មណ៍ជារៀងរហូតហើយគ្មានសង្ឃឹមក្នុងការទទួលបានយុត្តិធម៌ និង ដំណោះស្រាយតាមផ្លូវច្បាប់ទេ ។ របាយការណ៍ចេញផ្សាយនៅឆ្នាំ២០១០ ដោយអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត (ហៅកាត់ថា CASC) សហការណ៍ជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ហៅកាត់ថា CCHR) បានបង្ហាញអំពីបញ្ហាចម្បងចំនួនបួនដែលជាដើមហេតុនៃអំពើហិង្សាដោយទឹកអាស៊ីតនៅកម្ពុជា ។ បញ្ហាទាំងនោះរួមមានការអាចរកទិញទឹកអាស៊ីតបាននៅលើទីផ្សារ និទណ្ឌភាព និងការខ្វះខាតការផ្តល់ឲ្យនូវសេវាកម្ម

---

[៣] ច្បាប់នេះត្រូវបានប្រកាសនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១ និងត្រូវបានប្រកាសឲ្យប្រើដោយព្រះបាទនរោត្តមសីហមុនីនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ។

[៤] មើលគេហទំព័ររបស់ អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត; www.thecasc.org

[៥] J. Welsh, អត្ថបទដែលមានចំណងជើងថា *"It was like burning in hell: A Comparative Exploration of Acid Attack Violence"*, CAROLINA PAPERS ON INT'L HEALTH, UNC Global 3 (Fall 2009), អាចរកបាននៅគេហទំព័រ: *//cgi.unc.edu/uploads/media_items/it-was-like-burning-in-hell-a-comparative-exploration-of-acid-attack-violence.original.pdf*

សង្គ្រោះបន្ទាន់ក្រោយពីរងគ្រោះ ព្រមជាមួយការយល់របស់សាធារណជន ។[៦] អត្ថបទនេះនឹងពន្យល់អំពីបញ្ហាទាំង៤ខាងលើ ប៉ុន្តែ ការផ្តោតសំខាន់ទៅលើ “វប្បធម៌នៃនិទណ្ឌភាព” នៃអំពើហិង្សាដោយទឹកអាស៊ីតនៅកម្ពុជា ។ ទិន្នន័យរបស់អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត បានបង្ហាញថាជនល្មើស កម្រត្រូវបាននាំយកទៅកាត់ទោសណាស់ ។ ដោយអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត នៅក្នុងរឿងក្តីច្បាប់ចំនួន៨១ករណី មានតែរឿងក្តីចំនួន១១ករណីតែប៉ុណ្ណោះ ដែលត្រូវបានសម្រេចដោយតុលាការ ។[៧] មូលហេតុពាក់ព័ន្ធនឹងការមិនផ្តន្ទាទោសជនល្មើស អាចប្រទះឃើញនៅគ្រប់ជាន់ថ្នាក់ទាំងអស់នៃដំណើរការព្រហ្មទណ្ឌ ។ ជាលទ្ធផល អ្នករួចជីវិតពីអំពើហិង្សាដោយអាស៊ីតមិនទំនងជាបានឃើញជនដែលដល់ទទួលការជំនុំជម្រះក្តី និង ដំណោះស្រាយ នៅក្នុងតុលាការកម្ពុជា ។ ការស្វែងរក យុត្តិធម៌នៅតែមានការលំបាក ហើយជួនកាលនោះគឺមិនអាចធ្វើទៅរួចតែម្តង ។

អត្ថបទនេះ នឹងផ្តោតទៅលើឧបសគ្គដែលជនរងគ្រោះដោយទឹកអាស៊ីតបានជួបប្រទះនៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ។ អត្ថបទនេះ នឹងពិនិត្យទៅលើបាតុភូតនៃអំពើហិង្សាដែលបង្កឡើងដោយការប្រើប្រាស់ទឹកអាស៊ីត ព្រមទាំងដើមហេតុ និងផលប៉ះពាល់ដែលអាចកើតឡើង ។ លើសពីនេះទៅទៀត អត្ថបទនេះនឹងធ្វើការពិនិត្យលើបច្ចុប្បន្នភាពនៃប្រព័ន្ធច្បាប់កម្ពុជា និងផលប៉ះពាល់លើការស្វែងរកយុត្តិធម៌ដោយអំពើហិង្សាទឹកអាស៊ីត ។ អត្ថបទនេះ នឹងធ្វើការយកចិត្តទុកដាក់ជាពិសេសទៅលើច្បាប់អាស៊ីត ដែលដាក់ឲ្យប្រើថ្មីៗ និងអនុក្រឹត[៨] ដែលបានចូលជាធរមាន នៅចុងខែមករា ឆ្នាំ២០១៣ ព្រមជាមួយនឹង ឥទ្ធិពលនៃឯកសារទាំងនេះ ។

## ២. អំពើហិង្សាដោយទឹកអាស៊ីត-សាវតារសង្ខេប

---

[៦] CASC និងCCHR, *អត្ថបទដែលមានចំណងជើងថា* 'Breaking and Silence: Addressing Acid Attacks in Cambodia', *នៅ ខែឧសភា ឆ្នាំ២០១០, ទំព័រ១៦ ។*

[៧] *ទិន្នន័យអង្គភាពច្បាប់នៃ* CASC *។ សេចក្តីសម្រេចចុងក្រោយមានន័យថារឿងក្តីមិនត្រូវបានជម្រះសាជាថ្មីនោះទេ (ដោយសាររយៈពេលដែលត្រូវចំណាយក្នុងការប្តឹងឧទ្ធរណ៍ ឬអាចមកពីតុលាការកំពូលជាអ្នកចេញសាលក្រម) ។*

[៨] *អនុក្រឹតស្តីពីទម្រង់បែបបទ និងលក្ខខណ្ឌសម្រាប់ការគ្រប់គ្រងអាស៊ីតខ្លាំង, នៅក្នុង* Sub-decree on the Formalities and Conditions for Strong Acid Control, 13 Official Gazette1487 (Feb. 19, 2013) *។ ឯកសារបកប្រែពីភាសាខ្មែរទៅអង់គ្លេសក្រៅផ្លូវការត្រូវបានយកមកប្រើប្រាស់ក្នុងការវិភាគលើអនុក្រឹត្យនេះ ។*

អំពើហិង្សាដោយទឹកអាស៊ីត មិនមែនជាបញ្ហាដែលកើតឡើងតែនៅកម្ពុជាទេ ។ ការវាយប្រហារដោយទឹកអាស៊ីតត្រូវបានរាយការណ៍ជាញឹកញាប់នៅប្រទេសឥណ្ឌា ប៉ាគីស្ថាន បង់ក្លាដេស នេប៉ាល់ អ៊ីរ៉ង់ អ៊ីរ៉ាក់ យូហ្គាន់ដា និងកូឡុំប៊ី ។[៩] របាយការណ៍ពាក់ព័ន្ធនឹង ឧបទ្ទវហេតុដាច់ដោយឡែកកើតឡើងនៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាល្លឺម៉ង់ រុស្ស៊ី បែលហ្ស៊ិក និងប្រទេសកាណាដា ។[១០] យោងទៅលើកំណើននៃរបាយការណ៍ពាក់ព័ន្ធនឹងអំពើហិង្សាដោយទឹកអាស៊ីត យើងអាចនិយាយបានថា អំពើហិង្សាប្រភេទនេះជាបាតុភូតថ្មី ។ ប៉ុន្តែ របាយការណ៍ស្តីពីការប្រើប្រាស់ ទឹកអាស៊ីតក្នុងឥរិយាបថយង់ឃ្នងបានបង្ហាញថា ការប្រើប្រាស់ទឹកអាស៊ីតរបៀបនេះបានកើតឡើងយ៉ាងហោចណាស់ តាំងពីសតវត្សរ៍ទី១៨មកម្ល៉េះ ។[១១] នៅពេលដែល អាស៊ីតស៊ុលភួរិច អាចរកបានដោយងាយនៅអឺរ៉ុប និងអាមេរិច មនុស្សក៏ចាប់ផ្តើម ប្រើប្រាស់អាស៊ីតក្នុងគោលបំណងហិង្សា បន្ទាប់ពីអាស៊ីតប្រភេទនេះ

---

[៩] Arturo Wallace, អត្ថបទដែលមានចំណងជើងថា *Colombia Acid Victims Seek Justice As Attacks Spread*, BBC, នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២, អាចរកបាននៅគេហទំព័រ: http://www.bbc.co.uk/news/world-latin-america-18246717

[១០] **Chris Boyette**, អត្ថបទដែលមានចំណងជើងថា Police: NY man attacks daughter with acid, ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១២, ប្រភពពីអ៊ិនធើណិត, អាចរកបាននៅគេហទំព័រ: http://edition.cnn.com/2012/09/02/us/new-york-acid-attack; អត្ថបទដែលមានចំណងជើងថា The Guardian, Salford acid attack may be racially motivated, ថ្ងៃទី ២៦ ខែមិនា ឆ្នាំ២០១២, ប្រភពពីអ៊ិនធើណិត, អាចរកបាននៅគេហទំព័រ: http://www.guardian.co.uk/uk/2012/mar/26/salford-acid-attack-racially-motivated; អត្ថបទដែលមានចំណងជើងថា The Local, Two arrested in Rhineland acid attack, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២, ប្រភពពីអ៊ិនធើណិត, អាចរកបាននៅគេហទំព័រ: http://www.thelocal.de/national/20121231-47057.html#.URiOWPL74zk; CNN, អត្ថបទដែលមានចំណងជើងថា Russia's Bolshoi Ballet director may lose sight after acid attack, ថ្ងៃទី២៣ ខែ មករា ឆ្នាំ ២០១៣, ប្រភពពីអ៊ិនធើណិត, អាចរកបាននៅគេហទំព័រ: http://edition.cnn.com/2013/01/18/world/europe/russia-ballet-acid-attack; អត្ថបទដែលមានចំណងជើងថា The Daily Mail, Acid victim testifies against married lover, ថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០១២, ប្រភពពីអ៊ិនធើណិត, អាចរកបាននៅគេហទំព័រ: http://www.dailymail.co.uk/news/article-2113939/Patricia-Lefranc-Acid-attack-victim-arrives-testify-married-lover.html#axzz2KZPWgunl; អត្ថបទដែលមានចំណងជើងថា The Global Post, Acid attack in Canada puts woman into coma, ថ្ងៃទី២៩ ខែ សីហា ឆ្នាំ ២០១២, អត្ថបទដែលមានចំណងជើងថា, អាចរកបាននៅគេហទំព័រ: http://www.globalpost.com/dispatch/news/regions/americas/canada/120829/acid-attack-canada-tanya-st-arnaud-coma.

[១១] មើល; Welsh, *កំនត់ចំណាំលេខ៥ ខាងលើ*, ទំព័រ. ២១-២៥, ដើម្បីព័ត៌មានបន្ថែមលើអំពើហិង្សាដោយប្រើប្រាស់អាស៊ីតនៅអតីតកាល ។

ត្រូវបានផលិតជាលក្ខណៈឧស្សាហ៍កម្មនៅប្រទេសអង់គ្លេសក្នុងអំឡុង ឆ្នាំ១៧៥០ ។[១២] សម្រង់ពាក្យដែលបានដកស្រង់ចេញពីទស្សនាវដ្តីក្លាសហ្គោ តាំងពីឆ្នាំ១៨៣០ បានសសេរថា «ឧក្រិដ្ឋកម្មនៃការជះវីទ្រីយ៉ូល [អាស៊ីតស៊ុលហ្វួរិច] បានក្លាយជា រឿងមួយសាមញ្ញនៅក្នុងប្រទេសនេះ ដែលស្ទើរតែធ្វើឲ្យខូចចរិតជាតិទៅហើយ ។»[១៣] ប៉ុន្តែគិតត្រឹមពាក់កណ្តាលសតវត្សរ៍ទី២០ ការវាយប្រហារដោយទឹកអាស៊ីតនៅអឺរ៉ុប និងសហរដ្ឋអាមេរិក ស្ទើរតែសាបរលាបអស់ទៅវិញ ។ របាយការណ៍ស្តីពីអំពើហិង្សាដោយទឹកអាស៊ីត នៅក្នុងតំបន់ដទៃទៀតលើពិភពលោក (ដូចជានៅអាស៊ី និងអាស៊ីបូព៌ា) ទើបបានចាប់ផ្តើមកើនឡើងចាប់ ពីចុងសតវត្សរ៍ទី២០មក ។[១៤]

អំពើហិង្សា និងការវាយប្រហារដោយទឹកអាស៊ីត គឺជាការវាយប្រហារដោយចេតនាទៅលើបុគ្គលម្នាក់ ឬក៏ក្រុមមួយក្នុងគោលបំណងធ្វើឲ្យជនរងគ្រោះពិការ ខូចរូបរាងកាយអស់មួយជីវិត បង្កឲ្យមានការឈឺចាប់ ធ្វើទារុណកម្ម ឬសម្លាប់ជនរងគ្រោះបណ្តាលឲ្យមានការឈឺចាប់ធ្ងន់ធរលើផ្លូវកាយ និងផ្លូវចិត្ត ។ ផលប៉ះពាល់នៃអំពើហិង្សាដោយទឹកអាស៊ីដ និងគ្រោះថ្នាក់ដោយទឹកអាស៊ីត អាចបង្កភាពអន្តរាយយ៉ាងខ្លាំង ។ ជាទូទៅការវាយប្រហារដោយប្រើប្រាស់ ទឹកអាស៊ីតមិនអាចបណ្តាលឲ្យជនរងគ្រោះបាត់បង់ជីវិតទេ ប៉ុន្តែជានិច្ចជាកាល វាធ្វើឲ្យជនរងគ្រោះទទួលរងរបួស និងទទួលរងនូវការឈឺចាប់ភ្លាមៗ ។ ចំណែកឯផលប៉ះពាល់យូរអង្វែងវិញរួមមាន ការខូចរាងកាយអស់ មួយជីវិត ស្នាមសម្លាក ការឈឺចាប់ និងបញ្ហាវេជ្ជសាស្ត្រ ។ ក្រៅពីផលវិបាកផ្លូវកាយ និងវេជ្ជសាស្ត្រ អ្នករស់ជីវិតនិងគ្រួសាររបស់ពួកគេ ត្រូវតស៊ូប្រឈមមុខនឹងបញ្ហាសង្គម បញ្ហាផ្លូវចិត្ត និងទទួលរងទុក្ខអស់មួយជីវិត ។[១៥] ការវាយប្រហារត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណង «សងសឹក» ។[១៦] វែលស៍ (Welsh) បានមានប្រសាសន៍ថា អាចមានការពន្យល់ជាច្រើនសម្រាប់ការវាយប្រហារដោយប្រើប្រាស់

---

[១២] L. V. Anderson, Throwing vitriol. អត្ថបទដែលមានចំណងជើងថា *When did people start using acid as a weapon?*, Slate, ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៣, ប្រភពពីអ៊ិនធើណិត, អាចរកបាននៅគេហទំព័រ: http://www.slate.com/articles/news_and_politics/explainer/2013/02/history_of_acid_violence_when_did_people_start_throwing_vitriol.html

[១៣] អត្ថបទដែលមានចំណងជើងថា *Execution of Hugh Kennedy*, ៣-៤ THE REFORMER'S GAZETTE, ៣៣២ (Muir, Rowan & Co., 1831), អាចរកបាននៅគេហទំព័រ: http://books.google.com.kh/books?id=jDrhIzL32vwC&pg=RA1PA332&redir_esc=y#v=onepage&q=vitriol&f=false.

[១៤] Anderson, មើលកំណត់ចំណាំលេខ១២ ។

[១៥] អត្ថបទដែលមានចំណងជើងថា *Breaking the Silence* មើលកំណត់ចំណាំលេខ៦, ទំព័រ ៦ ។

[១៦] កិច្ចសម្ភាសន៍ជាមួយលោក ហ្សៀត សាមមេន (Ziad Samman), ប្រធានគម្រោងCASC ។

ទឹកអាស៊ីត រួមមាន ការអាចរកទិញទឹកអាស៊ីតបានក្នុងតម្លៃថោក ផ្នត់គំនិតជាលក្ខណៈប្រពៃណីពាក់ព័ន្ធនឹងស្ត្រី ការផ្លាស់ប្តូរតួនាទីយែនឌ័រ ឥទ្ធិពលពីប្រភពសារព័ត៌មាន ការបាត់បង់មុខមាត់កិត្តិយស និងបំណងចង់សងសឹក និងដាក់ទណ្ឌកម្ម ។[១៧]

ការវាយប្រហារដោយទឹកអាស៊ីតត្រូវបានធ្វើឡើងទាំងនៅទីសាធារណៈ និងនៅទីកន្លែងឯកជន ដោយការជះ ស្រោច និងចាក់ទឹកអាស៊ីតទៅលើមុខ និងខ្លួនប្រាណជនរងគ្រោះ ។ ឧទាហរណ៍ពាក់ព័ន្ធនឹងការវាយប្រហាររួមមាន មានជនល្មើសមួយចំនួនធ្វើការវាយប្រហារដោយជះទឹកអាស៊ីតតាមបង្អួចចំហ និងគាស់ចូលផ្ទះនៅពេលយប់ រួចស្រោចទឹកអាស៊ីតលើរូបរាងកាយជនរងគ្រោះនៅពេលដែល ជនរងគ្រោះកំពុងតែសម្រាន្ត ។ ការវាយប្រហារខ្លះទៀតបានធ្វើឡើងដោយការជះទឹកអាស៊ីតពីលើ ទោចក្រយានយន្ត ឬនៅទីកន្លែងដែលចង្អៀតដូចជាផ្សារជាដើម ។ ជាទូទៅមុខគឺជាគោលដៅ ចម្បងដែលនឹងត្រូវវាយប្រហារ ហើយទឹកអាស៊ីតហូរស្រោចមកលើដើមទ្រូងនិងពេញរាងកាយក្នុងអំឡុងពេលវាយប្រហារ ។ ជនល្មើស អាចធ្វើសកម្មភាពវាយប្រហារបានយ៉ាងងាយស្រួល នៅទីសាធារណៈដូចជានៅទីផ្សារ និងភោជនីយដ្ឋាន ដោយសារទឹកអាស៊ីតមិនមានលក្ខណៈដូចជាអាវុធទូទៅ ។ អាស៊ីតជាសារធាតុថ្លាដូចទឹក ដែលមើលទៅហាក់បីដូចជាទឹកធម្មតានៅក្នុងដបទឹកសុទ្ធអ៊ីចឹង ដែលធ្វើឲ្យខ្រិដ្ឋជនងាយស្រួលប្រើប្រាស់ដើម្បីធ្វើសកម្មភាព ដោយពុំស្តែងឲ្យឃើញត្រង់ៗឡើយ ។ មួយវិញទៀត ការវាយប្រហារដោយប្រើប្រាស់ទឹកអាស៊ីត មានលក្ខណៈ “ងាយស្រួល” ព្រោះការជះទឹកអាស៊ីតពុំបានបញ្ចេញសំឡេង ដែលអាចឲ្យជនរងគ្រោះដឹងពីព្រឹត្តិការណ៍ដែលបម្រុងនឹងកើតឡើងលើខ្លួនមុននោះទេ ។ នៅពេលទទួលរងការវាយប្រហារភ្លាមៗជនរងគ្រោះតែងតែគិតថា ខ្លួនរបស់គេត្រូវបានស្រោចដោយទឹកក្តៅ ក្រោយមកបន្តិចទើបដឹងថាខ្លួនត្រូវបានវាយប្រហារដោយទឹកអាស៊ីត ។ លើសពីនេះទៅទៀត នៅពេលដែលការវាយប្រហារបានធ្វើឡើងនៅទីសាធារណៈ វាធ្វើឲ្យខ្រិដ្ឋជន ងាយស្រួលបន្លំខ្លួនក្នុងចំណោមហ្វូងមនុស្ស ឬជិះម៉ូតូដែលនៅរង់ចាំគេចខ្លួន ។

## ២.១. ផលប៉ះពាល់ផ្នែកវេជ្ជសាស្ត្រ

នៅពេលដែលអាស៊ីតទៅប៉ះលើរាងកាយ ឬស្បែក វាធ្វើឲ្យមានអារម្មណ៍ស្រដៀងគ្នាទៅនឹងរលាកទឹកក្តៅដែរ ប៉ុន្តែ មិនយូរប៉ុន្មាន ជនរងគ្រោះនឹងទទួលអារម្មណ៍ក្តៅរលាកលើស្បែកកាន់តែខ្លាំង

[១៧] Welsh, *មើលកំណត់ចំណាំលេខ ៥*, *ទំព័រ ២ ។ កត្តាជំរុញពីក្រោយនៃអំពើហិង្សាដោយទឹកអាស៊ីតនឹងត្រូវពន្យល់បន្ថែមខាងក្រោម ។*

ឡើងៗ ប្រសិនបើមិនយកទឹកមកលាងសម្អាតជាតិអាស៊ីតចេញភ្លាមៗទេនោះ អាស៊ីតនឹងស៊ីស្បែក សាច់ សាច់ដុំ និងប្រព័ន្ធប្រសាទ ស៊ីឆ្អឹង ដែលនាំឲ្យឈានទៅដល់ការពិការសរីរាង្គ ។ ដោយសារមុខមនុស្ស ពោរពេញទៅដោយជាលិកា ទឹកអាស៊ីតអាចកាត់បំផ្លាញភ្នែក ត្របកភ្នែក ត្រចៀក បបូរមាត់ ច្រមុះ និងមាត់យ៉ាងឆាប់ហ័ស ។ ជនរងគ្រោះ នឹងទទួលរងនូវការឈឺចាប់រហូតទាល់តែលាងជម្រះជាតិអាស៊ីតអស់ ។ បន្ទាប់ពីរយៈពេលប្រហែលជា៥វិនាទីក្រោយពីប៉ះទឹកអាស៊ីត ស្នាមរលាកផ្នែកខាងក្រៅនឹងលេចឡើង រួចប្រមាណជា៣០វិនាទីក្រោយពីការរលាក ស្នាមរលាកនឹងលេចឡើងកាន់តែក្រាស់ទៅៗ ។ ជនរងគ្រោះនឹងទទួលរងការឈឺចាប់ខ្លាំងបំផុតពីរលាកស្បែកខាងក្រៅ ជាជាងការរលាកជ្រៅដោយសារតែ ការរលាកជ្រៅបានបំផ្លាញកោសិកាប្រសាទទៅហើយ ។ អាស៊ីតមានកំហាប់កាន់តែរាវ ផលប៉ះពាល់ដល់ខ្លួនប្រាណ និងស្បែកកាន់តែតិច ។[១៨]

បន្ទាប់ពីការវាយប្រហារភ្លាមៗ ជនរងគ្រោះនឹងទទួលរងនូវបញ្ហាសុខភាពធ្ងន់ធ្ងរជាច្រើន ។ បញ្ហាទាំងនោះរួមមាន អសមត្ថភាពក្នុងការដកដង្ហើម ដែលបង្កឡើងដោយការស្រូបយកចំហាយអាស៊ីត ដែលនាំឲ្យមានប្រតិកម្មជាតិពុល ឬអាចហើមសួត និងរលាកផ្លូវដង្ហើម ។ អស់រយៈពេលប៉ុន្មានសប្តាហ៍ក្រោយពីការគ្រោះថ្នាក់ ជនរងគ្រោះអាចប្រឈមមុខនឹងការឆ្លងមេរោគបង្កដោយសារមុខរបួសនៅចំហរ ដែលអាចប៉ះពាល់ដល់ជីវិតប្រសិនបើការព្យាបាលដោយបច្ចេកទេស លាងសម្អាត និងសម្លាប់មេរោគឲ្យបានត្រឹមត្រូវទេនោះ ។ ជាងនេះទៅទៀត ស្បែកដែលរលាកនឹងងាប់ រួចមុខរបួសនឹងឡើងខ្មៅ ហើយបន្សល់ទុកនូវសម្លាកធំៗ ។

កត្តាគំរាមកំហែងយ៉ាងធ្ងន់ធ្ងរទៅលើជនរងគ្រោះ គឺការខ្វះខាតការទទួលបាននូវសេវាកម្មសុខាភិបាលមួយដែលមានគុណភាព នៅប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ។ ពុំទទួលបានសេវាកម្មសុខាភិបាលគ្រប់គ្រាន់ និងត្រូវតែងតែធ្វើដំណើរឆ្ងាយៗ ដើម្បីទៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាពដែលនៅជិតបំផុត ចំណែកការព្យាបាលមុខរបួសដែលបង្កដោយទឹកអាស៊ីតត្រូវតែធ្វើឡើងភ្លាមៗដោយមិនអាចពន្យារបាន ។[១៩] ស្ទើរតែគ្រប់មន្ទីរពេទ្យរដ្ឋ និងមន្ទីរពេទ្យឯកជននៅកម្ពុជា ពុំបានផ្តល់សេវាកម្មព្យាបាលតាមតម្រូវការជនរងគ្រោះដោយការរលាកទឹកអាស៊ីតឡើយ ឬផ្តល់ការព្យាបាលមិនត្រឹមត្រូវដោយសារទទួលបានការហ្វឹកហ្វឺន និងចំណេះដឹងអំពីការរលាក នៅមានកម្រិត ហើយពេលខ្លះបានធ្វើឲ្យ

---

[១៨] អត្ថបទដែលមានចំណងជើងថា *Breaking the Silence* មើលកំណត់ចំណាំលេខ ៦, ទំព័រ ៥ ។

[១៩] P. Chatterjee, អត្ថបទដែលមានចំណងជើងថា *Campaigns Against Acid Violence Spur Change*, ៨៩ BULLETIN OF THE WORLD HEALTH ORG. ៨ (២០១១) ។

អ្នកជំងឺមានសភាពកាន់តែធ្ងន់ធ្ងរថែមទៀតផង ។ នៅកម្ពុជា មន្ទីរពេទ្យមានតែបីប៉ុណ្ណោះ ដែលមានផ្នែករលាកហើយមន្ទីរពេទ្យទាំងនោះ សុទ្ធតែមានទីតាំងនៅភ្នំពេញទាំងអស់ ។[២០] ដោយសារតែខ្វះមណ្ឌលសុខភាពនៅជិតផ្ទះ ជនរងគ្រោះបានធ្វើដំណើរទៅប្រទេសវៀតណាមដើម្បីទទួលបាននូវការព្យាបាលត្រឹមត្រូវ ក្នុងករណីដែលមានប្រាក់គ្រប់គ្រាន់សម្រាប់ទទួលបានការព្យាបាល ។ បញ្ហាមួយទៀតនោះ គឺកង្វះការថែទាំសុខភាពរយៈពេលវែង ។ នាពេលបច្ចុប្បន្ន អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត សហការជាមួយមជ្ឈមណ្ឌលវះកាត់កុមារ[២១] (CSC) ជាកន្លែងតែមួយគត់នៅកម្ពុជាដែលផ្តល់សេវាកម្មតាមដានស្ថានភាពជំងឺក្នុងរយៈពេលវែងសម្រាប់ការរលាកទឹកអាស៊ីត ។[២២] អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីតបានពុករណីដែលប្រជាជនទៅរកគ្រូខ្មែរបុរាណដើម្បីព្យាបាល (អាចមកពីពួកគាត់ មិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទទួលបាននូវការព្យាបាលតាមបែបវេជ្ជសាស្រ្តត្រឹមត្រូវ) ដោយប្រើប្រាស់ជ័រទៅលាបលើមុខរបួស ហើយប្រើស្លឹកចេករុំមុខរបួស ដែលការធ្វើរបៀបនេះ អាចបង្កការឆ្លងមេរោគធ្ងន់ធ្ងរ ។ កង្វះជំនាញ ចំណេះដឹង និងឧបករណ៍ចាំបាច់ក៏អាចជាកត្តាដែល នាំឲ្យសភាពជំងឺកាន់តែធ្ងន់ធ្ងរ និងអាចប៉ះពាល់ដល់អាយុជីវិតជនរងគ្រោះដែរ ។

ការរលាកទឹកអាស៊ីត អាចបណ្តាលឲ្យមានបញ្ហាសុខភាពក្នុងរយៈពេលវែង ឬមួយអាចពេញមួយជីវិតក៏ថាបាន ។ បញ្ហាសុខភាពទាំងនោះរួមមាន ខ្វាក់មួយជីវិត ការខូចខាតផ្នែកខ្លះនៃចក្ខុវិញ្ញាណស្តាប់មិនសូវលឺ ខូចទម្រង់មុខមាត់ មានសម្លាកអស់មួយជីវិត រួញនិងខូចទ្រង់ទ្រាយរូបរាងកាយការឈឺចាប់ផ្លូវចិត្ត និងពិការ ។[២៣] យោងតាមអង្គការសុខភាពពិភពលោក ដែលហៅកាត់ថា (WHO) ជនរងគ្រោះត្រូវចំណាយប្រាក់កាក់ច្រើនសម្រាប់សម្រាកព្យាបាលជំងឺយូរ ។[២៤] លោកវេជ្ជបណ្ឌិត រ៉ូណាល់ ហៀលស៍ (Ronald Hiles) ដែលជាពេទ្យវះកាត់នាំមុខមានបទពិសោធន៍ក្នុងការវះកាត់របួសដោយទឹកអាស៊ីតជាង២៥ឆ្នាំ បានប្រសាសន៍ថា ស្បែកដែលរលាកស្លាប់ត្រូវតែកាត់ចោល ក្នុងអំឡុងពេលពី ៤ទៅ៥ថ្ងៃ បើពុំដូច្នោះទេ ស្បែកថ្មីដែលដុះចេញលុបលើស្បែកដែលបានងាប់ដែលនឹង

---

[២០] មានមន្ទីរពេទ្យព្រះកុសមៈ មន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យព្រះសីហនុ មជ្ឈមណ្ឌលនៃក្តីសង្ឃឹម ។

[២១] មើលគេហទំព័រ www.csc.org សម្រាប់ព័ត៌មានទាក់ទងនឹងមជ្ឈមណ្ឌលវះកាត់កុមារ ។

[២២] បទសម្ភាសន៍ជាមួយវេជ្ជបណ្ឌិត វណ្ណា ជាវេជ្ជបណ្ឌិតនៅមជ្ឈមណ្ឌលវះកាត់កុមារ ។

[២៣] អត្ថបទដែលមានចំណងជើងថា *Breaking the Silence*, មើលកំណត់ចំណាំលេខ ៦, នៅទំព័រ៥ ។

[២៤] M. Peck, J. Molnar & D. Swart, ដកស្រង់ចេញពីអត្ថបទ *A Global Plan for Burn Prevention and Care*, ៨៧ BULLETIN OF THE WORLD HEALTH ORG., ៨០២ (២០០៩) ។

អាចបង្កជាផ្លែ និងខូចទ្រង់ទ្រាយ ។ នៅក្នុងករណីដែលជនរងគ្រោះរលាកនៅត្រង់ក និងក្លៀក ស្បែកដែលរលាកនៅផ្នែកទាំងពីរនោះត្រូវតែកាត់ចោល ដើម្បីជួយឲ្យជនរងគ្រោះអាចធ្វើចលនាបាននៅត្រង់ម្តុំនោះ ។ ការខូចរាងកាយ និងមានដុំសាច់ផ្លែ អាចប៉ះពាល់ដល់ការធ្វើចលនា ដែលនាំអាចធ្វើឲ្យជនរងគ្រោះពិការ ។[២៥]

អ្នកដែលរួចជីវិតពីការរលាកទឹកអាស៊ីត ត្រូវតែទទួលបានការវះកាត់ជាដំណាក់កាលដែលត្រូវចំណាយពេលរាប់ខែ ឬរាប់ឆ្នាំដើម្បីការពារកុំឲ្យខូចធ្ងន់ធ្ងរ ពិការភាព និងដើម្បីជួយឲ្យសរីរាង្គមានដំណើរការដូចធម្មតាវិញ ។[២៦] លើសពីនេះទៀត ជនរងគ្រោះត្រូវការលំហាត់ប្រាណដើម្បីឲ្យជាលិកាសម្លាកអាចបត់បែនបានយឺត ព្រមទាំងអាចធ្វើចលនាបាន ។ ជនរងគ្រោះត្រូវការស្បែករុំមុខរបួស (skin graft) និងកំណាត់រុំសម្ពាធ (pressure garment) ដែលកាត់ឲ្យសមនឹងទំហំខ្លួន ។ ក្នុងករណីដែលជនរងគ្រោះជាកុមារ នោះពួកគេនឹងអាចជួបប្រទះបញ្ហាប្រឈមកាន់តែធ្ងន់ ដោយសារកុមារស្ថិតក្នុងវ័យលូតលាស់ដែលទាមទារឲ្យមានការវះកាត់ ច្រើនដំណាក់កាលជាងមនុស្សវ័យជំទង់ ។ សារពាង្គកាយកុមារលូតលាស់ ប៉ុន្តែ ស្បែករុំរបួស និងសម្លាកមិនមានការលូតលាស់ដូចសារពាង្គកាយកុមារនោះទេ ចំណុចនេះនាំឲ្យមានបញ្ហាក្នុងការធ្វើចលនា ។[២៧] ការវះកាត់ចាំបាច់ក្នុងរយៈពេលវែង ទាមទារឲ្យមានការចំណាយប្រាក់ជាច្រើនសម្រាប់ការថែរក្សាសុខភាពក្នុងរយៈពេលច្រើនឆ្នាំ ។ ប៉ុន្តែ ដូចដែលលោកវេជ្ជបណ្ឌិត ហៀលស៍ បានពន្យល់ “*ទោះបីជាជនរងគ្រោះទទួលបានការវះកាត់ និងការថែទាំសុខភាពក្រោយពេលវះកាត់ល្អបំផុតក៏ដោយ ក៏ការស្រោចស្រង់ទម្រង់មុខ និងការធ្វើចលនាដូចដើមទាំងស្រុងនោះគឺស្ទើរតែមិនអាចទៅរួចតែម្តង*” ។[២៨]

ក្រៅពីបញ្ហាផ្នែករូបរាងកាយ អំពើហិង្សាដោយទឹកអាស៊ីត ក៏អាចធ្វើឲ្យមានផលប៉ះពាល់ផ្សេងៗទៀតផង ដូចជាបញ្ហាសតិអារម្មណ៍ធ្ងន់ធ្ងរ និងការទទួលរងរបួសផ្លូវចិត្ត ។[២៩] អ្នករស់រានមានជីវិតខ្លះត្រូវការជំនួយស្មារតីដើម្បីប្រឈមមុខនឹងរបួសផ្លូវចិត្តដែលជួបប្រទះ ។ ជនរងគ្រោះខ្លះអាចរងគ្រោះដោយភាពតានតឹងផ្លូវចិត្តដែលជាដើមហេតុនៃការយល់សប្តិអាក្រក់ ការថប់អារម្មណ៍ តានតឹង

---

[២៥] ដូចខាងលើ ។

[២៦] អត្ថបទដែលមានចំណងជើងថា *Breaking the Silence* មើលកំណត់ចំណាំលេខ ៦, ទំព័រ ៥ ។

[២៧] បទសម្ភាសន៍ជាមួយលោកវេជ្ជបណ្ឌិត រ៉ូណាល់ ហៀលស៍ ។

[២៨] ដូចខាងលើ ។

[២៩] អត្ថបទដែលមានចំណងជើងថា *Breaking the Silence* មើលកំណត់ចំណាំលេខ ៦, ទំព័រ ៥ ។

ផ្លូវចិត្ត និងធ្លាក់ទឹកចិត្ត ។[៣០] រោគសញ្ញាផ្សេងទៀតរួមមានជំងឺភ័យខ្លាច ដោយគ្មានមូលហេតុ ជំងឺហូបច្រើនខុសពីធម្មតា ការបាត់បង់ជំនឿចិត្តលើខ្លួន និងការប្រើប្រាស់ សារធាតុញៀន ឬព្រងើយកន្តើយ ។[៣១] បញ្ហាទាំងនេះទាមទារឲ្យមានការថែទាំយ៉ាងសមរម្យដែលអ្នកធ្វើការ សង្គម និងចិត្តវិទូអាចផ្តល់ឲ្យបាន ។

## ២.២. ផលវិបាកមិនមែនវេជ្ជសាស្ត្រ

ការរលាកទឹកអាស៊ីតអាចប៉ះពាល់ដល់ជីវភាពរបស់ជនរងគ្រោះ ហើយជាពិសេសនោះគឺអ្នកដែល មានជីវភាពខ្វះខាតខ្សោយ ។ ជនរងគ្រោះអាចនឹងពិការ រហូតដល់ថ្នាក់មិនអាចធ្វើការបាន ឬមិនអាច រកការងារបានធ្វើ ដោយសារនិយោជកមួយចំនួនមិនយកជនពិការមកធ្វើការ ។[៣២] នៅក្នុងករណីដែលជនរងគ្រោះជាមេគ្រួសារ ក្រុមគ្រួសារទាំងមូលនឹងខ្វះបុគ្គលដ៏សំខាន់ដើម្បីជ្រោមជ្រែង និង(ភាគច្រើន ជាប្តី ឬឪពុក) ផ្គត់ផ្គង់គ្រួសារ ។ បញ្ហានេះអាចនាំឲ្យប្រពន្ធ ឬម្តាយជនរងគ្រោះដើរតួជាអ្នកគ្រប់គ្រងគ្រួសារទាំងមូលជំនួសវិញ ។ យោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក ប្រសិនបើជា ជនរងគ្រោះស្ថិតក្នុងគ្រួសារក្រខ្សត់ ស្ថានភាពហិរញ្ញវត្ថុរបស់គ្រួសារជនរងគ្រោះនឹងកាន់តែលំបាកលំបិន ជាងមុនទៅទៀត ក្រោយពីជាសះស្បើយពីការរងគ្រោះ ។[៣៣]

ការខូចរូបរាងកាយ ផ្តល់ផលលំបាកដល់ជនរងគ្រោះហួសពីបន្ទុកហិរញ្ញវត្ថុទៅទៀត ។ បញ្ហានេះអាចនាំឲ្យមានការលែងរាប់រកពីសង្គម ការបន្ទាបបន្ថោកតម្លៃ និងមិនឲ្យចូលរួមក្នុងសហគមន៍ សូម្បីតែនៅក្នុងបណ្តាញគ្រួសាររបស់ខ្លួនផ្ទាល់ក៏ដោយ ។[៣៤] នៅក្នុងករណីខ្លះ សហគមន៍នឹងលែងរាប់រកជនរងគ្រោះ ក្រោយពីជនរងគ្រោះទទួលរងនូវការវាយប្រហារ ដោយសារតែការខូចរាងកាយ និងពិការភាព ។ ការរើសអើងនេះឯងនាំឲ្យ ជនរងគ្រោះទទួលរងទុក្ខវេទនាកាន់តែខ្លាំង ព្រមទាំងនាំ

---

[៣០] Peck, *មើលកំណត់ចំណាំលេខ២៨*, ទំព័រ ៨០២ ។

[៣១] Welsh, *មើលកំណត់ចំណាំលេខ៥*, ទំព័រ ២០ ។

[៣២] អត្ថបទដែលមានចំណងជើងថា *Breaking the Silence*, *មើលកំណត់ចំណាំលេខ ៦*, នៅលេខ ៧; H. Shah, អត្ថបទដែលមានចំណងជើងថា *Brutality by Acid: Utilizing Bangladesh as a Model to Fight Acid Violence in Pakistan*, ២៦ WIS. INT'L L.J. ១១៧២, ១១៧៨ (២០០៨-២០០៩) ។

[៣៣] Peck, *មើលកំណត់ចំណាំលេខ២៨*, ទំព័រ ៨០២ ។

[៣៤] ដូចខាងលើ ។

*ឲ្យមានតម្លៃសង្គម និងតម្លៃសេដ្ឋកិច្ចបន្ថែមទៀត ។*[៣៥] *ឧទាហរណ៍ នាង ច.ច បានទទួលរងការវាយប្រហារដោយទឹកអាស៊ីតនៅឆ្នាំ២០០៨ ហើយការវាយប្រហារនេះ បានធ្វើឲ្យនាង ចច ពិការភ្នែក និងខូចរាងកាយយ៉ាងធ្ងន់ធ្ងរ ។ អ្នកជិតខាងមិនរាប់រកនាងហើយថែម ទាំងហៅនាងថា«ខ្មោច» ។*[៣៦] *ដូចគ្នាដែរ នៅប្រទេសបង់ក្លាដេស មុខមាត់ដែលមានសម្លាកបន្សល់ទុកពីការរលាកទឹកអាស៊ីត ត្រូវបានគេចាត់ទុកថាជាប្រផ្នូលអាក្រក់ ។ ដោយសារសង្គមបង់ក្លាដេសផ្តល់តម្លៃឲ្យស្ត្រីដែលមានសមត្ថភាពទទួលបានអាពាហ៍ពិពាហ៍ល្អ*[៣៧] *ការខូចមុខមាត់ និងរូបរាងកាយដោយទឹកអាស៊ីត ដែលនាំឲ្យស្ត្រីបាត់បង់ឱកាសក្នុងការរៀបអាពាហ៍ពិពាហ៍ ស្ត្រីទាំងនោះបាត់បង់តម្លៃនៅក្នុងផ្នត់គំនិតសង្គម និងជួនកាលនៅក្នុងផ្នត់គំនិតរបស់គ្រួសារខ្លួនឯងផ្ទាល់ ។*

*លោក ហ្សៀត សាមមេន* (Ziad Samman) *ប្រធានគម្រោងនៃមូលនិធិជនរងគ្រោះដោយទឹកអាស៊ីតកម្ពុជា មានប្រសាសន៍ថា នៅកម្ពុជា គ្រួសារគឺជាបណ្តាញគាំទ្រយ៉ាងសំខាន់សម្រាប់ជនរងគ្រោះនៃការវាយប្រហារដោយទឹកអាស៊ីត ។ ប្រសិនបើជាក្រុមគ្រួសារមានឆន្ទៈក្នុងការជួយជនរងគ្រោះ ការជាសះស្បើយរបស់ជនរងគ្រោះ នឹងមានលទ្ធផលគួរឲ្យកត់សម្គាល់ជាមិនខាន ។ ប៉ុន្តែគួរឲ្យសោកស្តាយ ក្នុងករណីខ្លះ ក្រុមគ្រួសារបានចាត់ទុកជនរងគ្រោះជាបន្ទុកផ្នែកសេដ្ឋកិច្ច ឬសង្គម ហើយប្រព័ន្ធគាំទ្រទាំងមូលត្រូវ បរាជ័យ ដែលនាំឲ្យមានផលប៉ះពាល់អវិជ្ជមានដល់អនាគតជនរងគ្រោះ ។ ជនរងគ្រោះ ជាស្ត្រីម្នាក់ ដែលចង់ទទួលបានការវះកាត់ដែលផ្តល់ឲ្យដោយអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត និងមជ្ឈមណ្ឌលវះកាត់កុមារ ។ ការវះកាត់នេះ មានសារៈសំខាន់ដើម្បីសម្រួលដល់ការ ធ្វើចលនារបស់គាត់ ក៏ប៉ុន្តែក្រុមគ្រួសាររបស់គាត់បានបដិសេធមិនអនុញ្ញាតឲ្យវះកាត់ដោយខ្លាចថាពួកគេនឹង ត្រូវមើលថែគាត់នៅក្នុងអំឡុងពេលព្យាបាល ។ ការរងគ្រោះផ្លូវចិត្ត និងការបន្ទាបបន្ថោកក្នុងសង្គម គឺជាកត្តាពីរដែលធ្វើឲ្យជនល្មើសសម្រេចចិត្តជ្រើសរើសយកការវាយប្រហារដោយទឹកអាស៊ីត ។*

---

[៣៥] Shah, *មើលកំណត់ចំណាំលេខ៣២, ទំព័រ ១១៨៧*; D. Otis, Healing Burns, *អត្ថបទដែលមានចំណងជើងថា* Treating physical and mental scars at the Cambodian Acid Survivors Charity, *នៅក្នុងទស្សនាវដ្តី* *Southeast Asia Globe* មិនា *២០១៣, ទំព័រ ៨៤ ។*

[៣៦] *បទសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីការរលាកទឹកអាស៊ីត នាង ច.ច ។*

[៣៧] Sital Kalantry **&** Jocelyn Getgen Kestenbaum, *ដកស្រង់ចេញពីអត្ថបទ* *Combatting Acid Violence in Bangladesh, India and Cambodia, Avon Global Center for Women and Justice and Dorothea S. Clarke Program in Feminist Jurisprudence.* *អត្ថបទទី១ នៅទំព័រ២២*, *អាចរកបាននៅគេហទំព័រ*: http://scholarship.law.cornell.edu/avon_clarke/1 *(ខែមករា ឆ្នាំ២០១១) ។*

## ២.៣. ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល

នៅប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន អង្គការក្រៅរដ្ឋាភិបាលបានបំពេញមុខងារក្នុងការជួយគាំទ្រ ជ្រោមជ្រែងជនរងគ្រោះ និងប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាដោយទឹកអាស៊ីត ជាពិសេសនៅពេលដែលរដ្ឋាភិបាលមិនអាច ឬគ្មានឆន្ទៈក្នុងការធ្វើការងារនេះ ។[៣៨] អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត ជាឧទាហរណ៍តែមួយគត់នៅកម្ពុជាដែលប្តេជ្ញាជាពិសេស ក្នុងការធ្វើការជាមួយនឹងជនរងគ្រោះ និងសាច់ញាតិជនរងគ្រោះនៃអំពើហិង្សាដោយទឹកអាស៊ីត ។ អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងកង្វះសេវាកម្ម និងការថែរក្សាសុខភាពសម្រាប់ជនរងគ្រោះដោយការរលាកទឹកអាស៊ីត ។[៣៩] អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត បានផ្តល់សេវាកម្ម ចំនួន៤ប្រភេទដែលរួមមាន ការព្យាបាលបែបវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ, ការហ្វឹកហ្វឺនវិជ្ជាជីវៈ និងសមាហរណកម្មសង្គម, ការផ្តល់ប្រឹក្សានិងជ្រោមជ្រែងផ្នែកច្បាប់ដើម្បីកំណែទម្រង់ច្បាប់, លើកម្ពស់ការយល់ដឹងការស្រាវជ្រាវ, ការអប់រំ និងការតស៊ូមតិលុបបំបាត់អំពើហិង្សាដោយទឹកអាស៊ីត ។[៤០] រាល់សេវាកម្មដែលផ្តល់ឲ្យជនរងគ្រោះដោយការ វាយប្រហារ និងគ្រោះថ្នាក់ដោយទឹកអាស៊ីតទាំងអស់ពុំមានគិតកម្រៃទេ ។

នៅទូទាំងពិភពលោក អង្គការថ្នាក់ជាតិតែមួយចំនួនប៉ុណ្ណោះ ដែលប្តេជ្ញាក្នុងការទប់ស្កាត់អំពើហិង្សាដោយទឹកអាស៊ីត និងជ្រោមជ្រែងអ្នករស់រានមានជីវិតពីឧប្បត្តិហេតុពាក់ព័ន្ធនឹងទឹកអាស៊ីត ។ អង្គការដែលបានដើរតួសំខាន់ជាងគេនោះគឺ មូលនិធិជនរងគ្រោះដោយទឹកអាស៊ីត (Acid Survivors

---

[៣៨] Welsh, *មើលកំនត់ចំណាំលេខ៩*, ទំព័រ ៤៣ ។

[៣៩] អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត (CASC) ត្រូវបានបង្កើតឡើងដោយ មជ្ឈមណ្ឌលវះកាត់កុមារ (CSC) ដែលជាមណ្ឌលសុខភាពមួយដែលផ្តល់សេវាកម្មសុខភាពឲ្យជនរងគ្រោះ ដោយទឹកអាស៊ីតដោយមិនគិតថ្លៃ ។ ប៉ុន្តែដោយ មជ្ឈមណ្ឌលវះកាត់កុមារ (CSC) ជាមជ្ឈមណ្ឌលសម្រាប់ការវះកាត់ទូទៅ មជ្ឈមណ្ឌលនេះមិនទាន់អាចបំពេញតម្រូវការរបស់ជនរងគ្រោះលើសពីការព្យាបាលបែបវេជ្ជសាស្ត្របានទេ ។ ដោយសារបានយល់ឃើញតម្រូវការក្នុងការជ្រោមជ្រែងជនរងគ្រោះដោយទឹកអាស៊ីត ក្នុងការជាសះស្បើយ និងចូលរួមសង្គមវិញ មជ្ឈមណ្ឌលវះកាត់កុមារ (CSC) បានបង្កើត អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត (CASC) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្នែកផ្លូវកាយ ផ្លូវចិត្ត និង ហិរញ្ញវត្ថុក្នុងរយៈពេលយូរអង្វែងរបស់ជនរងគ្រោះដោយទឹកអាស៊ីត ។

[៤០] ពត៌មានបន្ថែមពាក់ព័ន្ធនឹងកិច្ចការរបស់ អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត (CASC) អាចរកបាននៅគេហទំព័រ: http://www.thecasc.org

Foundation (ASF)) នៅប្រទេសបង់ក្លាដេស, ASF ប៉ាគីស្ថាន, ASF យូហ្គាន់ដាន, ASF ឥណ្ឌា និង Burn Violence Survival (BVS) ។[៤១] នៅក្នុងកម្រិតសកលលោកវិញ អង្គការមានតែមួយគត់ដែលផ្តោតការងារជាពិសេសលើ អំពើហិង្សាដោយទឹកអាស៊ីតៈ មូលនិធិអន្តរជាតិសម្រាប់អ្នករស់ជីវិតពីទឹកអាស៊ីត (Acid Survivors Trust International (ASTI)) ។[៤២] ការដែលមានតែអង្គការថ្នាក់ជាតិមួយចំនួនតូច និងអង្គការអន្តរជាតិតែមួយគត់ធ្វើការងារលើបញ្ហានេះ បានបង្ហាញអំពីការខ្វះខាតនូវការយកចិត្តទុកដាក់លើបញ្ហា អំពើហិង្សាដោយទឹកអាស៊ីត ។ បើយោងតាម ឆាធើជី (Chatterjee) មុនឆ្នាំ១៩៩៩ ការយកចិត្តទុកដាក់ មានតិចតួចប៉ុណ្ណោះចំពោះបញ្ហាអំពើហិង្សាដោយប្រើប្រាស់ទឹកអាស៊ីត ប៉ុន្តែ ក្រោយពីការបង្កើតមូលនិធិជនរងគ្រោះដោយទឹកអាស៊ីត (ASF) បញ្ហាអំពើហិង្សាដោយទឹកអាស៊ីត ក៏បានបង្ហាញខ្លួនច្រើនជាងមុននៅក្នុងរបៀបវារៈនយោបាយ ។[៤៣] ទោះជាយ៉ាងណាក៏ដោយ ពុំមានការស្រាវជ្រាវច្រើនបានធ្វើពាក់ព័ន្ធនឹងប្រធានបទនេះទេ ។ អត្ថបទភាគច្រើនតែងផ្តោតទៅលើការវាយប្រហារដោយបុគ្គល ដោយមិនបានពិនិត្យមើលហេតុផលនៅពីក្រោយការវាយប្រហារដោយទឹកអាស៊ីត និង ការលំបាកផ្នែកផ្លូវច្បាប់ដែលអ្នករួចរស់ជីវិតពីការរលាកទឹកអាស៊ីតជួបប្រទះទេ ។[៤៤]

## ៣. អំពើហិង្សាដោយទឹកអាស៊ីតនៅកម្ពុជា – កត្តារួមចំណែកចំនួនបួន

ហេតុផលមួយចំនួនបានរួមចំណែកដល់ឧបទ្ទវហេតុដោយទឹកអាស៊ីតនៅកម្ពុជា ។ ហេតុផលសង្គមវប្បធម៌ ស្ថានការណ៍ និងសូម្បីតែហេតុផលជាក់ស្តែង អាចជានាំទៅដល់ការជ្រើសរើសយកទឹកអាស៊ីតមកធ្វើការវាយប្រហារ ។ ប៉ុន្តែ មិនមែនគ្រប់ឧបទ្ទវហេតុទាំងអស់សុទ្ធតែជាការវាយប្រហារនោះទេ ហើយជាក់ស្តែង ការរងរបួសដោយទឹកអាស៊ីតជាច្រើនត្រូវបានបង្កឡើងដោយការគ្រោះថ្នាក់ ។ ផ្នែកនេះនឹងធ្វើការពិនិត្យមើលលើទំហំនៃបញ្ហា និងពិភាក្សាលើកត្តាដែលនាំទៅដល់ឧបទ្ទវហេតុដោយចេតនា ឬដោយគ្រោះថ្នាក់ជាមួយទឹកអាស៊ីត ។

---

[៤១] ពត៌មានបន្ថែមពាក់ព័ន្ធនឹងអង្គការទាំងអស់នេះសូមមើលគេហទំព័រ: http://www.acidsurvivors.org (បង់ក្លាដេស); http://acidsurvivorspakistan.org (ប៉ាគីស្ថាន); http://www.acidsurvivorsug.org (យូហ្គាន់ដាន); http://www.asfi.in (ឥណ្ឌា); http://www.bvsnepal.org.np (នេប៉ាល់) ។

[៤២] សម្រាប់ពត៌មានបន្ថែមពាក់ព័ន្ធនឹង ASTI សូមមើលគេហទំព័រ http://www.acidviolence.org

[៤៣] Chatterjee, មើលកំណត់ចំណាំលេខ១៩, ទំព័រ ៧ ។

[៤៤] Welsh, មើលកំណត់ចំណាំលេខ៥, ទំព័រ ៥ - ៦ ។

## ៣.១. ស្ថិតិ

អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត បានរក្សាទុកទិន្នន័យអំពីឧបទ្ទវហេតុពាក់ព័ន្ធនឹងទឹកអាស៊ីតទាំងអស់នៅកម្ពុជា ដែលត្រូវបានបញ្ចូលសំណុំរឿងថ្មី និងបន្ថែមព័ត៌មានថ្មីរបស់ឧបទ្ទវហេតុចាស់ ។ ការវាយប្រហារដែលបានកត់ត្រាជាលើកដំបូងបានកើតឡើងនៅឆ្នាំ១៩៦៤ នៅទីក្រុងភ្នំពេញ គិតត្រឹមពេលសរសេរអត្ថបទនេះ ឧបទ្ទវហេតុសរុបចំនួន៣១៨ករណី និងបុគ្គលចំនួន៤០១នាក់ត្រូវបានកត់ត្រា ។ តួរលេខទាំងនេះរួមមានជនរងគ្រោះចំនួន១៤នាក់ ដែលមានរបួសធ្ងន់ដល់ជីវិត និង(ប៉ុនប៉ង) អត្តឃាតចំនួន៦នាក់ ។ នៅក្នុងចំណោមជនរងគ្រោះពេញវ័យ ជនរងគ្រោះចំនួន១៦០នាក់ជាបុរស និងចំនួន១៧៦នាក់ជាស្ត្រី ។ ជាងនេះទៅទៀត ជនរងគ្រោះជាក្មេងប្រុសមានចំនួន២៩នាក់ និងក្មេងស្រីចំនួន៣២នាក់ មានអាយុក្រោម១៣ឆ្នាំ ដែលអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត បានដឹងថាបានទទួលរងរបួសដោយសារទឹកអាស៊ីត ។[៤៥]

ឧបទ្ទវហេតុដែលបានកត់ត្រាស្ទើរតែទាំងអស់ ចំនួន២២៤ករណី បានកើតឡើងនៅអំឡុងទសវត្សរ៍ឆ្នាំ២០០០ ។[៤៦] អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត ជួបការលំបាកជាខ្លាំងក្នុងការស្វែងរកទិន្នន័យពីទសវត្សរ៍មុនៗ ។ គ្មានការិយាល័យរដ្ឋាភិបាល ឬអង្គការណាមួយបានធ្វើកំណត់ត្រាស្ដីពីឧបទ្ទវហេតុពាក់ព័ន្ធនឹងអាស៊ីតបានជាប់លាប់ទេ ។ តាមការពិត រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានទាក់ទងមកអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត ដើម្បីស្នើសុំព័ត៌មាន និងស្ថិតិនៃអំពើហិង្សាដោយទឹកអាស៊ីត និងឧបទ្ទវហេតុពាក់ព័ន្ធនឹងទឹកអាស៊ីតទៅវិញ ។

---

[៤៥] ទិន្នន័យដែលបានបង្ហាញខាងលើគឺជាទិន្នន័យដែលបានទទួលបានពី CASC ។ នៅក្នុងទិន្នន័យរបស់ CASC កុមារគឺគិតចាប់ពីអាយុ១៣ឆ្នាំចុះក្រោម ។ បើទោះជាអាយុពេញច្បាប់របស់មនុស្សពេញវ័យនៅកម្ពុជាគឺ ១៨ឆ្នាំក៏ដោយ យោងតាមទំនៀម ទម្លាប់ ប្រពៃណី និងវប្បធម៌ បើសិនជាមិនទាន់គ្រប់ការទេ នោះគេមិនចាត់ទុកជាមនុស្សពេញវ័យនោះទេ ។ ដូច្នេះ ដើម្បីឆ្លើយតបទៅនិងទិន្នន័យរបស់ CASC ដែលប្រើប្រាស់ក្នុងពេលសរសេរអត្ថបទនេះ ជនដែលមានអាយុ១៣ឆ្នាំចុះក្រោមត្រូវបានចាត់ទុកថាជាកុមារ ហើយជនដែលមានអាយុចាត់ពី ១៣ឆ្នាំឡើងលើត្រូវបានចាត់ទុកថាជាមនុស្សពេញវ័យ ។

[៤៦] មានឧប្បត្តិហេតុចំនួន១៦ករណីដែលមិនបានកត់ត្រាប្រាកដថាកើតឡើងនៅឆ្នាំណានោះទេ ។




តារាង ១. ចំនួនឧបទ្ទវហេតុ និងអ្នករស់ជីវិតនៅចន្លោះឆ្នាំ២០០០ និងបច្ចុប្បន្ន ។ កម្មសិទ្ធិរបស់អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត ។

អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត បានបែងចែកឧបទ្ទវហេតុជា១៣ប្រភេទដាក់លាក់៖ «គ្រោះថ្នាក់», «(ការប៉ុនប៉ង) ធ្វើអត្តឃាត», «ជម្លោះមុខជំនួញ», «ជម្លោះ», «អំពើហិង្សាក្នុងគ្រួសារ», «ជម្លោះក្នុងគ្រួសារ», «ការស្អប់», «ការប្រច័ណ្ឌ», «ជម្លោះដីធ្លី», «ការវាយប្រហារខុសគោលដៅ», «(ការយល់ថាមាន) អំពើផិតក្បត់», «អំពើលួចប្លន់» និង «មិនដឹង» ។[៤៧]




តារាង ២. កត្តាជំរុញពីក្រោយឧបទ្ទវហេតុពាក់ព័ន្ធនឹងអាស៊ីត ។ កម្មសិទ្ធិរបស់អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត ។

[៤៧] ទាំងនេះជាប្រភេទដែល CASC ប្រើប្រាស់ក្នុងទិន្នន័យស្តីអំពីអ្នករស់រានមានជីវិតពីការលោកទឹកអាស៊ីត ។

ដូចដែលបានបង្ហាញក្នុងទិន្នន័យខាងលើ ឧបទ្ទវហេតុយ៉ាងច្រើន(២៧ភាគរយ) ដែលមូលហេតុ (និង នៅក្នុងសំណុំរឿងជាច្រើន ជនដែលដល់) "មិនដឹង" ។ ជាងនេះទៅទៀត នៅក្នុង៤២ភាគរយនៃសំណុំរឿង"មិនដឹង" គេមិនអាចកំណត់បានថាតើឧបទ្ទវហេតុទាំងនោះជាការវាយប្រហារ ឬក៏ជាឧបទ្ទវហេតុទេ ដោយសារព័ត៌មានមិនគ្រប់គ្រាន់ប្រមូលពីភាគីទីបី កាសែត ឬមន្ត្រី និងភាពមិនអាចទំនាក់ទំនងបានជាមួយជនរងគ្រោះ ឬសាច់ញាតិ ។

ឧបទ្ទវហេតុដោយទឹកអាស៊ីតជាច្រើនករណី កើតឡើងក្នុងទម្រង់ជាគ្រោះថ្នាក់ ។ ក្នុងចំណោមជនរងគ្រោះទាំងអស់ដែលបានកត់ត្រាដោយអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត ២០,៧ ភាគរយ ទទួលរងរបួសដោយហេតុការណ៍គ្រោះថ្នាក់ ។ ចំនួនគ្រោះថ្នាក់ច្រើន និងមូលហេតុបែបនេះបង្ហាញឲ្យឃើញថា អាស៊ីតមិនត្រឹមតែមានវត្តមានជាធម្មតានៅតាមផ្ទះ និងកន្លែងធ្វើការទេ ប៉ុន្តែថែមទាំងបង្ហាញថា មនុស្សជាច្រើនមិនបានដឹងអំពីរបៀបប៉ះពាល់សារជាតិនេះតាមមធ្យោបាយដែលមានសុវត្ថិភាព និងសមរម្យ ។ ចំណែកឯការដឹកជញ្ជូនទឹកអាស៊ីត ពុំត្រូវបានធ្វើឡើងតាមបទដ្ឋានត្រឹមត្រូវឡើយ ទុកដាក់ទឹកអាស៊ីតនៅក្បែរដៃក្មេង និងពុំមានបិទស្លាកសម្គាល់ត្រឹមត្រូវទេ ។ លោកសាមមេន មានប្រសាសន៍ថា *"ប្រជាជនត្រូវដឹងពីវិធីទុកដាក់សារធាតុគ្រោះថ្នាក់នេះ ។ ប្រជាជនមិនយល់អំពីទំហំនៃអ្វីដែលសារធាតុអាចបង្ក"* ។[៤៨]

ការទុកដាក់ និងដឹកជញ្ជូនទឹកអាស៊ីតមិនបានត្រឹមត្រូវ គឺជាដើមហេតុដែលនាំឲ្យកើតមានឧបទ្ទវហេតុដោយទឹកអាស៊ីត ។ ក្នុងចំណោមអ្នករស់រានជីវិតចំនួន៦១នាក់ដែលរងគ្រោះនៅកន្លែងមានលក្ខណៈឯកជន អ្នករស់រានមានជីវិតប្រមាណជា២៦ភាគរយ បានទទួលរងគ្រោះពីការទុកដាក់ និងដឹកជញ្ជូនទឹកអាស៊ីតមិនបានត្រឹមត្រូវ ។ ទឹកអាស៊ីតតែងតែត្រូវគេទុកដាក់នៅកន្លែងសាធារណៈ ដោយច្រកចូលក្នុងធុងខូច ក្នុងថង់ប្លាស្ទិច ឬក្នុងដបទឹកសុទ្ធ ។ យ៉ាងហោចណាស់មាន៧ករណីដែលជនរងគ្រោះ ច្រឡំផឹកទឹកអាស៊ីតដោយគិតថាជាដបទឹកសុទ្ធ ដែលបណ្តាលឲ្យរលាកគ្រឿងក្នុងយ៉ាងធ្ងន់ធ្ងរ ។ ឧបទ្ទវហេតុខ្លះបានកើតឡើងដូចជា ដោយសារឪពុកម្តាយបានច្រកទឹកអាស៊ីតចូលទៅក្នុងដបទឹកសុទ្ធ ហើយកូនគាត់ច្រឡំថាជាទឹកធម្មតា និងបានផឹកទឹកអាស៊ីតនោះ, ទឹកអាស៊ីតត្រូវបានគេបោះចោលក្នុងគំនរសំរាម នៅពេលក្មេងប្រទះឃើញ យកមកលេង ក៏ទទួលរងការរលាក, ការដឹកទឹកអាស៊ីតក្នុងថង់ប្លាស្ទិច នៅពេលកំពុងធ្វើចរាចរ ហើយមានគ្រោះថ្នាក់ចរាចរណ៍ បណ្តាលឲ្យ

---

[៤៨] កិច្ចសម្ភាសន៍ជាមួយលោក ហ្សៀត សាមមេន (Ziad Samman), ប្រធានគម្រោងរបស់ CASC ។

កំពប់អាស៊ីតចេញមកក្រៅធ្វើឲ្យ រលាក, និងអ្នកខ្លះមានការធ្វេសប្រហែសដាក់ទឹកអាស៊ីតនៅក្បែរក្រែ រួចក៏ប្រែខ្លួនទៅប៉ះ បណ្តាលឲ្យកំពប់អាស៊ីត កំពប់នៅពេលកំពុងសម្រាន្ត ។ នៅក្នុងចំណោមឧបទ្ទវហេតុ ដែលបានរាយការណ៍ ឧបទ្ទវហេតុ ចំនួន៧៤ភាគរយ បានកើតឡើងនៅកន្លែងមានលក្ខណៈឯកជន និង២៥ភាគរយទៀតបានកើតឡើង នៅក្នុងពេលធ្វើការ ឬនៅក្នុងកន្លែងធ្វើការ ។ ឧបទ្ទវហេតុ ភាគច្រើន និងផលវិបាកមួយជីវិតដែលបន្តឡើងដោយឧបទ្ទវហេតុទាំងនោះ អាចបញ្ចៀសបាន ប្រសិនបើមានការការពារសុវត្ថិភាព និងគោរព តាមមាត្រដ្ឋានសុខភាពត្រឹមត្រូវ ។

ក្រៅពីការវាយប្រហារ និងគ្រោះថ្នាក់ចៃដន្យ មានឧបទ្ទវហេតុពីរប្រភេទទៀតដែលកើតឡើង ពាក់ព័ន្ធនឹងទឹកអាស៊ីត ។ ទោះបីជាមានចំនួនតិច បើប្រៀបធៀបទៅនឹងករណីពីរប្រភេទផ្សេងទៀតក៏ ដោយ ការ(ប៉ុនប៉ង)ធ្វើអត្តឃាតដោយប្រើទឹកអាស៊ីតបានកើតឡើង ។ បើយោងទៅតាមទិន្នន័យ ដែលមាននៅក្នុងដៃ ជនរងគ្រោះចំនួនបួននាក់បានធ្វើអត្តឃាតដោយផឹកទឹកអាស៊ីត ហើយមាន ជនរងគ្រោះចំនួនពីរនាក់ទៀតបានប៉ុនប៉ងធ្វើអត្តឃាត ប៉ុន្តែនៅរស់ ។

អាស៊ីតគឺជាសារធាតុរាវ ដែលអាចបែកខ្ចាយនៅពេលត្រូវគេគប់ ដែលអាចធ្វើឲ្យគ្រោះថ្នាក់ ដល់អ្នកដែលនៅក្បែរនោះ ។ ដោយហេតុនេះហើយ ជនរងគ្រោះនៃអំពើហិង្សា ដោយទឹកអាស៊ីត មួយចំនួន ត្រូវបានចាត់ទុកជា“ការវាយប្រហារខុសគោលដៅ” ។ បើទោះបីជាការវាយប្រហារខុស គោលដៅ បានកើតឡើងនៅក្នុងអំឡុងពេលនៃវាយប្រហារ ការវាយប្រហារនេះត្រូវបានយកមក ពិភាក្សានៅក្នុងផ្នែកនេះ ព្រោះជនរងគ្រោះមិនត្រូវបានវាយប្រហារដោយចេតនា ។ ទាក់ទងនឹង ជនរងគ្រោះពេញវ័យ ចំនួនជនរងគ្រោះដោយការវាយប្រហារខុសគោលដៅមាន ប្រមាណជា ២០ភាគរយ ដែលជាចំនួនច្រើនបំផុតបន្ទាប់ពីករណី“មិនដឹង[មូលហេតុច្បាស់លាស់]” ។ ជនរងគ្រោះ ដោយការវាយប្រហារខុសគោលដៅមានចំនួនច្រើន ដោយសារទឹកអាស៊ីតពុំមានរើសអើងមនុស្សទេ ។ ដូចដែលបានពិភាក្សាខាងលើ នៅពេលខ្លះ ការវាយប្រហារដោយទឹកអាស៊ីតត្រូវបានធ្វើឡើងនៅទី សាធារណៈចង្អៀត ដូចជាទីផ្សារ ដែលនាំឲ្យមនុស្សច្រើននាក់ទទួលរងគ្រោះដោយសារទឹកអាស៊ីត ។ នៅពេលដែលមានមនុស្សច្រើននាក់ជិះលើម៉ូតូតែមួយ ដែលយើងតែងប្រទះឃើញនៅកម្ពុជា ប្រសិន បើមានគេជះទឹកអាស៊ីតទៅមនុស្សម្នាក់ក្នុងចំណោមអ្នកដែលជិះលើម៉ូតូ ទឹកអាស៊ីតនឹងទំនងជាបាចសាច ទៅលើអ្នកដទៃទៀតដែលកំពុងធ្វើដំណើរជាមួយគ្នា ។ មានឧទាហរណ៍មួយចំនួនដែលជាដើមហេតុនៃ កំណើនការវាយប្រហារខុសគោលដៅ ។ នៅខែមីនា ឆ្នាំ២០០៧ នៅខេត្តកំពង់ឆ្នាំង ការប៉ុនប៉ង វាយប្រហារលើនារីម្នាក់បានកើតឡើង ហើយមនុស្ស៩នាក់នៅក្បែរនារីនោះក៏បានទទួលរងរបួស ដោយកាវាយប្រហារផងដែរ ។ ចំណែកឯករណីមួយទៀតវិញ បុរសម្នាក់បានព្យាយាមសង្គ្រោះ

ម្តាយ នៅពេលមានការវាយប្រហារដោយទឹកអាស៊ីតលើម្តាយរបស់គាត់ ហើយកូនស្រីរបស់គាត់ត្រូវរលាកទឹកអាស៊ីត ដោយសារពួកគេដេកនៅដេកនៅក្បែរជីដូន ។ នៅពេលដែលបុរសនោះបីកូនស្រីទៅមន្ទីរពេទ្យ គាត់ក៏បានប៉ះទឹកអាស៊ីត ហើយទទួលរងការរលាកលើ ក ដៃ និងដងខ្លួន ។ បើទោះបីជាគាត់ខំព្យាយាមជួយសង្គ្រោះភ្លាមៗក៏ដោយ ម្តាយនិងកូនស្រីរបស់គាត់បានស្លាប់ក្រោយពីការវាយប្រហារដោយសាររបួសធ្ងន់ ។

ជនរងគ្រោះទាំងអស់ពុំមែនសុទ្ធតែជាមនុស្សពេញវ័យនោះទេ ។ កុមារក៏អាចក្លាយជាជនរងគ្រោះដោយសារអំពើហិង្សាដោយទឹកអាស៊ីត និងឧប្បត្តិហេតុពាក់ព័ន្ធនឹងទឹកអាស៊ីតដែរ ។ កុមារចំនួនច្រើន ប្រមាណជា៦១នាក់ បានរងគ្រោះដោយសារទឹកអាស៊ីត ប៉ុន្តែ ចំនួនច្រើននេះមិនមែនប្រាកដថាកុមាររងគ្រោះទាំងអស់សុទ្ធតែទទួលរងការវាយប្រហារដោយចេតនានោះទេ ។ កុមារជាច្រើននាក់ បានរងគ្រោះដោយសារតែការវាយប្រហារខុសគោលដៅ ។ ជាក់ស្តែង ការវាយប្រហារខុសគោលដៅប៉ះពាល់លើកុមារយ៉ាងវិសមាមាត្រ ។ ទឹកអាស៊ីតបានបាចសាចទៅលើពួកគេនៅពេលដែលជនល្មើសជះទឹកអាស៊ីតលើជនដែលជាគោលដៅនៃការវាយប្រហារ ធ្លាយប៉ះលើជនរងគ្រោះទាំងនោះនៅពេលពួកគេកំពុងបីដោយជនដែលជាគោលដៅនៃការវាយប្រហារ ឬនៅពេលដែលពួកគេដេកនៅលើគ្រែជាមួយជនដែលជាគោលដៅនៃការវាយប្រហារ ។

នៅក្នុងចំណោមកុមាររងគ្រោះ៦១នាក់ មានតែម្នាក់ប៉ុណ្ណោះដែលជាគោលដៅនៃការវាយប្រហារដោយទឹកអាស៊ីត ។ កុមារផ្សេងទៀតដែលរងគ្រោះដោយរលាក គឺទទួលរងរបួសដោយសារឧបទ្ទវហេតុ(៤១ភាគរយ), ដោយការវាយប្រហារខុសគោលដៅ(៤៤.៣ភាគរយ), និង/ឬ រងគ្រោះដោយពុំបានដឹងមូលហេតុច្បាស់(១៣.១ភាគរយ) ។ កុមាររងគ្រោះដែលត្រូវបានគេវាយប្រហារដោយចេតនាតែម្នាក់គត់នោះគឺកុមារ ភ.រ.អ៊ី ដែលមានអាយុ៣ឆ្នាំ ។ ជនល្មើសដែលជាអតីតគូស្នេហ៍របស់ម្តាយកុមាររងគ្រោះ បានលបវាយម្តាយកុមាររងគ្រោះនៅក្នុងផ្ទះ ដោយស្រោចទឹកអាស៊ីតលើម្តាយ ហើយក្រោយមកជនល្មើសក៏ចាប់ទាញកុមាររងគ្រោះ រួចស្រោចទឹកអាស៊ីតលើជើងកុមាររងគ្រោះបន្សល់ទុកសម្លាកឲ្យម្តាយកូនទាំងពីរអស់មួយជីវិត ។

នៅក្នុងករណីខ្លះ ជនរងគ្រោះដែលគេបម្រុងវាយប្រហារបានឱបកុមារជាប់ក្នុងដៃ ឬនៅអង្គុយលើម៉ូតូជាមួយគ្នា ហើយវត្តមានរបស់កុមារនេះមិនអាចបញ្ចៀសការវាយប្រហារពីសំណាក់ជនល្មើសបានទេ ។ ឧទាហរណ៍នៃការវាយប្រហារមួយទៀតនោះគឺករណីរបស់កុមារ ប.ច ដែលបច្ចុប្បន្ននេះ មានអាយុប្រាំពីរឆ្នាំ ដែលកាលពីអាយុ៣ឆ្នាំ កំពុងអង្គុយនៅពីមុខម្តាយរបស់កុមារីនេះ នៅពេល

ដែលម្តាយត្រូវគេស្រោចទឹកអាស៊ីតដោយជនល្មើស២រូប ។ កុមារី ប.ច បានទទួលរងរបួសជាទម្ងន់លើក្បាល មុខ ក ខ្លួន ហើយនឹងត្រូវវះកាត់ជាច្រើនលើកច្រើនសារនៅក្នុងដំណាក់កាលកំពុងលូតលាស់ ។

ចំណុចសំខាន់មួយពាក់ព័ន្ធនឹងស្ថិតិនៃគ្រោះថ្នាក់ដោយទឹកអាស៊ីត គឺគ្រោះថ្នាក់ជាច្រើនដែលពុំត្រូវបានរាយការណ៍ ។ បើយោងតាមលោក សាមមេន ការប៉ាន់ស្មានអំពីសភាព និងទំហំពិតប្រាកដនៃឧបទ្ទវហេតុដែលពាក់ព័ន្ធនឹងទឹកអាស៊ីតគឺជារឿងមួយដ៏លំបាក ។ ប៉ុន្តែ ដោយយោងតាមបទពិសោធន៍នៃការធ្វើបេសកកម្មផ្សព្វផ្សាយ សំណុំរឿងដែលចុះបញ្ជីនាពេលបច្ចុប្បន្ន មានចំនួនប្រមាណជា ២០ភាគរយនៃចំនួនពិតប្រាកដនៃឧប្បត្តិហេតុដែលបានកើតឡើងក្នុងមួយឆ្នាំប៉ុណ្ណោះ ។[៤៩] មានហេតុផលមួយចំនួនដែលពាក់ព័ន្ធនឹងការខកខានមិនបានរាយការណ៍ពីគ្រោះថ្នាក់ ទាំងឧបទ្ទវហេតុ និងការវាយប្រហារដោយទឹកអាស៊ីតៈ ប្រជាជនមិនដឹងថាពួកគាត់ត្រូវទាក់ទងទៅអ្នកណា ឬអង្គការណា ប្រជាជនរស់នៅតំបន់ដាច់ស្រយាល ពុំលទ្ធភាព ឬលទ្ធភាពតិចតួចក្នុងការទទួលបានការសង្គ្រោះផ្នែកវេជ្ជសាស្ត្រ និងពីសមត្ថកិច្ច ជនរងគ្រោះអាចមានភាពអាម៉ាស់ និងគិតថាពួកគាត់សមនឹងទទួលនូវអ្វីដែលបានកើតឡើង ។ ពួកគេភ័យខ្លាចទទួលរងការសងសឹកពីឧក្រិដ្ឋជន, ពួកគេខ្វះខាតថវិកា និង ធនធានដើម្បីទទួលបានការព្យាបាល ឬពួកគេយល់ឃើញថា ពួកគាត់អាចព្យាបាលស្នាមរបួសដោយខ្លួនឯងបាន ។ លើសពីនេះទៅទៀត ដោយសារមិនមានប្រព័ន្ធចុះបញ្ជីផ្លូវការនៅនឹងកន្លែងនៅឡើយ អ្នកផ្តល់សេវាកម្មសុខភាពបានចុះបញ្ជីអំពីការរលាក ប៉ុន្តែមិនបានចុះពីមូលហេតុនៃការរលាកនោះទេ ដែលនាំឲ្យមានការលំបាកក្នុងការចងក្រងទិន្នន័យដែលពេញលេញ ។[៥០] ការខកខានមិនបានរាយការណ៍ពីមូលហេតុនៃឧបទ្ទវហេតុពុំមែនកើតឡើងតែនៅកម្ពុជាទេ ។ អ្នកស្រាវជ្រាវបានប៉ាន់ប្រមាណថា នៅគ្រប់ប្រទេសដែលមានអំពើហិង្សាដោយទឹកអាស៊ីត ចំនួនពិតប្រាកដនៃករណីអំពើហិង្សា គឺច្រើនជាងចំនួនដែលបានចងក្រងទុកបច្ចុប្បន្ន ។[៥១] ការមិនរាយការណ៍ឲ្យបានគ្រប់គ្រាន់ មិនត្រឹមតែនាំទៅដល់ការយល់ដឹងមិនត្រឹមត្រូវអំពីទំហំពិតប្រាកដនៃបញ្ហានោះទេ វាក៏បង្ហាញពីការដែលថា អ្នករួចរស់ជីវិតជាច្រើនមិនបានទទួលនូវការថែទាំសមរម្យ ។

---

[៤៩] កិច្ចសម្ភាសន៍ជាមួយលោក ហ្សៀត សាមមេន (Ziad Samman), ប្រធានគម្រោង CASC ។

[៥០] ដូចខាងលើ ។

[៥១] Chatterjee, *មើលកំណត់ចំណាំលេខ ១៩*, ទំព័រ៧; Welsh, *មើលកំណត់ចំណាំលេខ ៥*, ទំព័រ ៣១-៣២; S. Shackle , ដកស្រង់ចេញពីអត្ថបទ Acid Attacks: *"I Couldn't Look at Myself, Let Alone Let Others Look at Me,"* THE NEW STATESMEN, ១៥ ខែមេសា ឆ្នាំ២០១៣, អាចរកបាននៅគេហទំព័រ: http://www.newstatesman.com/samira-shackle/2013/04/acid-attacks-i-couldnt-look-myself-let-alone-let-others-look-me.

## ៣.២. ការអាចរកទិញបាននូវទឹកអាស៊ីត និងផលប៉ះពាល់

ភាពងាយស្រួលក្នុងការរកទិញទឹកអាស៊ីត នៅកម្ពុជា មិនឥទ្ធិពលមិនអាចប្រកែកបាន លើចំនួននៃការវាយប្រហារដោយទឹកអាស៊ីតដែលបានកើតឡើង ។[៥២] អាស៊ីតអាចរកទិញបាន និងប្រើប្រាស់ជាទូទៅនៅស្ទើរតែគ្រប់ទីកន្លែង ។ អាស៊ីតស៊ុលភួរិច ត្រូវបានប្រើប្រាស់សម្រាប់ដាក់អាគុយម៉ូតូ និងនៅតាមផ្ទះដើម្បីផ្តល់ចរន្តអគ្គិសនី ។ ចំណែក អាស៊ីតអ៊ីដ្រូលិច ត្រូវបានប្រើប្រាស់ក្នុងតាមចម្ការកៅស៊ូ ។ អាស៊ីតនីទ្រិច មានសារៈប្រយោជន៍សម្រាប់ក្រូម៉េគ្រឿងអលង្ការ ។[៥៣] ម្យ៉ាងវិញទៀត ទឹកអាស៊ីតអាចប្រើសម្រាប់ជ្រលក់ពណ៌សម្លៀកបំពាក់ និងធ្វើឲ្យស្បែកសត្វឡើងក្រម៉ៅ ។ អាស៊ីតមួយលីត្រ មានតម្លៃប្រហែលជាមួយដុល្លារ ដែលអាចរកទិញបាននៅទីផ្សារ និងហាងជួសជុលម៉ូតូ ដែលការនេះមិនត្រឹមតែធ្វើឲ្យងាយស្រួលរកទិញប៉ុណ្ណោះទេ ថែមទាំងជាវត្ថុដែលមានតម្លៃថោកអាចរកទិញបានដោយស្របច្បាប់ទៀតផង ។[៥៤] បើយោងតាមមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អាស៊ីតជាសារធាតុម្យ៉ាងដែលអាចយកបានដោយពុំធ្វើឲ្យអ្នកដទៃចាប់អារម្មណ៍នោះទេ ។[៥៥] ដោយសារតែអាស៊ីតអាចរកបាននៅស្ទើរតែគ្រប់ទីកន្លែង សម្រាប់ការប្រើប្រាស់ផ្សេងៗច្រើនយ៉ាងនៅកម្ពុជា គ្រួសារជាច្រើនមានអាស៊ីតទុកនៅផ្ទះ និងនៅកន្លែងធ្វើការ ដែលធ្វើឲ្យអាស៊ីតក្លាយទៅជាអាវុធ«ងាយ» និងស្រួលរកនៅពេលមនុស្សម្នាក់ចង់ធ្វើបាបមនុស្សម្នាក់ទៀត ។

បើទោះបីជាអាស៊ីតអាចរកទិញបានដោយងាយក៏ដោយ ក៏ប្រជាពលរដ្ឋនៅខ្វះចំណេះដឹងពីផលប៉ះពាល់របស់អាស៊ីតនៅឡើយ ។ លោក សាមមេន បានធ្វើសេចក្តីពន្យល់ថា នៅក្នុងករណីខ្លះជនល្មើសពុំបានយល់ដឹងពីផលប៉ះពាល់ដែលអាចបណ្តាលដោយអាស៊ីតនោះទេ ហើយជាពិសេសនោះគឺក្នុងករណីអំពើហិង្សាដោយទឹកអាស៊ីតជាលក្ខណៈគ្រួសារ ។[៥៦] ជាឧទាហរណ៍ ស្ត្រីម្នាក់ដែលជះទឹកអាស៊ីតទៅលើប្តីរបស់ខ្លួន បានធ្វើឲ្យប្តីរបស់គាត់ពិការមួយជីវិត ។ អ្នកស្រី អ.ក បានជះទឹកអាស៊ីតទៅលើប្តីរបស់គាត់ដោយសារតែប្តីគាត់លួចមានស្រីក្រៅ ។ នៅក្នុងបទសម្ភាសន៍ គាត់បាននិយាយថា មនុស្សម្នាក់

---

[៥២] ដកស្រង់ចេញពីល្មោន Breaking the Silence, *មើលកំណត់ចំណាំលេខ១៦, ទំព័រ៨ ។*
បទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាតាមរយៈសារអេឡិចត្រូនិច ។

[៥៣] ដូចខាងលើ, មើលលេខ៥ ។

[៥៤] ដូចខាងលើ, មើលលេខ ៨ ។

[៥៥] បទសម្ភាសន៍ជាមួយបុគ្គលិក CCHR តាមរយៈសារអេឡិចត្រូនិច ។

[៥៦] កិច្ចសម្ភាសជាមួយលោក ហ្សៀត សាមមេន (Ziad Samman), ប្រធានគម្រោង CASC ។

ប្រាប់គាត់ថា«អាស៊ីតអាចបំផ្លាញរូបសម្បត្តិ» ហើយគាត់គិតថា នោះមានន័យថា ប្តីគាត់នឹងលែងសូវមានភាពទាក់ទាញដូចមុន ។ ប៉ុន្តែ គាត់មិនបានដែលមិនបានដឹងថា ការនេះកើតឡើងដោយសារតែការរលាក និងស្នាមសម្លាកធ្ងន់ធ្ងរឡើយ ។ អ្នកស្រី អ.ក បានបន្ថែមថា គាត់ក៏មិនដែលដឹងថាអាស៊ីតរលាកនោះទេ ព្រោះ«*ពេលដែលកាន់ទឹកអាស៊ីត ខ្ញុំមិនមានអារម្មណ៍ថាក្តៅ ដូចកាន់ទឹកក្តៅឡើយ*» ។ គាត់បាននិយាយបន្ថែមទៀតថា ប្រសិនបើគាត់បានដឹងអំពីផលអន្តរាយនៃអាស៊ីតលើផ្ទៃមុខ និងភ្នែករបស់ជនរងគ្រោះ គាត់នឹងមិនប្រើប្រាស់វាទេ ។

ម្យ៉ាងវិញទៀត ប្រជាជនមួយចំនួនធំបានយល់ដឹងពីមហន្តរាយបង្កដោយទឹកអាស៊ីតទៅលើស្បែក ដូចជា ការរលាក និងការខូចរាងកាយធ្ងន់ធ្ងរ ការឈឺចាប់ខ្លាំង និងការរងទុក្ខវេទនាអស់មួយជីវិត ប៉ុន្តែបានជ្រើសរើសប្រើប្រាស់វាជាអាវុធដើម្បីឲ្យបានផលដូចដែលខ្លួនចង់បាន ។ នៅក្នុងសង្គមដែលវាយតម្លៃមនុស្សដោយផ្អែកលើសំបកក្រៅ និង តម្លៃរបស់មនុស្សដោយផ្អែកទៅលើរូបសម្ផស្ស ការខូចរាងកាយហាក់បីដូចជាការទទួលទោសប្រហារជីវិតអ៊ីចឹងដែរ ។ ដូចដែលបានពិភាក្សាពីខាងដើម ជនរងគ្រោះមួយចំនួនត្រូវបានគេវិនិច្ឆ័យ និង លែងរាប់រកពីគ្រួសារដោយសារតែរបួសដោយទឹកអាស៊ីត ។ នៅក្នុងប្រទេសស្ទើរតែទាំងអស់ ការខូចរូបរាងកាយអាចនាំឲ្យជីវិតក្លាយជាអ្នកដែលសង្គមមិនរាប់រក ។ អ្នកនិពន្ធមួយចំនួន បានចង្អុលបង្ហាញថា អាស៊ីតត្រូវបានជ្រើសរើសយកមកប្រើប្រាស់ ដោយសារតែវាមិនមែនសម្រាប់សម្លាប់មនុស្ស ប៉ុន្តែ សម្រាប់បំផ្លាញរូបរាងកាយ ។[៥៧] មានការយល់ស្របគ្នាថា នៅប្រទេសបង់ក្លាដេស ប៉ាគីស្ថាន និងប្រទេសឥណ្ឌា បុរសនឹងធ្វើការវាយប្រហារដោយទឹកអាស៊ីតទៅលើស្ត្រី ឬក្មេងស្រី ដោយសារតែការបន្ទាបបន្ថោកតម្លៃក្នុងសង្គម ដែលជនរងគ្រោះទាំងនោះនឹងទទួលរងក្រោយពីការវាយប្រហារ ។[៥៨] លោក កូហាន (Cohan) បានធ្វើការប្រៀបធៀបរវាងការវាយប្រហារដោយទឹកអាស៊ីតទៅលើស្ត្រី ទៅនឹងការសម្លាប់ដើម្បីស្តាកិត្តិយស (Honour Killing) ដោយបានពន្យល់ថា ការវាយប្រហារដោយទឹកអាស៊ីត ដូចការសម្លាប់ស្តាកិត្តិយសដែរ គឺជាអំពើគិតទុកជាមុនក្នុងគោលបំណង«បន្ទាបតម្លៃ»ជនរងគ្រោះ ។ គាត់បានអះអាងថា

---

[៥៧] Chatterjee, *មើលកំណត់ចំណាំលេខ ១៩*, ទំព័រ ៧ ។

[៥៨] Kalantry & Kestenbaum, *មើលកំណត់ចំណាំលេខ ៣៧*, ទំព័រ ៣ ។

ការបំផ្លាញទម្រង់រាងកាយរបស់មនុស្សម្នាក់ គឺដើម្បីឲ្យជនរងគ្រោះ និង គ្រួសារទទួលរងនូវភាពអាម៉ាស់ ។[៥៩]

បើទោះបីជា អំពើហិង្សាដោយទឹកអាស៊ីត ជាធម្មតា ជាការវាយប្រហារដោយគិតទុកជាមុន ដែលបានគ្រោងទុក និងអនុវត្តយ៉ាងល្អិតល្អន់ ដោយសារជនល្មើសត្រូវទិញអាស៊ីត និងចូលទៅជិតជនរងគ្រោះដែលជាគោលដៅក៏ដោយ មានករណីខ្លះដែលអាស៊ីតត្រូវបានគេប្រើប្រាស់ដើម្បីនៅពេលផ្ទុះកំហឹង ឬការរំជួលចិត្តខ្លាំង ។ ជាឧទាហរណ៍ ស្ត្រីម្នាក់ ដែលបានជះទឹកអាស៊ីតទៅលើស្វាមីរបស់គាត់ បានប្រាប់បុគ្គលិកផ្នែកច្បាប់របស់អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីតថា “*យើងកំពុងតែឈ្លោះគ្នា ចំពេលដែលខ្ញុំកំពុងតែកាន់ទឹកអាស៊ីតក្នុងដៃដើម្បីបញ្ចូលអាគុយ ខ្ញុំខឹងគាត់ខ្លាំងពេក ក៏ជះទឹកអាស៊ីតដាក់គាត់តែម្តងទៅ ។ តែខ្ញុំមិនមែនជះលើគាត់ដោយសារវាជាទឹកអាស៊ីតនោះទេ ។ ប្រសិនបើខ្ញុំកាន់កាំបិតក្នុងដៃ ខ្ញុំនឹងយកកាំបិតកាប់គាត់មិនខាន*” ។[៦០] ទោះបីករណីនេះ គឺជាករណីមួយដែលមិនសូវធម្មតាក៏ដោយ គេត្រូវតែទទួលស្គាល់អំពីលទ្ធភាពដែលថាទឹកអាស៊ីតមិនត្រូវបានជ្រើសរើសយកមកវាយប្រហារដោយចេតនាទេ ប៉ុន្តែ ត្រូវបានយកមកប្រើដោយសារតែទឹកអាស៊ីតមាននៅជិតដៃស្រាប់ ។

### ៣.៣. និទណ្ឌភាពសម្រាប់ជនល្មើស

ការយល់ដឹងដែលថាជនល្មើសនៃអំពើហិង្សាដោយទឹកអាស៊ីត មិនសូវត្រូវបានចាប់ខ្លួន ឬដាក់ទោស អាចជាមូលហេតុមួយដែលនាំឲ្យមានការរាតត្បាតនៃការវាយប្រហារផងដែរ ។ នេះមិនមែនជាករណីដែលកើតឡើងតែនៅកម្ពុជានោះទេ ។ ប្រទេសដទៃទៀត និងអ្នកនិពន្ធផ្សេងៗ ក៏បានកត់សម្គាល់ថា នៅក្នុងករណីជាច្រើន ជនល្មើសមិនត្រូវបានដាក់ទោសទេ ។[៦១] មូលហេតុសម្រាប់បញ្ហានិទណ្ឌភាពនេះ មានរួមទាំងការខ្វះខាតច្បាប់ដែលផ្តល់លទ្ធភាពសម្រាប់កាត់ទោស និងផ្តន្ទាទោស អំពើពុករលួយ និងកង្វះធនធាន ។ លោក វែលស៍ (Welsh) បានមានប្រសាសន៍ថា និទណ្ឌភាពសម្រាប់ជនល្មើស និងអ្នកអុជអាល អាចបង្រៀនអ្នកផ្សេងទៀតថា ជនរងគ្រោះមួយចំនួនសមនឹងទទួលរងការវាយប្រហារ ដោយទឹកអាស៊ីត និងថា ជនល្មើសមិនត្រូវបានផ្តន្ទាទោសដោយសារតែអំពើដែលពួកគេបាន

---

[៥៩] J. A. Cohan, ដកស្រង់ចេញពីអត្ថបទ *Honour Killings and the Cultural Defense*, ៤០ CAL. W. INT'L L.J. ១៧៧, ១៩៨ (២០១០) ។

[៦០] បទសម្ភាសន៍ជាមួយ អក និង ចច, ជនល្មើសនៃអំពើហិង្សាដោយទឹកអាស៊ីត ។

[៦១] Kalantry & Kestenbaum, *មើលកំណត់ចំណាំលេខ ៣៧*, ទំព័រ៤; Shah, *មើលកំណត់ចំណាំលេខ ៣២*, ទំព័រ ១៧៤ ។

ប្រព្រឹត្តជាអំពើសមស្រប ។[៦២] យោងតាមលោក ហ្គោឡុកលី (Gollogly) អំពើហិង្សាដោយទឹកអាស៊ីត ត្រូវបានគិតថាជាមធ្យោបាយដែលអាចទទួលយកបានសម្រាប់ដោះស្រាយជម្លោះ ដោយសារតែកង្វះនូវផលវិបាកធ្ងន់ធ្ងរប្រឆាំងនឹងអំពើហិង្សាប្រភេទនេះ ។[៦៣] ការយល់ឃើញទាំងអស់នេះ បាននាំឲ្យមានសង្គមទទួលយកអំពើហិង្សាដោយទឹកអាស៊ីត និងបានធ្វើឲ្យមានវប្បធម៌នៃនិទណ្ឌភាពនេះ ។

បើទោះបីជាស្ទើរតែគ្រប់ប្រទេសទាំងអស់ បានចាត់ទុកអំពើហិង្សាដោយទឹកអាស៊ីតជាអំពើហិង្សាយែនឌ័រ[៦៤] ក៏ដោយ ខ្ញុំយល់ថា អំពើហិង្សាដោយទឹកអាស៊ីត នៅកម្ពុជាមិនមែនជាអំពើហិង្សាយែនឌ័រទេ ប៉ុន្តែវាជាអំពើហិង្សា«មួយបែបផ្សេងទៀត» ។ លោក សាមមេន ក៏មានគំនិតដូចគ្នាដែរ ដោយបានលើកឡើងថា «*វាជាអំពើហិង្សាមួយបែបមានទម្រង់ផ្សេង*» ។[៦៥] អំពើហិង្សាដោយទឹកអាស៊ីតនៅកម្ពុជាមិនអាចភ្ជាប់ទៅនឹងអំពើហិង្សាបែបយែនឌ័រទាំងស្រុងនោះទេ ដោយសារតែជនរងគ្រោះមិនមែនសុទ្ធតែជាស្ត្រីទាំងអស់ឡើយ ។ តាមការពិត អ្នករស់រានមានជីវិតពីអំពើហិង្សាដោយទឹកអាស៊ីតជាច្រើនជាបុរស ។ ជនរងគ្រោះជាបុរសមានចំនួនដល់ទៅ៤០ភាគរយ ក្នុងចំណោមជនរងគ្រោះនៃអំពើហិង្សាដោយទឹកអាស៊ីតនៅកម្ពុជាទាំងអស់ ដែលតួលេខនេះបានបង្ហាញពីភាពខុសគ្នារវាងកម្ពុជា និងប្រទេសដទៃទៀត ដែលជនរងគ្រោះស្ទើរតែទាំងអស់សុទ្ធតែជាស្ត្រី ត្រូវទទួលរងការវាយប្រហារ ។[៦៦] ជាងនេះទៅទៀត នៅពេលប្រៀបធៀបជាមួយប្រទេសដទៃ វាមានមូលហេតុជាច្រើននៅពីក្រោយការវាយប្រហារដោយទឹកអាស៊ីតជាជាងអំពើហិង្សាយែនឌ័រ ។ ឧទាហរណ៍ ជម្លោះមុខជំនួញ ជម្លោះកម្មសិទ្ធិ និងបញ្ហាគ្រួសារ ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានយល់ស្របថា កម្ពុជាមានភាពខុសគ្នាពីករណីរបស់ប្រទេសផ្សេងទៀត ដោយសារជនរងគ្រោះមានចំនួនស្ទើរតែស្មើគ្នារវាងជនរងគ្រោះបុរស និងស្ត្រី ។[៦៧]

---

[៦២] Welsh, *មើលកំណត់ចំណាំលេខ៥*, ទំព័រ៥៣ ។

[៦៣] J. Gollogly, S Von Vath & A. Malmberg, ដកស្រង់ចេញពីអត្ថបទ *Acid Attacks in Cambodia: Serious Reminders of Personal Conflicts*, 2:4 ASIAN BIOMEDICINE 329, 333 (សីហា ២០០៨), អាចរកបាននៅគេហទំព័រ http://abm.digitaljournals.org/index.php/abm/article/viewFile/197/116 ។

[៦៤] សូមមើលឧទាហរណ៍ Welsh, *មើលកំណត់ចំណាំលេខ ៥*, ទំព័រ ៥៤; Shah, *មើលកំណត់ចំណាំលេខ ៣២*, ទំព័រ ១១៨២, ១១៩៥; Kalantry & Kestenbaum *មើលកំនត់ចំណាំលេខ៣៧*, ទំព័រ ១-៣, ១៦-១៧ ។

[៦៥] កិច្ចសម្ភាសជាមួយលោក ហ្សៀត សាមមេន (Ziad Samman), ប្រធានគម្រោង CASC ។

[៦៦] មើលទិន្នន័យរបស់ CASC. នៅស្ទើរតែគ្រប់ករណី ស្ត្រីគឺជាជនរងគ្រោះនៃការវាយប្រហារដោយទឹកអាស៊ីត ដែលនាំឲ្យមានការផ្តោតខ្លាំងថាស្ត្រីជសុទ្ធតែជាជនរងគ្រោះ ហើយមិនយកចិត្តទុកដាក់ចំពោះជនរងគ្រោះដែលជាបុរស ។

[៦៧] បទសម្ភាសន៍ជាមួយបុគ្គលិក CCHR តាមរយៈសារអេឡិចត្រូនិច ។

ដើម្បីពន្យល់ខ្លះអំពីបុព្វហេតុនៃអំពើហិង្សាដោយទឹកអាស៊ីតនៅកម្ពុជា ដែលកើតឡើងចំពោះជនរងគ្រោះទាំងបុរសនិងស្ត្រី យើងគួរតែផ្តោតទៅលើប្រវត្តិសាស្ត្រ និង បទដ្ឋានសង្គមនិងវប្បធម៌ខ្មែរ ។ កម្ពុជាជាប្រទេសដែលរងគ្រោះដោយសង្គ្រាមអស់ជាងបីទសវត្សរ៍ ហើយគ្រប់ក្រុមគ្រួសារទាំងអស់សុទ្ធតែត្រូវរងផលប៉ះពាល់ដោយសង្គ្រាម ។ នៅខែមេសា ឆ្នាំ១៩៧៤ បក្សកុម្មុយនីស្តកម្ពុជាហៅកាត់ថា CKP ដែលជាទូទៅត្រូវបានគេស្គាល់ថាជាខ្មែរក្រហម បានចូលកាន់កាប់ប្រទេសកម្ពុជា ប្តូរឈ្មោះប្រទេសនេះទៅជាកម្ពុជាប្រជាធិបតេយ្យ ហើយនៅក្នុងគោលបំណងបង្កើតសង្គមកសិកម្មថ្មីទាំងស្រុងមួយ បានដាក់ចេញគោលនយោបាយដែលបានបណ្តាលឲ្យបាត់បង់ជីវិតប្រជាជនកម្ពុជារាប់លាននាក់ តាមរយៈការសម្លាប់ ឬការបង្ខំឲ្យធ្វើការងារបាក់កម្លាំងដោយមិនមានម្ហូបអាហារគ្រប់គ្រាន់ ។[៦៨] នៅខែមករា ឆ្នាំ១៩៧៩ កងកម្លាំងវៀតណាមបានបណ្តេញខ្មែរក្រហមចេញពីអំណាច ដែលបាននាំទៅដល់រយៈកាលមួយដែលគ្រប់គ្រងដោយវៀតណាម និងភាពប្រទូសរ៉ាយជាបន្ត ជាពិសេសនៅតំបន់តាមព្រំដែនថៃ ។ បន្ទាប់ពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១ អង្គការសហប្រជាជាតិ តាមរយៈបេសកកម្មរបស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ (អ៊ុនតាក់ ឬ UNTAC) បានរៀបចំការបោះឆ្នោតលើកដំបូងក្នុងរយៈពេលរាប់ទសវត្សរ៍ ប៉ុន្តែខ្មែរក្រហមបានបដិសេធទម្លាក់អាវុធដែលបាននាំទៅដល់ភាពតានតឹង និងការវាយប្រហារសាជាថ្មី ។[៦៩] បើទោះបីជាគណបក្សហ៊្វុនស៊ិនប៉ិចរបស់ព្រះអង្គម្ចាស់ រណឫទ្ធិ ឈ្នះការបោះឆ្នោតខែឧសភា ឆ្នាំ១៩៩៣ក៏ដោយ បក្សនេះមិនទទួលបានការគាំទ្រភាគច្រើនដាច់ខាតនៅក្នុង ហើយត្រូវបង្ខំចិត្តបង្កើតសម្ព័ន្ធភាពជាមួយគណបក្សប្រជាជនកម្ពុជា ដែលដឹកនាំដោយលោក ហ៊ុន សែន ។[៧០] រដ្ឋាភិបាលថ្មីនេះមិនបាននាំមកនូវសន្តិភាពជូនកម្ពុជាភ្លាមៗទេ ដោយសមាជិកខ្មែរក្រហមនៅតែបន្តធ្វើការវាយប្រហារ ហើយសូម្បីតែរវាងបក្សកាន់អំណាចទាំងពីរក៏មានការវាយប្រហារគ្នាឯងដែរ ។ ស្ថានការណ៍បែបនេះបាននាំឲ្យមានការធ្វើ«រដ្ឋប្រហារ»ដោយលោក ហ៊ុន សែន នៅខែកក្កដា ឆ្នាំ១៩៩៧ ដែលតាមរយៈនេះ

---

៦៨ S. HEDER, ដកស្រង់ចេញពីសៀវភៅ SEVEN CANDIDATES FOR PROSECUTION: ACCOUNTABILITY FOR THE CRIMES OF THE KHMER ROUGE, ៣ (មជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ ២០០៤) ។

៦៩ J. BRINKLEY, ដកស្រង់ចេញពីសៀវភៅ CAMBODIA'S CURSE, THE MODERN HISTORY 73 (Black Ink, ២០១១) ។

៧០ ដូចខាងលើ, ទំព័រ ៧៩-៨៥ ។

គាត់ដណ្ដើមបានការកាន់កាប់រដ្ឋាភិបាលទាំងស្រុង ។[៧១] ចាប់តាំងពីពេលនោះមក គាត់បានក្លាយជានាយករដ្ឋមន្ត្រីរហូត ។[៧២]

សង្គ្រាម និងជម្លោះជាច្រើនសម័យកាល មិនត្រឹមតែនាំឲ្យបុរសមានចំនួនតិចជាងស្ត្រីតែប៉ុណ្ណោះទេ[៧៣] ហើយវាថែមទាំងនាំឲ្យប្រជាជនខ្មែរជាច្រើននាក់ជួបប្រទះនូវអំពើហិង្សា និងការស្លាប់ទៀតផង ដែលអាចជាហេតុផលចិត្តសាស្ត្រមួយដែលនាំឲ្យសង្គមខ្មែរក្លាយជាសង្គមមួយដែលទទួលស្គាល់ថាអំពើហិង្សាជាអំពើមួយដែលអាចទទួលយកបាន ។[៧៤] របាយការណ៍ស្ដីពីអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាបានកំណត់បទពិសោធន៍អំពើហិង្សាកាលពីកុមារ ថាជាកត្តាហានិភ័យសំខាន់ដែលនាំទៅដល់អំពើហិង្សានៅថ្ងៃអនាគត ។[៧៥] ភស្តុតាងជាបទសម្ភាសន៍បានបង្ហាញថាមានប្រជាជនកម្ពុជាជាច្រើន ដែលកាលពីនៅក្មេង ត្រូវបានបង្រៀនថាអំពើហិង្សាគួរតែត្រូវយកមកដោះស្រាយជម្លោះ និងដែលក្រោយមកមានឥរិយាបថធម្មតាចំពោះការប្រើប្រាស់អំពើហិង្សាសម្រាប់ដោះស្រាយជម្លោះ ។[៧៦] តាមរបាយការណ៍នេះ បុរសចំនួន៣០ភាគរយ និងស្ត្រីចំនួន២៦ភាគរយ បាននិយាយឃើញថា ពេលខ្លះ ការជះទឹកអាស៊ីតអាចជាអំពើដែលអាចទទួលយកបាន ។[៧៧] បទពិសោធន៍ពីកុមារភាពបែបនេះអាចជាផ្នែកមួយនៃមូលហេតុដែលមនុស្ស ជួនកាល ជ្រើសរើសយកទឹកអាស៊ីតមកធ្វើការវាយប្រហារ ជាជាងប្រើប្រាស់មធ្យោបាយដែលមិនសូវកាចសាហាវដូចការប្រើប្រាស់ទឹកអាស៊ីតដើម្បីដោះស្រាយជម្លោះ ។

---

[៧១] ដូចខាងលើ, ទំព័រ ១២២ - ១២៩ ។

[៧២] គណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោតនៅឆ្នាំ ១៩៩៨, ២០០៣, ២០០៨, ហើយឈ្នះដោយចម្រូងចម្រាសនៅឆ្នាំ ២០១៣ ។

[៧៣] D. de Walqu, ដកស្រង់ចេញពីអត្ថបទ *Selective Mortality During the Khmer Rouge Period in Cambodia*, ៣១ POPULATION & DEV. REV. ៣៥១, ៣៥៨ (មិថុនា ២០០៥) ។

[៧៤] Welsh, *មើលកំណត់ចំណាំលេខ ៥*, ទំព័រ ១៣ ។

[៧៥] Partners for Prevention (P4P) (an interagency initiative of UNDP, UNFPA, UN Women and UNV in Asia and the Pacific), ដកស្រង់ចេញពីអត្ថបទ *ដើម្បូងប្រាំហត្ថនៅកម្ពុជាសម័យថ្មី: A Qualitative Exploration of Gender Norms, Masculinity and Domestic Violence*, ទំព័រ១១, ៣០ - ៣១ (ភ្នំពេញ, ២០១០) ។

[៧៦] ដូចខាងលើ, មើលទំព័រ ៣៩ ។

[៧៧] ដូចខាងលើ, មើលទំព័រ ៧៨ ។

ការយល់ឃើញជាទូទៅនៅកម្ពុជា ហាក់បីដូចជាថា ប្រសិនបើមាននរណាម្នាក់ប្រព្រឹត្តខុសមកលើខ្លួន គេអាចសងសឹកជននោះវិញតាមវិធីណាមួយ ។[៧៨] នៅពេលគួបផ្សំជាមួយការយល់ឃើញស្រាលៗក្នុងការទទួលយកអំពើហិង្សាដើម្បីដោះស្រាយជម្លោះ ទឹកអាស៊ីតបានក្លាយជាអាវុធងាយស្រួលរក មិនថ្លៃ យ៉ាងមានប្រសិទ្ធិភាព ប្រសិនបើគោលបំណងគឺដើម្បី "យកឈ្នះ" លើជម្លោះ ឬ បំផ្លាញជីវិតមនុស្សម្នាក់ ។[៧៩]

សរុបមក តាមគំនិតខ្ញុំ ការវាយប្រហារដោយទឹកអាស៊ីតនៅកម្ពុជាមិនមែនប្រព្រឹត្តជាទូទៅក្នុងទម្រង់ជាអំពើហិង្សាបែបយែនឌ័រនោះទេ ។ ប៉ុន្តែដោយសារតែមូលហេតុរួមផ្សំមួយចំនួន ទើបនាំឲ្យទាំងបុរស និងស្ត្រីសុទ្ធតែក្លាយជាជនរងគ្រោះដូចគ្នា ។ មូលហេតុទាំងនេះរួមមានភាពងាយស្រួលរកទឹកអាស៊ីត (កង្វះ) ការយល់ដឹងពីគ្រោះថ្នាក់ដោយទឹកអាស៊ីត និងបញ្ហាសង្គម និងបញ្ហាចិត្តសាស្ត្រ ។

## ៣.៤. ការយល់ឃើញជាសាធារណៈ

ដូចដែលបានពិភាក្សាពីខាងលើ ៦៣ភាគរយនៃខប្បត្តិហេតុដែលបានចុះក្នុងបញ្ជីទាំងអស់ គឺជាការវាយប្រហារដែលត្រូវបានផ្ទៀងផ្ទាត់ ។ ចំណែកគ្រោះថ្នាក់ផ្សេងទៀត បានកើតឡើងក្នុងទម្រង់ជាខបទ្ទវហេតុ ការធ្វើអត្តឃាត ឬជាករណីដែលមិនដឹងប្រភពច្បាស់ថាតើជាការវាយប្រហារដោយចេតនា ឬជាខបទ្ទវហេតុ ។ ការវាយប្រហារដែលត្រូវបានផ្ទៀងផ្ទាត់មានន័យថា អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីតកម្ពុជា អាចបញ្ជាក់ថា (តាមរយៈចម្លើយរបស់អ្នករស់រានមានជីវិត និងសាក្សីភ័ស្តុតាង និងឯកសារផ្សេងទៀត) ថា ជនរងគ្រោះត្រូវបានទទួលរងការវាយប្រហារដោយចេតនាដោយទឹកអាស៊ីត ទោះបីដោយជនដៃដល់ផ្ទាល់ ឬដោយការបញ្ជាឲ្យអ្នកដទៃធ្វើការវាយប្រហារជំនួស ។

ជាទូទៅ នៅពេលដែលមានការវាយប្រហារដោយទឹកអាស៊ីត មនុស្សទូទៅតែងយល់ឃើញថាការវាយប្រហារប្រាកដជាកើតឡើងដោយសារភាពមិនស្មោះត្រង់ ឬការប្រច័ណ្ឌ ដូចជាអំពើផិតក្បត់ជម្លោះស្នេហ៍ ឬការបដិសេធស្នេហា ។ ការយល់ឃើញមួយទៀតនោះគឺថា នៅពេលដែលស្ត្រីម្នាក់ទទួលរងការវាយប្រហារ ស្ត្រីរងគ្រោះនោះប្រាកដជាប្រពន្ធចុង ឬស្រីស្នេហ៍របស់នរណាម្នាក់ ។[៨០] បើទោះ

[៧៨] Welsh, *មើលកំណត់ចំណាំលេខ ៥*, ទំព័រ ៦០ ។

[៧៩] *Breaking the Silence*, *មើលកំណត់ចំណាំលេខ៦*, ទំព័រ ១ ។

[៨០] *ដូចខាងលើ.*, មើលកំណត់ចំណាំលេខ ៤ ។

បីដា វាគឺជាការពិតដែលថា បញ្ហាទាំងនេះផ្នែកមួយនៃការវាយប្រហារក៏ដោយ អង្គការជួយជនរងគ្រោះកម្ពុជាដោយទឹកអាស៊ីត បានបែងចែកមូលហេតុនៃការវាយប្រហារជា៧ប្រភេទ ដែលបានបញ្ជាក់ថា អំពើផិតក្បត់ និងការប្រចណ្ឌ មិនមែនជាហេតុផលតែមួយគត់ដែលនាំឲ្យមានការឲ្យមានអំពើហិង្សាដោយទឹកអាស៊ីតនោះទេ ។ ជាក់ស្ដែង ជនរងគ្រោះរស់រានជីវិតយ៉ាងហោចណាស់២៦ភាគរយ ទិន្នន័យរបស់ អង្គការជួយជនរងគ្រោះកម្ពុជាដោយទឹកអាស៊ីត មិនមែនទទួលរងការវាយប្រហារដោយអំពើប្រចណ្ឌ ឬអំពើផិតក្បត់ទេ ។ ទិន្នន័យនេះអាចបញ្ជាក់ប្រាប់ថាការវាយប្រហារទាំងអស់មិនមែនសុទ្ធតែកើតឡើងដោយការប្រចណ្ឌ និងអំពើផិតក្បត់ឡើយ ។ មូលហេតុផ្សេងទៀតនៃការវាយប្រហារនោះរួមមាន ជម្លោះកម្មសិទ្ធិ ឬព្រំដី ជម្លោះគ្រួសារ ការប្រកួតប្រជែងមុខជំនួញ និងអំពើលួចគាស់ផ្ទះ ។ នៅក្នុងករណីមួយដែលត្រូវបានរាយការណ៍ បុរសម្នាក់បានធ្វើការវាយប្រហារលើបងស្រីថ្លៃដោយសារតែបងថ្លៃចោទថាបុរសនោះលក់កូនស្រីខ្លួនឯង ។ បើទោះបីជាអំពើហិង្សាភាគច្រើនត្រូវបានប្រព្រឹត្តឡើងដោយការប្រចណ្ឌ និងពាក់ព័ន្ធនឹងអំពើផិតក្បត់ក៏ដោយ ក៏កត្តាទាំងពីរនេះមិនមែនជាមូលហេតុតែមួយគត់ចំពោះបទល្មើសនេះ ។

ជាទូទៅ នៅស្ទើរតែគ្រប់ប្រទេសទាំងអស់ គេតែងតែគិតថាជនរងគ្រោះដោយការវាយប្រហារដោយទឹកអាស៊ីត ទទួលរងនូវការវាយប្រហារដោយសារតែពួកគាត់បានប្រព្រឹត្តអ្វីមួយខុស ឧទាហរណ៍ ជនរងគ្រោះទទួលរងការវាយប្រហារ ដោយសារតែកម្មពៀររបស់ពួកគាត់ដែលបន្សល់ពីជាតិមុន ។[៨១] ជាទូទៅ ជនរងគ្រោះតែងត្រូវទទួលរងការបន្ទោសចំពោះអ្វីដែលបានកើតឡើងចំពោះពួកគាត់ ។ ដូចជាក្នុងករណីរបស់បុរសវ័យ៤២ឆ្នាំម្នាក់ និងមិត្តស្រីវ័យ១៩ឆ្នាំរបស់គាត់ ដែលបានទទួលរងការវាយប្រហារដោយទឹកអាស៊ីតនៅពេលដែលពួកគេទាំងពីរកំពុងគេងលក់ ។ បុរសវ័យ៤២ឆ្នាំរូបនោះបានទទួលរងរបួសយ៉ាងធ្ងន់ធ្ងររហូតដល់ស្លាប់ដោយសាររបួសទាំងនោះ ។ របាយការណ៍មួយដែលចេញដោយមេភូមិបានបញ្ជាក់ថា ការវាយប្រហារនោះគឺជាអំពើសមរម្យ ដែលឆ្លើយតបទៅនឹងការរំលោភបំពានរបស់បុរសដែលជាជនរងគ្រោះធ្លាប់បានធ្វើមកលើជនល្មើស ។[៨២]

ចំណុចខុសគ្នាគួរឲ្យចាប់អារម្មណ៍មួយទៀតរវាងប្រទេសកម្ពុជានិងប្រទេសផ្សេងទៀត ដែលមានការវាយប្រហារដោយទឹកអាស៊ីតកើតឡើង ភាគច្រើននៃករណីវាយប្រហារដែលបានចុះបញ្ជីនៅកម្ពុជា

---

៨១ Welsh, *មើលកំណត់ចំណាំលេខ ៥*, ទំព័រ ៦០, CASC *មើលកំណត់ចំណាំលេខ ៦*, ទំព័រ ៤ ។

៨២ CCHR, ដកស្រង់ចេញពីអត្ថបទ *Ending the Cycle of Impunity for Acid Crimes in Cambodia,* ទំព័រ ១៣ (ឧសភា ២០១២) ។

ឧក្រិដ្ឋជនសុទ្ធតែជាស្ត្រី ។ ស្ថិតិបានបង្ហាញថា អ្នករស់រានមានជីវិតយ៉ាងតិច១៤១នាក់ (រួមទាំងការវាយប្រហារដោយចេតនា និង ការវាយប្រហារខុសគោលដៅ) ត្រូវបានវាយប្រហារដោយស្ត្រី ឬស្ត្រីជាអ្នកបញ្ជាការវាយប្រហារដោយផ្ទាល់ ។[៨៣] បើធ្វើការប្រៀបធៀប អ្នករស់រានមានជីវិតយ៉ាងហោចណាស់ចំនួន៦៧នាក់ ត្រូវបានវាយប្រហារដោយបុរស ឬបុរសជាអ្នកបញ្ជាពីក្រោយការវាយប្រហារផ្ទាល់ ។ ដោយមិនរាប់អំពីករណីមិនដឹង នេះមានន័យថា នៅក្នុង៦៧,៨ភាគរយ ជនដៃដល់ ឬអ្នកបញ្ជាពីក្រោយ ជាបុរស ។[៨៤] វាជាការលំបាកមួយក្នុងការនិយាយឲ្យរឹងមាំមួយណាមួយអំពីភាពខុសគ្នានេះ ដោយសារតែពុំទាន់មានការសិក្សាជាផ្លូវការស្តីពីជនល្មើសជាស្ត្រីនៅឡើយ ។ ហេតុដូច្នេះសេចក្តីពន្យល់នេះគ្រាន់តែជាការយល់ឃើញប៉ុណ្ណោះ ។ លោក សាមមេន បានអះអាងលើករណីនេះ ប៉ុន្តែលោកក៏បានយល់ឃើញដែរថា នៅក្នុងករណីអំពើផិតក្បត់ កត្តាមួយក្នុងចំណោមកត្តាជំរុញដទៃទៀតដែលនាំឲ្យស្ត្រីធ្វើវាយប្រហារលើដៃគូរបស់ខ្លួន ប្រហែលជាក្នុងគោលបំណងចង់ឲ្យដៃគូត្រូវរំពឹងលើខ្លួនក្នុងន័យធ្វើឲ្យស្ត្រីទាំងនោះមានអំណាចទៅលើដៃគូ និងឲ្យបុរសជាដៃគូបន្តចិត្តរស់នៅជាមួយខ្លួន ។[៨៥]

ជាទូទៅ ពាក់ព័ន្ធនឹងករណីវាយប្រហារដោយទឹកអាស៊ីតនេះ អំពើផិតក្បត់ និងការប្រចណ្ឌមិនមែនជាកត្តាតែមួយគត់ដែលនាំឲ្យស្ត្រីក្លាយជាអ្នកវាយប្រហារផ្ទាល់ ឬអ្នកផ្តើមគំនិតក្នុងការវាយប្រហារនោះទេ ។ បើទោះបីជាករណីទាំងពីរនេះអាចជាបញ្ហាបង្កឲ្យមានការវាយប្រហារ ក៏នៅមានមូលហេតុដើមចមដទៃទៀតដែលនាំឲ្យមានការវាយប្រហារដែរ ។ បញ្ហាដែលសំខាន់នោះគឺ នៅក្នុងសង្គមខ្មែរ ស្ត្រីភាគច្រើនត្រូវពឹងផ្អែកលើស្វាមីទាំងស្រុង ទាំងផ្នែកហិរញ្ញវត្ថុ និងសង្គម ។[៨៦] ការមិនមានគូគ្រង

---

[៨៣] ដោយសាររបៀបនៃការរៀបចំស្ថិតិតែស្ថិតិ ចំនួននៃការវាយប្រហារទាំងនេះបានបូករួមទាំងការវាយប្រហារខុសគោលដៅ ។

[៨៤] Chatterjee, *មើលកំណត់ចំណាំលេខ ១៩*, ទំព័រ ៧ ។

[៨៥] កិច្ចសម្ភាសជាមួយលោក ហ្សៀត សាមមេន (Ziad Samman), ប្រធានគម្រោង CASC ។

[៨៦] នេះដោយសារតែអាកប្បកិរិយា ព្រមទាំងរចនាសម្ព័ន្ធ សង្គម និងយែនឌ័រ ។ នៅក្នុងសង្គមខ្មែរ បុរសមានឋានៈសង្គមខ្ពស់ជាងស្ត្រី ។ ករណីនេះបានជះឥទ្ធិពលដល់ទំនាក់ទំនងយែនឌ័រ និងរចនាសម្ព័ន្ធផ្សេងៗ ។ បុរសត្រូវបានគេចាត់ទុកជាអ្នករ៉ាប់រងសេដ្ឋកិច្ចគ្រួសារដ៏ចម្បង និងជាអ្នកជ្រោមជ្រែងគ្រួសារក្នុងខណៈពេលដែលស្ត្រី និងកុមារីត្រូវបាន បង្រៀនឲ្យគោរពគ្រួសារ និងប្តី ។ ហើយកិច្ចការសំខាន់ នៅក្នុងជីវិតរបស់ស្ត្រីគឺ បំពេញកាតព្វកិច្ចជាប្រពន្ធ និងមាតាដ៏ល្អ ។ ជាពិសេស ករណីនេះកើតឡើងនៅជនបទ និងខេត្តដាច់ស្រយាល ។ ផ្នត់គំនិតពាក់ព័ន្ធនឹងតួនាទីរបស់ស្ត្រី តែងតែជាមូលហេតុដែលនាំឲ្យកុមារីមិនបានទទួលការអប់រំ ដែលធ្វើឲ្យពួកគេទទួលបានឱកាសតិចតួច ។ ហេតុផលទាំងអស់នេះ ហើយដែលនាំឲ្យស្ត្រីត្រូវពឹងផ្អែកលើស្វាមី ដើម្បីជួយជ្រោមជ្រែងខ្លួននិងកូន ។

ហាក់បីដូចជាទទួលរងនូវអស្ថិរភាពហិរញ្ញវត្ថុ ។ ប្រសិនបើស្ត្រីជាភរិយាដឹងថាប្តីខ្លួនលួចមានស្រីស្នេហ៍ខាងក្រៅ ព្រមទាំងប្រហែលជាជ្រោមជ្រែងស្ត្រីនោះខាងផ្នែកហិរញ្ញវត្ថុទៀតនោះ ស្ត្រីជាប្រពន្ធនឹងធ្វើការវាយប្រហារលើស្ត្រីដែលជាកំណាន់ចិត្តរបស់ប្តីខ្លួន ដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ និងឋានៈក្នុងសង្គមរបស់ខ្លួននិងកូន ។ តាមរបៀបនេះ អសមភាពយេនឌ័របានក្លាយជាកត្តានាំឲ្យមានការវាយប្រហារដោយទឹកអាស៊ីត ។ ឧទាហរណ៍មួយកើតឡើងនៅខែឧសភា ឆ្នាំ២០០៥ បានបង្ហាញអំពីករណីនេះ ។ ស្ត្រីជាប្រពន្ធបានរកឃើញថា បុរសជាប្តីលួចមានស្រីកំណាន់ចិត្តអស់រយៈពេល៨ឆ្នាំរួចមកហើយ និងបន្ទាប់ពីបានព្រមានឲ្យផ្តាច់ទំនាក់ទំនងនេះម្តងហើយម្តងទៀត បានសម្រេចចិត្តទិញទឹកអាស៊ីត ។ នៅយប់មួយ បន្ទាប់ពីត្រឡប់ពីជួបស្រីកំណាន់ចិត្តវិញ ប្តីប្រពន្ធទាំងពីរនាក់ ក៏បានឈ្លោះប្រកែកគ្នា ហើយប្រពន្ធក៏ជះទឹកអាស៊ីតទៅលើបុរសជាប្តី ។ ការពន្យល់របស់ស្ត្រីជាប្រពន្ធនៅពេលធ្វើបទសម្ភាសន៍គួរឲ្យចាប់អារម្មណ៍ ដោយបានប្រាប់ថា «*ការមានស្រីកំណាន់ខាងក្រៅមិនមែនជាអំពើត្រឹមត្រូវនោះទេ ។ ខ្ញុំមិនប្រកាន់ទេ ប្រសិនបើគាត់ទៅរកស្រីខូច ប៉ុន្តែខ្ញុំមិនអាច ទទួលបានទេប្រសិនបើគាត់មានស្រីកំណាន់*» ។[៨៧]

បើប្រៀបធៀបទៅនឹងប្រទេសដទៃទៀត ដែលមានការវាយប្រហារដោយទឹកអាស៊ីតកើតឡើង យើងអាចមើលឃើញថា វាមានលក្ខណៈខុសគ្នាទាំងយេនឌ័ររបស់ជនរងគ្រោះ និងយេនឌ័ររបស់ជនដៃដល់នៅកម្ពុជា ។ បើសិនជាប្រៀបធៀបទៅនឹងប្រទេសដទៃ នៅកម្ពុជា មិនត្រឹមតែមានជនរងគ្រោះជាបុរសច្រើនជាងទេ ចំនួនជនដៃដល់ជាស្ត្រីក៏ច្រើនជាងដែរ ។

## ៤. ប្រព័ន្ធច្បាប់កម្ពុជា: ក្តីសង្ឃឹមក្នុងការទទួលបានយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតពីអំពើហិង្សាដោយទឹកអាស៊ីត

ផ្នែកខាងក្រោមនេះ នឹងពិនិត្យមើលលើប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន ច្បាប់ជាក់លាក់ និងបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងអំពើហិង្សាដោយទឹកអាស៊ីត និងបញ្ហាជាក់លាក់ដែលជនរងគ្រោះដោយទឹកអាស៊ីតជួបប្រទះក្នុងដំណើរស្វែងរកដំណោះស្រាយផ្លូវច្បាប់ ។

អ្នករស់រានមានជីវិតពីការវាយប្រហារដោយទឹកអាស៊ីតជាច្រើននាក់ បានរង់ចាំអស់រយៈពេលរាប់ឆ្នាំរហូតទម្រាំតែរឿងក្តី របស់ខ្លួនអាចឈានដល់ដំណាក់កាលវិនិច្ឆ័យ ឬក៏នៅតែរង់ចាំការជំនុំជម្រះសំណុំរឿងរបស់ខ្លួន ។ នៅពេលដែលនាង ក.ស បានដឹងថាបងថ្លៃនាងបានយកក្មួយស្រីអាយុ១៣ឆ្នាំទៅលក់ នាងក៏បានប្រឈមមុខ និងទាមទារឲ្យបងថ្លៃរបស់ខ្លួនប្រគល់ក្មួយស្រីទៅម្តាយដែលជាងបងស្រី

---

[៨៧] បទសម្ភាសន៍ជាមួយឧក្រិដ្ឋជននៃអំពើហិង្សាដោយទឹកអាស៊ីត នៅខែវិច្ឆិកា ឆ្នាំ២០១២ ។

របស់ខ្លួនវិញ ។ បងថ្លៃនោះ ក៏បានតបតវិញដោយជះទឹកអាស៊ីតទៅលើមុខនាង ក.ស ដែលនាំឲ្យមុខមាត់នាងខូចខាតជាទម្ងន់ ដែលបានធ្វើឲ្យខូចរូបរាងកាយធ្ងន់ធ្ងរជានិច្ច ។ នាង ក.ស បានទទួលរងការវាយប្រហារនៅដើមឆ្នាំ២០០៩ ប៉ុន្តែការជំនុំជម្រះក្តីនៅពុំទាន់ចាប់ផ្តើមធ្វើឡើងនៅឡើយ ។ ជាក់ស្តែងនោះគឺក្រោយពេលដែលនាង ក.ស បានដាក់ពាក្យបណ្តឹងនៅខែវិច្ឆិកា ឆ្នាំ២០០៩ ពាក្យបណ្តឹងទើបតែបានបញ្ជូនទៅតុលាការមានសមត្ថកិច្ចនៅខេត្តសៀមរាប ក្នុងខែសីហា ឆ្នាំ២០១០ ។[៨៨] ដោយមានការជួយជ្រោមជ្រែងពីអង្គការជួយជនរងគ្រោះកម្ពុជាដោយទឹកអាស៊ីត នាង ក.ស អាចជួបជាមួយប្រធានតុលាការ នៅខែកញ្ញា ឆ្នាំ២០១២ ហើយនៅខែវិច្ឆិកា ឆ្នាំ២០១២ ទើបអង្គភាពច្បាប់របស់អង្គការជួយជនរងគ្រោះកម្ពុជាដោយទឹកអាស៊ីត បានទទួលដំណឹងថា រឿងក្តីរបស់នាង ក.ស នឹងចាប់ផ្តើមក្នុងពេលឆាប់ៗ ។ នេះគឺជាការទទួលដំណឹងលើកចុងក្រោយពីតុលាការ ទាក់ទងនឹងរឿងក្តីរបស់នាង ក.ស ហើយក៏ពុំបានដឹងច្បាស់ថាតើតុលាការចាត់វិធានការអ្វីខ្លះទៀតលើរឿងក្តីនេះដែរ ។

គួរឲ្យសោកស្តាយ រឿងក្តីនេះមិនមែនជាករណីលើកលែងនោះទេ ។ ទិន្នន័យរបស់អង្គការជួយជនរងគ្រោះកម្ពុជាដោយទឹកអាស៊ីត បានបង្ហាញថា ក្នុងរឿងក្តីសរុបចំនួន៤១ករណី ដែលមូលនិធិជនរងគ្រោះដោយទឹកអាស៊ីតកម្ពុជា បានដោះស្រាយក្នុងរយៈពេល៣ឆ្នាំចុងក្រោយ មានរឿងក្តីតែ១១ករណីប៉ុណ្ណោះដែលបានឈានទៅដល់ការចេញសេចក្តីសម្រេចចុងក្រោយ ។

ហេតុអ្វីបានជាតុលាការចំណាយពេលដ៏យូរសម្រាប់កាត់ក្តីសម្រេច និងជម្រះក្តីរបស់ជនរងគ្រោះនៃអំពើហិង្សាដោយទឹកអាស៊ីត? តើច្បាប់ស្តីពីអាស៊ីតដែលទើបតែបង្កើតថ្មី អាចធ្វើឲ្យមានការផ្លាស់ប្តូរថ្មីលើករណីនេះដែរឬទេ? ផ្នែកបន្ទាប់នឹងឆ្លើយតបនឹងសំណួរទាំងនេះ ។

### ៤.១. ដំណើរការច្បាប់កម្ពុជា

អង្គការសិទ្ធិមនុស្ស អ្នកជំនាញការច្បាប់ និងអង្គការអន្តរជាតិជាច្រើន បានផ្តល់មតិយោបល់លើលក្ខណៈនៃប្រព័ន្ធច្បាប់នៅកម្ពុជា ។[៨៩] ឧទាហរណ៍ អង្គការឃ្លាំមើលសិទ្ធិមនុស្សដែលហៅកាត់ថា (HRW) បានធ្វើការត្រួតពិនិត្យយ៉ាងជិតដល់លើប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ព្រមទាំងហៅប្រព័ន្ធនេះជា

---

[៨៨] ជនរងគ្រោះនៃឧក្រិដ្ឋកម្ម អាចដាក់ពាក្យបណ្តឹងដោយយោងតាមមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែការដាក់ពាក្យបណ្តឹងមិនសុទ្ធតែមានន័យថាការជំនុំជម្រះក្តីព្រហ្មទណ្ឌនឹងត្រូវបានចាប់ផ្តើមនោះទេ រឿងនេះគឺពឹងផ្អែកទៅលើព្រះរាជអាជ្ញាជាអ្នកសម្រេចចិត្ត ។

[៨៩] មើលឧទាហរណ៍: The CCHR, ‘*Briefing Note: Judicial Reform*’, ខែកុម្ភៈ ឆ្នាំ២០១៣; Bridget Di Certo, *Justice in the Dock*, ដកស្រង់ចេញពីទស្សនាវដ្តី SOUTHEAST ASIA GLOBE, ចុះផ្សាយនៅខែកុម្ភៈ ឆ្នាំ២០១៣, ទំព័រ ២៥ ។

ប្រព័ន្ធ "បក្សពួកនិយម" និងជាប្រព័ន្ធដែលមាន "ចៅក្រមឋិតនៅក្រោមឥទ្ធិពលនយោបាយ" ។[៩០] អង្គការនេះក៏បានបញ្ជាក់ទៀតថានយោបាយ និងរាជរដ្ឋាភិបាលកម្ពុជា "ត្រូវបានញាំញីដោយអំពើពុករលួយ និងការអនុវត្តច្បាប់ដែលទទួលឥទ្ធិពលពីនយោបាយ" និង "អវត្តមាននូវប្រព័ន្ធតុលាការឯករាជ្យ" ។[៩១]

នៅឆ្នាំ១៩៩២ អង្គការសហប្រជាជាតិ បានបង្កើតបេសកកម្មអ៊ុនតាក់ជាអាជ្ញាធរអន្តរកាលនៅកម្ពុជាដើម្បីធ្វើការត្រួតពិនិត្យ និង រៀបចំការបោះឆ្នោតជាលក្ខណៈប្រជាធិបតេយ្យលើកដំបូងក្នុងរយៈពេលជាច្រើនទសវត្សរ៍ ។ អ៊ុនតាក់បានអនុម័តច្បាប់មួយចំនួនដើម្បីបង្កើតក្របខណ្ឌសម្រាប់ប្រព័ន្ធ តុលាការកម្ពុជាឲ្យស្របតាមបទដ្ឋានអន្តរជាតិ ។[៩២] ក្តីសង្ឃឹមនោះគឺថា ការនេះនឹងជំរុញឲ្យមានការផ្លាស់ប្តូរក្នុងស្ថាប័នកម្ពុជា ជាពិសេស ស្ថាប័នដែលទទួលបន្ទុកផ្នែករដ្ឋបាលយុត្តិធម៌ ។ ប៉ុន្តែ កំណែទម្រង់ប្រព័ន្ធតុលាការនៅកម្ពុជា គឺមានភាពយឺតយ៉ាវនៅឡើយ ។ អស់រយៈពេលជាច្រើនឆ្នាំ អង្គការក្រៅរដ្ឋាភិបាលប្រទេសម្ចាស់ជំនួយ និងអង្គការអន្តរជាតិ បានស្នើសុំឲ្យរាជ្យរដ្ឋាភិបាល កម្ពុជាខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងរឿងនេះ ។ រាជរដ្ឋាភិបាលកម្ពុជាបានយល់ព្រមនឹងការស្នើសុំខាងលើ ប៉ុន្តែ យើងនៅមិនទាន់ឃើញមានការផ្លាស់ប្តូរអ្វីជាដុំកំភួននៅឡើយខាងផ្នែកវប្បធម៌អនុវត្តកន្លងមក ។ ផ្នែកសំខាន់ក្នុងការស្នើសុំនោះរួមមាន កងកម្លាំងនគរបាលមានវិជ្ជាជីវៈ ឯករាជភាពរបស់ព្រះរាជអាជ្ញានិងចៅក្រម ព្រមទាំងដោះស្រាយលើបញ្ហាអំពើពុករលួយ និងបញ្ចប់វប្បធម៌និទណ្ឌភាព ។[៩៣]

### ៤.២. ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីតខ្លាំង (២០១២)

តាមទ្រឹស្តី ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជាត្រូវបំពេញការងារដូចខាងក្រោម ។ ឧក្រិដ្ឋកម្មត្រូវរាយការណ៍ជូននគរបាល ។ ក្រោយពីបានទទួលពាក្យបណ្តឹង នគរបាលត្រូវធ្វើការស៊ើបអង្កេត

---

[៩០] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ដកស្រង់ចេញពីអត្ថបទ *Statement to the UN Human Rights Council on Cambodia* , (១៨ វិច្ឆិកា ឆ្នាំ២០១២), អាចរកបាននៅគេហទំព័រ: http://www.hrw.org/news/2012/11/18/cambodia-obama-should-publicly-denounce-rights-abuses

[៩១] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ដកស្រង់ចេញពីអត្ថបទ *Statement to the UN Human Rights Council on Cambodia*, (២៨ កញ្ញា ឆ្នាំ ២០១១), អាចរកបាននៅគេហទំព័រ: http://www.hrw.org/news/2011/09/28/statement-un-human-rights-council-cambodia

[៩២] Di Certo, មើលកំណត់ចំណាំលេខ ៩៥ខាងលើ, ទំព័រ ២៥ ។

[៩៣] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ដកស្រង់ចេញពីអត្ថបទ *Tell Them That I Want To Kill Them* (ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១២), អាចរកបាននៅគេហទំព័រ: http://www.hrw.org/node/111246/section/5

ហ្មត់ចត់មួយ ។ បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត នគរបាលនឹងផ្តល់ដំណឹងជូនព្រះរាជអាជ្ញានៃតុលាការមានសមត្ថកិច្ច ។[៩៤] បន្ទាប់មក ព្រះរាជអាជ្ញានឹងចាប់ផ្តើមធ្វើការស៊ើបអង្កេត រួចធ្វើបទបង្ហាញស្តីពីការស៊ើបអង្កេតទៅចៅក្រមជំនុំជម្រះ ។[៩៥] ប្រធានចៅក្រម នឹងចាត់តាំងចៅក្រមស៊ើបអង្កេត និងចៅក្រមជំនុំជម្រះ ។[៩៦] បន្ទាប់មកទៀត ចៅក្រមស៊ើបអង្កេតនឹងចាប់ផ្តើមបើកការស៊ើបអង្កេត ។ ដំណាក់កាលស៊ើបអង្កេតនេះរួមមាន ការសាកសួរជនរងគ្រោះ ការសាកសួរសាក្សី និងសួរចម្លើយជនដៃដល់ (បើសិនជាអាចធ្វើទៅបាន) និងការប្រមូលភស្តុតាង ។ ក្រោយពីបិទការស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតនឹងចេញរបាយការណ៍ភ្ជាប់ជាមួយនឹងអនុសាសន៍ថាតើរឿងក្តីនេះគួរតែត្រូវបន្តវិនិច្ឆ័យ ឬត្រូវច្រានចោលការចោទប្រកាន់ ។ របាយការណ៍ចេញដោយចៅក្រមស៊ើបនេះ នឹងត្រូវបញ្ជូនទៅព្រះរាជអាជ្ញា និងចៅក្រមជំនុំជម្រះ ។ រឿងក្តីអាចនឹងត្រូវបិទ ឬអាចនឹងចាប់ផ្តើមជម្រះ នៅពេលវេលាណាមួយដែលចាត់ដោយចៅក្រម ។[៩៧] គួរឲ្យកត់សម្គាល់ នៅក្នុងនីតិវិធីព្រហ្មទណ្ឌ មានតែព្រះរាជអាជ្ញា និងទណ្ឌិតប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យប្តឹងសារទុក្ខបាន ។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី (ជនរងគ្រោះ) គ្រាន់តែអាចប្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងបញ្ហារដ្ឋប្បវេណីនៃរឿងក្តីប៉ុណ្ណោះ (ដូចជា សំណង) ។[៩៨] ក្រោយមកបណ្តឹងឧទ្ធរណ៍ត្រូវតែធ្វើឡើងក្នុងអំឡុងពេលមួយខែក្រោយពីតុលាការបានចេញសាលក្រម ។[៩៩] ក្រោយបណ្តឹងឧទ្ធរណ៍ ភាគីអាចស្នើសុំមោឃភាពពីតុលាការកំពូល ។[១០០]

ច្បាប់ស្តីពីអាស៊ីត ត្រូវបានចូលជាធរមាននៅខែមករា ឆ្នាំ២០១២ ។ ច្បាប់នេះ ជាច្បាប់ដែលដាក់ទណ្ឌកម្មលើអំពើហិង្សាដោយទឹកអាស៊ីត និងចែងពីបទបញ្ញត្តិស្តីពីទំនួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល និងនីតិបុគ្គល ។ នៅខែមករា ឆ្នាំ២០១៣ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចេញ

---

[៩៤] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, *កំណត់ចំណាំលេខ៨៨*, មាត្រា ៤៣-៤៤ ។

[៩៥] ដូចខាងលើ, មាត្រា ៥១ ។

[៩៦] ដូចខាងលើ មាត្រា ២៤៦-២៤៧; Asia Regional Cooperation to Prevent People Trafficking, *Gender, Human Trafficking and the Criminal Justice System in Cambodia*, ទំព័រ ៤៧-៤៨ (ខែធ្នូ ឆ្នាំ២០០៣) ។

[៩៧] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, *កំណត់ចំណាំលេខ ៨៨*, មាត្រា ២៥០ ។

[៩៨] ដូចខាងលើ, មាត្រា៣៧៥ ។

[៩៩] ដូចខាងលើ, មាត្រា ៣៨១-៣៨២ ។

[១០០] ដូចខាងលើ, មាត្រា ៤១៧-៤២០ ។

អនុក្រឹត្យស្តីពីទម្រង់ និងលក្ខខណ្ឌសម្រាប់ត្រួតពិនិត្យលើអាស៊ីតខ្លាំង (អនុក្រឹត្យស្តីពីអាស៊ីត) ដែលបានបញ្ជាក់បន្ថែមពីបទបញ្ញានៃការដឹកជញ្ជូន ការទិញដូរ និងដាក់ទុកដាក់អាស៊ីតខ្លាំង ។

រហូតដល់ពេលដែលច្បាប់ស្តីពីអាស៊ីតចូលជាធរមាន នីតិកម្មព្រហ្មទណ្ឌនៅកម្ពុជាខកខានពុំបានដាក់បញ្ចូលការដាក់ទោសលើហេតុការណ៍ដែលទឹកអាស៊ីតត្រូវយមកប្រើជាអាវុធដោយចេតនា ។ មុនពេលអនុម័តច្បាប់ស្តីពីអាស៊ីត បទល្មើសពាក់ព័ន្ធនឹងអាស៊ីតត្រូវជម្រះក្រោមបទបញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ លើសពីនេះទៅទៀត បទបញ្ញាពាក់ព័ន្ធនឹងការទិញ លក់ ទុកដាក់ និងដឹកជញ្ជូនអាស៊ីត ពុំទាន់ត្រូវបានរៀបចំឲ្យបានត្រឹមត្រូវនៅឡើយ ។ ច្បាប់ដែលមានពីមុន ពុំបានទទួលស្គាល់ពីតម្រូវការជាពិសេសរបស់អ្នករួចរស់ជីវិតពីការវាយប្រហារដោយទឹកអាស៊ីត ភាពធ្ងន់ធ្ងរនៃបទល្មើស ឬមានបញ្ចូលនូវបទបញ្ញត្តិសមរម្យពាក់ព័ន្ធទៅនឹងការដាក់ទណ្ឌកម្មចំពោះបទល្មើសដែលពាក់ព័ន្ធនឹងការប្រើប្រាស់ទឹកអាស៊ីតនោះទេ ។ យោងតាម លោក ហ្គោឡូកលី នៅពេលរឿងក្តីពាក់ព័ន្ធនឹងអំពើហិង្សាដោយទឹកអាស៊ីតត្រូវជំនុំជម្រះ រឿងទាំងនេះត្រូវបានបញ្ជូនទៅតុលាការកាត់ក្តីរឿងគ្រួសារជាជាងបញ្ជូនទៅតុលាការព្រហ្មទណ្ឌ ដោយសារតែអំពើហិង្សាដោយទឹកអាស៊ីតភាគច្រើនពាក់ព័ន្ធទៅនឹងបញ្ហាគ្រួសារ[១០១] ដែលតាមរយៈវាបង្ហាញពីការមិនទទួលស្គាល់លើទម្រង់ព្រហ្មទណ្ឌនៃអំពើនេះ ។ សហគមន៍អង្គការក្រៅរដ្ឋាភិបាលមានជំនឿថា ច្បាប់គ្រប់គ្រងអាស៊ីត អាចបញ្ចៀសជនដៃដល់មិនឲ្យប្រើអំពើហិង្សាទឹកអាស៊ីត ។ ដោយហេតុនេះហើយ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ជាពិសេសអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានបញ្ចុះបញ្ចូលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យបង្កើតច្បាប់នេះ ។ យោងតាមមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា *«វិធីគន្លឹះមួយដើម្បីដោះស្រាយអំពើហិង្សាដោយទឹកអាស៊ីត គឺការអនុម័តច្បាប់រឹងមាំមួយដែលមានបញ្ចូលការដាក់ទោស និងការដាក់ពិន័យសមរម្យទៅលើជនដៃដល់នៃអំពើហិង្សាដោយទឹកអាស៊ីត»* ។[១០២]

ច្បាប់ស្តីពីអាស៊ីត បានចែងថា មនុស្សឃាតដោយចេតនាដោយប្រើប្រាស់ទឹកអាស៊ីតត្រូវជាប់ពន្ធនាគារពី ១៥ឆ្នាំ ទៅ ៣០ឆ្នាំ ហើយអាចនឹងបន្ថែមឲ្យជាប់ទោសមួយជីវិត ប្រសិនបើឧក្រិដ្ឋជនលបវាយប្រហារ ឬធ្វើទារុណកម្មលើជនរងគ្រោះមុន ឬអំឡុងពេលសម្លាប់ ។[១០៣] ការធ្វើទារុណកម្មនិងប្រព្រឹត្តអំពើព្រៃផ្សៃដទៃទៀតដោយទឹកអាស៊ីតអាចត្រូវដាក់ទោសពី ១០ ទៅ ២០ឆ្នាំ ហើយអាច

[១០១] Gollogly et al., *កំណត់ចំណាំលេខ ៦៣*, ទំព័រ ៣៣៣ ។

[១០២] បទសម្ភាសន៍ជាមួយបុគ្គលិក CCHR តាមរយៈសារអេឡិចត្រូនិច ។

[១០៣] ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីតខ្លាំងឆ្នាំ (អនុម័តនៅខែមករា ទី១១ ឆ្នាំ២០១២), មាត្រា ១៦ ។

បន្ថែមទោសពី ១៥ ទៅ ២៥ឆ្នាំ ប្រសិនបើទារុណកម្មនោះធ្វើឲ្យជនរងគ្រោះ ពិការអស់មួយជីវិត និងពី២០ ទៅ៣០ឆ្នាំក្នុងករណីអំពើទារុណកម្មធ្វើឲ្យជនរងគ្រោះស្លាប់ដោយអចេតនា ឬធ្វើអត្តឃាត ។[១០៤] ការប្រព្រឹត្តអំពើហិង្សាដោយទឹកអាស៊ីតដោយចេតនាត្រូវពិន័យឲ្យជាប់ទោសពី ២ ទៅ ៥ឆ្នាំ ហើយអាចបន្ថែមដល់ ៥ ទៅ ១០ឆ្នាំ ប្រសិនបើនាំឲ្យជនរងគ្រោះពិការអស់មួយជីវិត និងបន្ថែមដល់១៥ ទៅ២៥ឆ្នាំ ប្រសិនបើអំពើហិង្សាដោយចេតនានាំទៅដល់មនុស្សឃាតដោយអចេតនា ឬអត្តឃាតដោយជនរងគ្រោះ ។[១០៥] ច្បាប់ស្តីពីអាស៊ីត បានចែងថារាជរដ្ឋាភិបាលនឹងផ្តល់ការថែទាំសុខភាព ការជ្រោមជ្រែង និងការពារផ្នែកច្បាប់ដល់ជនរងគ្រោះដោយទឹកអាស៊ីត ។[១០៦] ប៉ុន្តែ ជាក់ស្តែង ច្បាប់នេះមិនបានចែងពីរបៀបនៃការជ្រោមជ្រែងទាំងនោះទេ ។ បើទោះបីជាច្បាប់ស្តីពីអាស៊ីត ត្រូវបានអនុម័តឡើងតាំងពីខែធ្នូ ឆ្នាំ២០១១ក៏ដោយ ក៏ប្រជាជនកម្ពុជាបានដឹងតិចតួចអំពីវត្តមាន និងវិធីអនុវត្តច្បាប់នេះកាន់តែតិចតួចទៅទៀត ។ យោងតាមមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា កម្មវិធីបណ្តុះស្មារតីទ្រង់ទ្រាយធំមួយ គួរតែត្រូវធ្វើឡើង ដើម្បីធានាថាសាធារណជនបានយល់ដឹងពីបញ្ហាទាំងនេះ ។[១០៧]

ការបង្កើតច្បាប់នេះឡើង ជាការទទួលស្គាល់ផ្លូវការលើអំពើហិង្សាដោយទឹកអាស៊ីត ។ តាមទ្រឹស្តី ការបង្កើតច្បាប់មានន័យថាឧក្រិដ្ឋជននឹងត្រូវទទួលខុសត្រូវលើបទល្មើសដែលខ្លួនប្រព្រឹត្ត ។ លោក សាមមេន បានបន្ថែមថា ច្បាប់ស្តីពីអាស៊ីតស្តែងឲ្យឃើញពីការរីកចម្រើនទៅមុខ ដោយសារប្រទេសភាគច្រើនពុំទាន់មានច្បាប់ជាក់លាក់ដើម្បីដោះស្រាយបញ្ហានេះនៅឡើយ ។[១០៨] បើទោះបីជាការបង្កើតច្បាប់ស្តីពីអាស៊ីតគឺជាការរីកចម្រើនវិជ្ជមានមួយក៏ដោយ ក៏ការអនុវត្តច្បាប់គឺជាឧបសគ្គចម្បងមួយ ។ ដើម្បីឲ្យច្បាប់មួយមានសុពលភាព ទាល់តែព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីក្នុងជួររដ្ឋាភិបាលអនុវត្ត និងប្រតិបត្តិច្បាប់នោះតាមរយៈការដាក់ទោសឧក្រិដ្ឋជន ដែលបង្ហាញថា គ្មាននិទណ្ឌភាពនៃអំពើហិង្សាដោយទឹកអាស៊ីត ។ ប្រព័ន្ធច្បាប់កម្ពុជាពុំទាន់អនុវត្តបានត្រឹមត្រូវនៅឡើយទេ ពោលគឺមិនត្រឹមតែ

---

[១០៤] ដូចខាងលើ, មាត្រា ១៩ ។

[១០៥] ដូចខាងលើ, មាត្រា ២០ ។

[១០៦] ដូចខាងលើ, មាត្រា ១០ - ១២ ។

[១០៧] បទសម្ភាសន៍ជាមួយបុគ្គលិក CCHR តាមរយៈសារអេឡិចត្រូនិច ។

[១០៨] បទសម្ភាសន៍ជាមួយលោក ហៀត សាមមេន ប្រធានគម្រោងនៅ CASC ។

ការអនុវត្តច្បាប់ពាក់ព័ន្ធនឹងទឹកអាស៊ីតប៉ុណ្ណោះទេ និយាយរួមគឺការអនុវត្តច្បាប់ណាក៏ដោយនៅកម្ពុជាជាបញ្ហាចោទតែម្តង ។[១០៩]

### ៤.២.១ អនុក្រឹត្យស្តីពីបែបបទ និងលក្ខខណ្ឌនៃការគ្រប់គ្រងអាស៊ីតខ្លាំង

អនុក្រឹត្យស្តីពីអាស៊ីត ត្រូវបានអនុម័តឡើងសម្រាប់ជំនួយដល់ការអនុវត្តច្បាប់ស្តីពីអាស៊ីត និងសម្រាប់ផ្តល់បទបញ្ញត្តិជាក់លាក់ពាក់ព័ន្ធនឹងប្រធានបទដុំវិញច្បាប់នេះ ។ បើយោងតាមអនុក្រឹត្យនេះ អនុក្រឹត្យនេះ“មានគោលបំណងកំណត់ពីបែបផែន និងលក្ខខណ្ឌ នៃការលក់ ការទិញ ការរក្សាទុក ការចែកចាយ ការដឹកជញ្ជូន ការវេចខ្ចប់ ការយកតាមខ្លួន និងការប្រើប្រាស់អាស៊ីតខ្លាំងគ្រប់ប្រភេទ” ។[១១០] បញ្ញត្តិច្បាប់ចែងមានដូចខាងក្រោម៖ អ្នកលក់ និង អ្នកចែកចាយអាស៊ីតខ្លាំងត្រូវតែមានទីតាំងចែកចាយ ដែលប្រគល់អាជ្ញាប័ណ្ណដោយអាជ្ញាធររដ្ឋបាល ។ អ្នកលក់ត្រូវតែកត់ត្រារាល់គ្រប់ព័ត៌មានពាក់ព័ន្ធនឹងការទិញលក់ និងអត្តសញ្ញាណរបស់របស់អតិថិជន និង ត្រូវតែវេចខ្ចប់ និងទុកដាក់ទឹកអាស៊ីតនៅក្នុងដប ឬធុងមានសុវត្ថិភាព ហើយមានបិទស្លាកសញ្ញាហាមប្រាមជាភាសាខ្មែរ និងមានវិញ្ញាប័នបត្របង្ហាញពីប្រភពនៃទំនិញ ឲ្យបានត្រឹមត្រូវ ។[១១១]

អ្នកទិញទឹកអាស៊ីតត្រូវតែមានអាយុយ៉ាងតិច១៨ឆ្នាំ ហើយត្រូវមានឯកសារបង្ហាញពីមុខងារបច្ចេកទេសដែលត្រូវការប្រើប្រាស់ទឹកអាស៊ីត បង្ហាញឲ្យជាក់លាក់ពីគោលបំណងនៃការទិញទឹកអាស៊ីតព្រមទាំងទុកវិក័យបត្រសម្រាប់ការត្រួតពិនិត្យក្នុងពេលដឹកជញ្ជូន ។[១១២] ឃ្លាំងផ្ទុកអាស៊ីតត្រូវមានទីតាំងនៅឆ្ងាយពីទីប្រជុំជន មានបំពាក់ប្រព័ន្ធសុវត្ថិភាព មានការការពារនិងពន្លត់អគ្គីភ័យ កត់ត្រារាល់វត្តមាននៃទឹកអាស៊ីតទាំងអស់ និង ត្រូវគោរពតាមបទដ្ឋានបច្ចេកទេសនៃការស្តុកទុកសារធាតុគីមី ។[១១៣] ការដឹកជញ្ជូនអាស៊ីតត្រូវតែធ្វើឡើងដោយគោរពតាមបទដ្ឋានបច្ចេកទេស អាស៊ីតខ្លាំងដែលត្រូវបានវេចខ្ចប់ត្រឹមត្រូវប៉ុណ្ណោះដែលអាចដឹកជញ្ជូនបាន ហើយការដឹកជញ្ជូនទឹកអាស៊ីតដែលមានចំណុះពី

---

[១០៩] *Asia Regional Cooperation to Prevent People Trafficking, មើលកំណត់ចំណាំលេខ ៩៦, ទំព័រ ៤៣ ។*

[១១០] *អនុក្រឹត្យ, មើលកំណត់ចំណាំលេខ ៨, ទំព័រ ១៨៨៨ ។*

[១១១] *ដូចខាងលើ, មាត្រា ៦, ១០ ទំព័រ ១៨៨៩-១៨៩០ ។*

[១១២] *ដូចខាងលើ, មាត្រា ៧, ទំព័រ ១៨៨៩ ។*

[១១៣] *ដូចខាងលើ, មាត្រា ៨, ទំព័រ ១៨៨៩-១៨៩០ ។*

១០០០គីឡូក្រាមឡើងទៅ មិនត្រូវអនុញ្ញាតឲ្យធ្វើដំណើរកាត់តាមទីមានមនុស្សរស់នៅច្រើនដាដាច់ខាត ។[១១៤]

បើទោះបីជាអនុក្រឹត្យស្តីពីអាស៊ីត ជាជំហ៊ានឈានទៅរកការកាត់បន្ថយនូវគ្រោះថ្នាក់កើតឡើងដោយអាស៊ីតក៏ដោយ ក៏ន័យសេចក្តីមួយចំនួននៃអនុក្រឹត្យនៅមានភាពមិនច្បាស់លាស់ដែលតម្រូវឲ្យមានការបញ្ជាក់បន្ថែម ។ ឧទាហរណ៍ មាត្រា៨ បានចែងថា ឃ្លាំងផ្ទុកត្រូវតែនៅឆ្ងាយពីទីប្រជុំជន ប៉ុន្តែ នៅក្នុងការអនុវត្ត ពាក្យ“នៅឆ្ងាយ” នៅពុំច្បាស់លាស់នោះទេ ។ តើឆ្ងាយប៉ុណ្ណាទើបគ្រប់គ្រាន់? លើសពីនេះទៅទៀត ច្បាប់បានចែងថា “កងនគរបាលជំនាញ” នឹងធ្វើការត្រួតពិនិត្យលើប្រព័ន្ធការពារនិងពន្លត់អគ្គីភ័យ ។ ក៏ប៉ុន្តែ អង្គភាពប្រភេទនេះនៅមិនទាន់មាននៅឡើយទេ បច្ចុប្បន្ននេះ ។ តើនរណាជាអ្នកបង្កើតកងនគរបាលនេះ ហើយតើត្រូវទទួលការហ្វឹកហ្វឺនដោយរបៀបណា?

អនុក្រឹត្យនោះបានចែងដែរថា ប្រព័ន្ធការពារសុវត្ថិភាព មធ្យោបាយដឹកជញ្ជូន និងរបៀបបោះចោលទឹកអាស៊ីត ត្រូវតែធ្វើតាម“បទដ្ឋានបច្ចេកទេស” ប៉ុន្តែ បទដ្ឋានទាំងនោះមិនត្រូវបានបញ្ជាក់ឲ្យលំអិតនោះទេ ។ លើសពីនេះទៅទៀត គេមិនប្រាកដទេថាតើបញ្ញត្តិច្បាប់ទាំងនេះមានឥទ្ធិពលយ៉ាងណាដល់អ្នកលក់តូចតាចមួយចំនួនធំនៅតាមខេត្ត ជាពិសេស អ្នកនៅតំបន់ដាច់ស្រយាលបំផុត ។ តើវាអាចជាការពិតដែរទេដែលថា អ្នកលក់នៅតាមថ្នាក់មូលដ្ឋានបានដឹងពីបទបញ្ញត្តិទាំងនេះ? តើពួកគាត់មានសមត្ថភាពក្នុងការគោរពតាមបទដ្ឋានសុវត្ថិភាពថ្មី ដូចជាការដំឡើងប្រព័ន្ធការពារ និងពន្លត់អគ្គីភ័យដែរឬក៏អត់? ប្រសិនបើពួកគាត់មិនអាចគោរពតាម តើនឹងមានផលវិបាកអ្វីខ្លះ? ច្បាប់មានឥទ្ធិពលខ្លាំងលុះណាតែមានការអនុវត្ត និងប្រតិបត្តិតាមយ៉ាងជាប់លាប់ ។ ដើម្បីឲ្យអនុក្រឹត្យមានឥទ្ធិពលពិតប្រាកដ អាជ្ញាធរត្រូវតែមានចំណាត់ការសមស្របជាមួយអ្នកដែលមិនគោរពតាមបទបញ្ញត្តិដែលបានចែងក្នុងអនុក្រឹត្យ ។ សំណួរទាំងនេះនាំឲ្យយើងអាចធ្វើការសន្និដ្ឋានថា អនុក្រឹត្យស្តែងឲ្យឃើញពីការរីកចម្រើនមួយ ប៉ុន្តែដោយសារតែអនុក្រឹត្យនៅមានការខ្វះខាតដែលធ្វើឲ្យប៉ះពាល់ដល់អានុភាពនៃអនុក្រឹត្យនោះនៅពេលអនុវត្ត ។

គួរឲ្យកត់សម្គាល់ អនុក្រឹត្យ និងច្បាប់ស្តីពីអាស៊ីតគ្រាន់តែចែងពីសារធាតុដែលចាត់ទុកជាអាស៊ីតខ្លាំងប៉ុណ្ណោះ ហើយមិនបានរាប់បញ្ចូលអាស៊ីតស៊ុលភួរិចដែលមានកំហាប់ក្រោម៣៣ភាគរយជាអាស៊ីតខ្លាំងនោះទេ ។ ប៉ុន្តែ អាស៊ីតស៊ុលភួរិចជាអាស៊ីតមួយប្រភេទដែលគេនិយមប្រើជាទូទៅដោយសារ

---

[១១៤] ដូចខាងលើ, មាត្រា ៩, ទំព័រ ១៤៩០ ។

វាប្រើនៅក្នុងអាគុយ ។[១១៥] បើទោះបីជាអាស៊ីតស៊ុលហ្វួរិចនេះជាអាស៊ីតរាវក៏ដោយ ក៏អាស៊ីតប្រភេទនេះនៅតែអាចធ្វើឲ្យរលាកបានដែរ ។ ការដែលមិនបានរាប់បញ្ចូលប្រភេទអាស៊ីតដែលគេនិយមប្រើជាទូទៅ អាចបង្កើតឲ្យមាននូវភាពប្រថុយប្រថានដែលថា បញ្ហានឹងមានការផ្លាស់ប្តូរទិសដៅ ហើយការប្រើអាស៊ីតបញ្ចូលអាគុយដើម្បីធ្វើការវាយប្រហារនឹងមានការកើនឡើង ។ លើសពីនេះទៅទៀត ដោយសារតែអាស៊ីតសម្រាប់បញ្ចូលអាគុយតែងតែត្រូវបានប្រើប្រាស់ជាទូទៅ ការមិនដាក់ឲ្យអាស៊ីតប្រភេទនេះនៅក្រោមបទបញ្ញត្តិសុវត្ថិភាពស្តីពីការថែរក្សា និងការដឹកជញ្ជូន នឹងអាចកាត់បន្ថយប្រសិទ្ធិភាពនៅក្នុងការការបញ្ចៀសគ្រោះថ្នាក់ផ្សេងៗ ។

## ៤.៣. ឧបសគ្គទូទៅដែលរារាំងជនរងគ្រោះពីការទទួលបានយុត្តិធម៌

ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់កម្ពុជា មានបញ្ហាជាច្រើន ប៉ុន្តែ និទណ្ឌភាព ជាបញ្ហានាំមុខគេ ។ បើយោងតាមអ្នកកាសែត ដេវីដ ប្រ៊ីងគ្លី (David Brinkley) ពាក្យដែលសក្តិសមសម្រាប់ធ្វើការពណ៌នាប្រព័ន្ធតុលាការកម្ពុជានោះគឺពាក្យ "និទណ្ឌភាព" ។[១១៦] នៅកម្ពុជា អ្នករំលោភបំពានច្បាប់ និងសិទ្ធិមនុស្ស តែងតែដើរហើរដោយសេរី ដោយពុំមានការចាប់ខ្លួន និងជំនុំជម្រះលើអំពើដែលបានប្រព្រឹត្តឡើយ ។ ប្រេដ អាដាម (Brad Adam) ពីអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានកត់សម្គាល់ថា នៅកម្ពុជា នេះគឺជាការពិត "បើទោះបីជាអំពើរបស់ពួកគេប្រព្រឹត្តអាក្រក់យ៉ាងណាក៏ដោយ" ។ លោក អាដាម ក៏បានបញ្ជាក់ដែរថា ប្រជាជនកម្ពុជាមានការពិបាកក្នុងការផ្តល់សេចក្តីទុកចិត្តលើប្រព័ន្ធតុលាការកម្ពុជាព្រោះ *"ជាជាងការពារសិទ្ធិ ប្រព័ន្ធតុលាការកម្ពុជាបែរជាត្រូវបានប្រើប្រាស់សម្រាប់សង្កត់សង្កិនលើមតិជំទាស់ និងធ្វើឲ្យចុះខ្សោយយុត្តិធម៌ទៅវិញ"* ។[១១៧] បញ្ហាមួយចំនួនដែលជាដើមហេតុនៃដំណើរការមិនប្រក្រតីនៃប្រព័ន្ធតុលាការ ។

### ៤.៣.១. កង្វះឯករាជ្យភាពតុលាការ

---

[១១៥] *Breaking the Silence*, មើលកំណត់ចំណាំលេខ ៦, ទំព័រ ៥ ។

[១១៦] Brinkley, មើលកំណត់ចំណាំលេខ ៦៩, ទំព័រ ១១២-១១៣ ។

[១១៧] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, *Cambodia, 15 Years On, No Justice in Grenade Attack* (ថ្ងៃទី២៩ ខែមិនា ឆ្នាំ ២០១២), អាចរកបាននៅគេហទំព័រ: http://www.hrw.org/news/2012/03/29/cambodia-15-years-no-justice-grenade-attack; អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ដកស្រង់ *Cambodia: Shame Courts Undermine Rights* (២៧ ខែធ្នូ ឆ្នាំ២០១២), អាចរកបាននៅគេហទំព័រ: http://www.hrw.org/news/2012/12/27/cambodia-sham-court-cases-undermine-rights

មូលហេតុមួយដែលនាំឲ្យមាននិទណ្ឌភាពនោះគឺការខ្វះឯករាជភាពនៃស្ថាប័នតុលាការ ។ នេះគឺជាកង្វល់ដ៏ចម្បង ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានបញ្ជាក់ថា តុលាការកម្ពុជាមិនមែនជាស្ថាប័នឯករាជ្យនោះទេ ហើយស្ថាប័ននេះគ្រាន់តែជា "អាយ៉ង" របស់រដ្ឋាភិបាលកម្ពុជាតែប៉ុណ្ណោះ ព្រោះការបែងចែកអំណាចពិតប្រាកដគឺពុំមាននោះទេ ។ រដ្ឋាភិបាលមានឥទ្ធិពលយ៉ាងខ្លាំងលើប្រព័ន្ធតុលាការ និងបានប្រើអំណាចនេះដើម្បីធ្វើទុក្ខបុកម្នេញអ្នករិះគន់រដ្ឋាភិបាល និងអ្នកការពារសិទ្ធិមនុស្ស ។[១១៨]

ឧទាហរណ៍ដែលចង្អុលបង្ហាញពីកង្វះការបែងចែកអំណាចរវាងរាជរដ្ឋាភិបាលកម្ពុជា និងប្រព័ន្ធតុលាការកម្ពុជានោះគឺការដែលថា លោក ឌិត មន្ទីរ ដែលជាប្រធានតុលាការកំពូលរបស់កម្ពុជាគឺជាសមាជិកនៃគណៈកម្មការអចិន្ត្រៃយ៍នៃគណៈកម្មការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា និងជាសមាជិកម្នាក់នៃគណៈកម្មការអចិន្ត្រៃយ៍ដែលមានសមាជិក៦នាក់ ។[១១៩] ករណីនេះអាចជាការរំលោភលើទ្រឹស្តីបែងចែកអំណាច (trias politica) ។ យោងតាមអង្គការតម្លាភាពអន្តរជាតិ ដែលជាអង្គការអន្តរជាតិប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅក្នុងឆ្នាំ ២០១១/២០១២ ឯករាជភាពនៃស្ថាប័នតុលាការកម្ពុជាពីឥទ្ធិពលខាងក្រៅ ស្ថិតក្នុងលេខរៀងទី៩៦ក្នុងចំណោម១៤២នៃប្រទេសដែលត្រូវបានវាយតម្លៃ ។[១២០] យោងតាមការស្ទង់ជាសកល (Global Barometer) ឆ្នាំ២០១៣ របស់អង្គការតម្លាភាពអន្តរជាតិ ប្រជាជននៅកម្ពុជាប្រមាណជា៦០ភាគរយគិតថា ស្ថាប័នតុលាការនៅកម្ពុជាបានទទួលឥទ្ធិពលពីអំពើពុករលួយ[១២១] ដែលនេះគឺជាលទ្ធផលគួរឲ្យព្រួយបារម្ភ ។ ប្រព័ន្ធតុលាការ ជាស្ថាប័នមួយដែលបានទទួលរងឥទ្ធិពលពីខាងក្រៅ ជាជាងជាស្ថាប័នមួយដែលមិនលម្អៀង និងអព្យាក្រឹត្យ ។ អ្នកដឹកនាំនយោបាយបានប្រើប្រាស់មុខតំណែង និងអំណាចរបស់ខ្លួនដើម្បីបង្ខំឲ្យចៅក្រម និងព្រះរាជ

---

[១១៨] Frontline Defenders, ដកស្រង់ចេញពី *2013 Annual Report, Global Trends in 2012 for Human Rights Defenders*, ទំព័រ ១០(២០១៣);
អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ដកស្រង់ចេញពី *Cambodia: Escalating Violence, Misuse of Courts* (ខែកុម្ភៈ ឆ្នាំ២០១៣), អាចរកបាននៅគេហទំព័រ: http://www.hrw.org/news/2013/02/01/cambodia-escalating-violence-misuse-courts

[១១៩] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ដកស្រង់ចេញពី *Country Summary: Cambodia* (ខែមករា ឆ្នាំ២០១២), អាចរកបាននៅគេហទំព័រ: http://www.hrw.org/sites/default/files/related_material/cambodia_2012.pdf

[១២០] Transparency International Corruption Perception Index ២០១២, អាចរកបាននៅគេហទំព័រ http://www.transparency.org/country#KHM

[១២១] Transparency International Global Barometer ២០១៣, អាចរកបាននៅគេហទំព័រ: http://www.transparency.org/gcb2013/country/?country=cambodia

អាជ្ញា ឲ្យចេញសេចក្ដីសម្រេចដែលខ្លួនចង់បាន ។[១២២] ការជ្រៀតជ្រែកផ្នែកនយោបាយទៅលើតុលាការបានចោទជាបញ្ហាដែលនាំឲ្យចៅក្រម និងព្រះរាជអាជ្ញាពិបាកក្នុងការបំពេញភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានបញ្ជាក់ថា *“មានតែចៅក្រមដែលក្លាហានទេដែលហ៊ានប្រឆាំងនឹងឥទ្ធិពល ... ព្រះរាជអាជ្ញា*

*ពុះពារជម្នះអ្នកដឹកនាំនៃរដ្ឋដែលដាក់ស្តែងជារដ្ឋឯកបក្ស”* ។[១២៣]

ឧទាហរណ៍ដ៏ល្បីមួយអំពីការជ្រៀតជ្រែកនយោបាយ គឺសំណុំរឿងម្ចាស់ស្ថានីយវិទ្យុ លោក ម៉ម សូណង់ដូ ដែលជាអ្នកគាំពារសិទ្ធិមនុស្ស និងសកម្មជនដែលនិយាយឥតសំចៃ ។ នៅពេលដែលអាជ្ញាធរបណ្ដេញប្រជាជនចេញពីដីធ្លីតាមរយៈសំណើរបស់ក្រុមហ៊ុនចម្ការកៅស៊ូមួយនោះ ក្រុមអាជ្ញាធរបានបាញ់ប្រហារទៅលើក្រុមប្រជាជនដែលមិនព្រមចេញពីផ្ទះរបស់ពួកគេ ដែលបណ្ដាលឲ្យកុមារីម្នាក់ស្លាប់ ។ ក្រោយពីឧប្បត្តិហេតុនេះ លោក សូណង់ដូ ដែលមិនមានវត្តមាននៅពេលបណ្ដេញចេញ ជាមួយនឹងប្រជាជនមួយចំនួនតូច ត្រូវបានគេចាប់ខ្លួនដោយចោទប្រកាន់ថាចូលរួមចលនាអបគមន៍ស្វែងរកឯករាជភាពពីកម្ពុជា ។[១២៤] នៅសាលាដំបូង លោក សូណង់ដូ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន ២០ឆ្នាំ ។ ក្រោយមក នៅឧទ្ធរណ៍ ទោសត្រូវព្យួរ ហើយគាត់ត្រូវដោះលែងទំនងជាដោយសារមានការរិះគន់ពីអង្គការអន្តរជាតិ ។ ប៉ុន្តែ ពុំមាននរណាម្នាក់ទទួលខុសត្រូវចំពោះការស្លាប់របស់កុមារីរងគ្រោះទេ ។[១២៥] បើយោងតាមមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ករណីនេះបង្ហាញឲ្យឃើញនូវភាពមិនស្មើគ្នាក្នុងការអនុវត្តច្បាប់កម្ពុជា និងរបៀបដែលរាជរដ្ឋាភិបាល នឹងប្រើប្រាស់អំណាចដើម្បីសម្រេចលទ្ធផលដែលមានភាពងាយស្រួលខាងនយោបាយ ។[១២៦] ការប្រើ

---

[១២២] Cambodian League for the Promotion and Defense of Human Rights, *Human Rights ២០១២: The Year in Review*, ទំព័រ១១ (ខែកុម្ភៈ ឆ្នាំ២០១៣); World Justice Project, *Rule of Law Index ២០១២-២០១៣*, ទំព័រ ៧៣ (២០១២) ។

[១២៣] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ដកស្រង់ចេញពី , *Khmer Rouge Trial is Failing Cambodian Victims of Pol Pot's Regime* (ខែវិច្ឆិកា ទី២៣ ឆ្នាំ២០១១), អាចរកបាននៅគេហទំព័រ http://www.hrw.org/news/2011/11/23/khmer-rouge-trial-failing-cambodian-victims-pol-pots-regime

[១២៤] CCHR, *Briefing Note*, *មើលកំណត់ចំណាំលេខ ៨៩*, ទំព័រ ៣-៤ ។

[១២៥] K. Hodal, ដកស្រង់ចេញពី អត្ថបទ *Cambodian Activist Mam Sonando to Be Freed in Days*, THE GUARDIAN, ខែមិនា. ទី១៤, ឆ្នាំ២០១៣, អាចរកបាននៅគេហទំព័រ http://www.guardian.co.uk/world/2013/mar/14/cambodian-activist-mam-sonando-freed ។

[១២៦] CCHR, *Briefing Note*, *មើលកំណត់ចំណាំលេខ៨៩*, ទំព័រ ៣-៤ ។

ប្រាស់តុលាការដើម្បីគំរាមកំហែងអ្នកគាំពារសិទ្ធិមនុស្សដោយការកាត់ទោស និងដាក់ឲ្យជាប់ពន្ធនាគារ គឺជាទម្រង់ធ្ងន់ធ្ងរមួយនៃរុកគួនដោយប្រើប្រាស់ប្រព័ន្ធតុលាការ ។[១២៧]

មូលហេតុមួយដែលនាំឲ្យស្ថាប័នតុលាការខ្វះឯករាជភាព គឺដោយសារតែចៅក្រម និងព្រះរាជអាជ្ញា ពុំមានសុវត្ថិភាពនៃការកាន់មុខតំណែង ។ រដ្ឋាភិបាលអាចដកហូតចៅក្រម ឬសម្រេចទុកឲ្យនៅក្នុងតំណែង ដោយសារតែចៅក្រមត្រូវបានគ្រប់គ្រងដោយ បញ្ញត្តិអំពីសហលក្ខន្តិករាជការស៊ីវិល ។ ជាលទ្ធផល ចៅក្រមណាដែលចេញសេចក្តីសម្រេចប្រឆាំងទៅនឹងគោលបំណងរបស់រាជរដ្ឋាភិបាល អាចនឹងមានអាជីពជាចៅក្រមបានត្រឹមរយៈពេលខ្លី ជាងចៅក្រមណាដែលគោរពតាម ។[១២៨] ផ្ទុយទៅវិញ រាជរដ្ឋាភិបាលកម្ពុជាទទូចថា ស្ថាប័នតុលាការកម្ពុជាជាស្ថាប័នដែលមានឯករាជ្យ និង អព្យាក្រឹត្យពេញលេញ ។[១២៩]

ដោយមានជំនួយពីអង្គការសហប្រជាជាតិ និង ម្ចាស់ជំនួយបរទេស សេចក្តីព្រាងច្បាប់ចំនួនពីរដែលមានបំណងចង់បង្កើនឯករាជភាពនៃប្រព័ន្ធតុលាការ ត្រូវបានពង្រៀង ប៉ុន្តែ មិនទាន់បានចូលជាធរមាន ។[១៣០] ច្បាប់សំខាន់ទាំងនេះ នឹងរៀបចំឋានានុក្រមរបស់ចៅក្រម និងព្រះរាជអាជ្ញា រៀបចំប្រព័ន្ធតុលាការ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលតែងតាំង និងដាក់ពិន័យលើចៅក្រម ។[១៣១] គេសង្ឃឹមថា ការអនុម័តច្បាប់ទាំងនេះនឹងនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់ស្ថាប័នតុលាការកម្ពុជា ព្រោះច្បាប់ទាំងនេះនឹងជួយបង្កើតខ្សែបន្ទាត់រវាងអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

---

១២៧ Frontline Defenders មើលកំណត់ចំណាំលេខ ១១៨, ទំព័រ ៤ ។

១២៨ CCHR, *Briefing Note*, មើលកំណត់ចំណាំលេខ ៨៩, ទំព័រ ៤ ។

១២៩ Di Certo, មើលកំណត់ចំណាំលេខ ៨៩, ទំព័រ ២៥ ។

១៣០ ដូចខាងលើ ។

នៅខែកញ្ញា ឆ្នាំ២០១៣ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការសន្យាក្នុងការអនុម័តច្បាប់ចំនួនបីនៅដើមឆ្នាំ២០១៤ ។ Kevin Ponniah, ដកស្រង់ចេញពីអត្ថបទ *Judicial Reform Pledged by PM*, កាសែតភ្នំពេញប៉ុស្ត៍, ខែកញ្ញា ថ្ងៃទី២៦ ឆ្នាំ២០១៣, អាចរកបាននៅគេហទំព័រ http://www.phnompenhpost.com/national/judicial-reform-pledged-pm ។

១៣១ CCHR, *Briefing* មើលកំណត់ចំណាំលេខ ៨៩, ទំព័រ ៣; របាយការណ៍នៃអ្នករាយការណ៍ពិសេសស្តីអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, Surya P. Subedi, U.N. Doc. A/HRC/24/36, ¶ 15 (ខែសីហា ទី៥ ឆ្នាំ២០១៣); របាយការណ៍នៃអ្នករាយការណ៍ពិសេសស្តីអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា Surya P. Subedi, U.N. Doc. A/HRC/15/46, ¶¶ 19-29 (ខែកញ្ញា ទី១៦ ឆ្នាំ២០១០) ។

### ៤.៣.២. អំពើពុករលួយ និងកង្វះធនធាន និងចំណេះដឹង

ពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធទៅនឹងកង្វះឯករាជភាពនៃស្ថាប័នតុលាការកម្ពុជា គឺអំពើពុករលួយ ។ វាជាការពិតដែលត្រូវបានគេទទួលស្គាល់ជាទូទៅដែលថា អំពើពុករលួយបានចាក់ឫសនៅគ្រប់ស្រទាប់ជាន់ថ្នាក់នៃសង្គមនិងស្ថាប័នកម្ពុជា ។ នៅក្នុងប្រព័ន្ធច្បាប់ អំពើពុករលួយយ៉ាងរីករាយដាលត្រូវបានស្តែងឡើងឲ្យឃើញតាមរយៈឧក្រិដ្ឋជនសូកប៉ាន់មន្ត្រីនគរបាល ឬមន្ត្រីយុត្តិធម៌ ដើម្បីបានរួចពីការកាត់ទោស ឬទទួលបានសាលក្រមមិនជាប់ទោស ហើយតាមរយៈនេះ ទទួលបាននិទណ្ឌភាពចំពោះបទល្មើសដែលបានប្រព្រឹត្ត ។ នៅក្នុងឆ្នាំ២០១៣ ៦៥ភាគរយនៃអ្នកចូលរួមនៅក្នុងការស្ទង់មតិមួយរបស់អង្គការតម្លាភាពអន្តរជាតិ បានបង្ហាញថា ពួកគេសូកប៉ាន់តុលាការ ហើយ៦៥ភាគរយក៏បានឆ្លើយតបថាពួកគេធ្លាប់សូកប៉ាន់នគរបាល ។[១៣២] មន្ត្រីនគរបាល ចៅក្រម និងព្រះរាជអាជ្ញា សុទ្ធតែត្រូវបានមើលឃើញថា ពុករលួយ មានឆន្ទៈទទួលយកសំណូក និងការណែនាំពីអ្នកដែលមានអំណាចនីតិប្រតិបត្តិ ។[១៣៣]

បុគ្គលដែលមានខ្សែជាឥស្សរជននយោបាយជាញឹកញាប់មាននិទណ្ឌភាព សូម្បីតែពួកគេត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរក៏ដោយ ដោយសារតែខ្សែរបស់ពួកគេ ឬអំណាចផ្ទាល់ខ្លួនរបស់ពួកគេ ។[១៣៤] ជារៀងរាល់ឆ្នាំ អង្គការតម្លាភាពអន្តរជាតិតែងតែចេញផ្សាយតារាងការយល់ឃើញនៃអំពើពុករលួយ ។ ការបោះពុម្ពផ្សាយចុងក្រោយបង្អស់ឆ្នាំ២០១២ បានចំណាត់ថ្នាក់កម្ពុជានៅខាងក្រោមតារាង នៅលេខរៀង១៥៧ ក្នុងចំណោម១៧៦ប្រទេស មានន័យថាសេវាសាធារណៈរបស់កម្ពុជាត្រូវបានគេចាត់ទុកថា ជាសេវាសាធារណៈមួយ ដែលស្ថិតនៅក្នុងចំណោមសេវាសាធារណៈពុករលួយបំផុតនៅក្នុងពិភពលោក ។[១៣៥] ឧទាហរណ៍ នៃអំពើពុករលួយអាចរួចមានការទាមទារឲ្យជនរងគ្រោះបង់ប្រាក់ពិន័យ មុនជម្រះរឿងក្តីរបស់ខ្លួន និងការទទួលប្រាក់សំណូកដើម្បី

---

[១៣២] Transparency International Global Barometer ២០១៣, អាចរកបាននៅគេហទំព័រ http://www.transparency.org/gcb2013/country/?country=cambodia

[១៣៣] Di Certo, *មើលកំណត់ចំណាំលេខ ៨៩*, ទំព័រ ២៥ ។

[១៣៤] CCHR, *Briefing Note*, *កំណត់ចំណាំលេខ ៨៩*, ទំព័រ ២ ។

[១៣៥] Transparency International Corruption Perception Index ២០១២, អាចរកបាននៅគេហទំព័រ http://www.transparency.org/country#KHM ។

ដោះលែងជនសង្ស័យ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានលើកឡើងថា "*អស់រយៈពេលជាយូរពេកហើយ ព្រះរាជអាជ្ញា និងចៅក្រម ត្រូវបានគេប្រើប្រាស់ជាឧបករណ៍សម្រាប់ការពារអ្នកដែលទទួលបានការជ្រោមជ្រែងពីអាជ្ញាធរកម្ពុជាដែលមានអំណាច*" ។[១៣៦] អង្គការឃ្លាំមើលសិទ្ធិមនុស្សក៏បានអំពាវនាវឲ្យបញ្ចប់និទណ្ឌភាពផងដែរ ។

បញ្ហាមួយទៀតដែលប្រព័ន្ធយុត្តិធម៌កម្ពុជាជួបប្រទះនោះ គឺកង្វះបទពិសោធន៍ និងវគ្គហ្វឹកហ្វឺនសម្រាប់កម្លាំងនគរបាល និងប្រព័ន្ធតុលាការ ។ ដើម្បីឲ្យរឿងក្ដីមួយបានទទួលជោគជ័យនៅក្នុងតុលាការ (ជាពិសេស ការនាំទៅដល់ការដាក់ទោស) ភស្តុតាងរឹងមាំគឺមានភាពចាំបាច់ណាស់ ។ ប៉ុន្តែ ដោយសារតែការខ្វះខាតនូវធនធាន និងចំណេះដឹង តុលាការពុំបានទទួលភស្តុតាងរឹងមាំគ្រប់ពេលវេលានោះទេ ។ បញ្ហានេះបានស្ដែងឡើង ទាំងនៅអំឡុងពេលស៊ើបអង្កេត និងក្នុងដំណាក់កាលជំនុំជម្រះក្ដី ។ ចំណេះដឹង និងជំនាញស៊ើបអង្កេតរបស់មន្ត្រីនគរបាលនៅមានកម្រិតនៅឡើយ ដោយសារតែពុំមានការហ្វឹកហ្វឺនគ្រប់គ្រាន់ ។ លើសពីនេះទៅទៀត កម្លាំងនគរបាលនៅមិនទាន់មានសម្ភារ និងឧបករណ៍គ្រប់គ្រាន់សម្រាប់ស៊ើបអង្កេត ។ ឧទាហរណ៍ មានការខ្វះខាតបន្ទប់សម្រាប់ធ្វើបទសម្ភាសន៍ជនរងគ្រោះ និងសាក្សី ជាលក្ខណៈឯកជន និងមានផាសុខភាព ។[១៣៧] កង្វះខាតទីកន្លែងឯកជនសម្រាប់ធ្វើបទសម្ភាសន៍អាចនាំឲ្យជនរងគ្រោះ និងអ្នករួចរស់ជីវិត ពុំមានផាសុខភាពគ្រប់គ្រាន់ ក្នុងការនិយាយរឿងរបស់ខ្លួន និងផ្ដល់សក្ខីកម្មឲ្យបានពេញលេញ ។ កង្វះខាតចំណេះដឹងអំពីជំនាញស៊ើបអង្កេត និងហ្វឹកហ្វឺននៅក្នុងការស៊ើបអង្កេត អាចរួមចំណែកដល់ការស៊ើបអង្កេតមួយដែលមិនពេញលេញ ។[១៣៨]

ស្ថាប័នតុលាការ ក៏នៅមានកង្វះខាតចំណេះដឹងផ្នែកច្បាប់ និងសិទ្ធិមនុស្សដែរ មិនទទួលបានការហ្វឹកហ្វឺនគ្រប់គ្រាន់ និងមានសមត្ថភាពទទួលចំនួនរឿងក្ដីនៅមានកម្រិត ។ នៅក្នុងគម្រោងអង្កេតសវនាការ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានរកឃើញថា សវនាការប្រព្រឹត្តទៅក្នុងលក្ខណៈប្រញាប់ប្រញាល់ដោយសារតែរឿងក្ដីមានចំនួនច្រើន សាលក្រមមានផ្ដល់ហេតុផលច្បាប់តិចតួច ឬគ្មានហេតុ

---

១៣៦ *អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ដកស្រង់ចេញពី* *Cambodia: Investigate Government Cover-Up* *(ខែធ្នូ ទី២២ ឆ្នាំ២០១២), អាចរកបាននៅគេហទំព័រ*
http://www.hrw.org/news/2012/12/22/cambodia-investigate-government-cover ។

១៣៧ Asia Regional Cooperation to Prevent People Trafficking, *មើលកំណត់ចំណាំលេខ ៩៦*, ទំព័រ ៤៤ ។

១៣៨ *ដូចខាងលើ ។ ការស៊ើបអង្កេតលើអំពើហិង្សាដោយទឹកអាស៊ីតនៅប្រទេសដទៃក៏ត្រូវបានរារាំងដោយកង្វះខាតជំនាញការស៊ើបអង្កេត និងកត្តាជំរុញផងដែរ*, *មើល* Shah, *កំណត់ចំណាំលេខ ៣២*, ទំព័រ. ១១៨២ ។

ផលច្បាប់តែម្តង ហើយគុណភាពនៃអំណោះអំណាងច្បាប់គឺមានលក្ខណៈខ្សោយ ។[១៣៩] ឧទាហរណ៍មួយនៃសមិទ្ធផលវិជ្ជមាន គឺការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវតុលាការ ដែលអាចផ្តល់វគ្គហ្វឹកហ្វឺន និងការអប់រំ និងដែលអាចបង្កើនចំនួនអ្នកប្រកបវិជ្ជាជីវច្បាប់មានសមត្ថភាព និងជំនាញបានច្រើនជាងមុន ។ ប៉ុន្តែ កេរ្តិ៍ឈ្មោះរបស់រាជបណ្ឌិតសភានេះមានប្រឡាក់ដាមទៅដោយរឿងពុករលួយ ។[១៤០] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានរាយការណ៍ថា បើទោះបីជាមានការប្រឹងប្រែងដើម្បីអភិវឌ្ឍវិស័យច្បាប់ និងវិស័យតុលាការក៏ដោយ ក៏វិស័យទាំងពីរនេះនៅតែអភិវឌ្ឍយឺតជាងវិស័យដទៃ ។[១៤១]

ប៉ុន្តែ អ្វីដែលមិនត្រូវភ្លេចនោះគឺថា ប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងតែកសាងសាជាថ្មីក្រោយពីរងគ្រោះដោយសង្គ្រាម និងការរំលោភសិទ្ធិមនុស្សអស់ជាច្រើនទសវត្សរ៍ ។ នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម អ្នកចេះដឹងស្ទើរតែទាំងអស់បានចាកចេញពីប្រទេស ត្រូវសម្លាប់ ឬស្លាប់ដោយសារជំងឺ ឬការអត់ឃ្លាន ។ មានតែអ្នកចេះដឹងមួយចំនួនតូចប៉ុណ្ណោះដែលបានរួចជីវិត ។ គ្រូបង្រៀន គ្រូពេទ្យ និង អ្នកច្បាប់ ត្រូវបានលុបបំបាត់ជាលក្ខណៈប្រព័ន្ធ ដោយសារតែរបបនោះជឿថា អ្នកចេះដឹងជាការគំរាមកំហែងដល់ការស្រមើសម័យវិស័យកសិកម្មហួសវិស័យដែល ប៉ុល ពត និងអ្នករួមគំនិតជាមួយគាត់បានគិតទុក ។[១៤២] វាច្បាស់ណាស់ថា របបនេះបានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងទៅលើមូលដ្ឋានចំណេះដឹង និងសមត្ថភាពយុត្តិធម៌នៅកម្ពុជា ។ អស់រយៈពេលជាងបីទសវត្សរ៍មក សហគមន៍អន្តរជាតិបានខិតខំជាខ្លាំងក្នុងការជ្រោមជ្រែងបង្កើតក្របខណ្ឌសម្ព័ន្ធតុលាការវិជ្ជាជីវៈមួយដែលផ្អែកលើនីតិរដ្ឋ ។[១៤៣] ប៉ុន្តែ កំណែទម្រង់ និងការផ្លាស់ប្តូរមិនអាចសម្រេចបាននោះទេ បើសិនជាគ្មានឆន្ទៈ និងការជ្រោមជ្រែងផ្នែកនយោបាយ ។ មកទល់ពេលនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាហាក់បីដូចជាចាប់អារម្មណ៍លើការអភិវឌ្ឍសេដ្ឋកិច្ចជាងប្រព័ន្ធច្បាប់ដែលមាន

[១៣៩] CCHR, *កំណត់ចំណាំលេខ ៩២, ទំព័រ ២ ។*

[១៤០] *ពុំមានឈ្មោះអ្នកនិពន្ធច្បាស់លាស់, CAMBODIA: To Be a Judge, Be Ready to Bribe: Students (ខែឧសភា ទី១២ ២០០៩), អាចរកបាននៅគេហទំព័រ* http://www.humanrights.asia/news/forwarded-news/AHRC-FAT-004-2009/?searchterm%3E ។

[១៤១] *បទសម្ភាសន៍ជាមួយបុគ្គលិក* CCHR *តាមរយៈសារអេឡិចត្រូនិច ។*

[១៤២] Di Certo, *មើលកំណត់ចំណាំលេខ ៨៩, ទំព័រ ២៥ ។*

[១៤៣] M. Montesano, *ដកស្រង់ចេញពីអត្ថបទ Current International Efforts in Cambodia: Developing a Court System to Protect Human Rights*, ១១ J. L. & Soc. Challenges *៧១, ៧២ (រដូវស្លឹកឈើជ្រុះ ២០០៩) ។*

ដំណើរការល្អ ។[១៤៤] ដូច្នេះ កន្លះប្រព័ន្ធច្បាប់ដែលមានដំណើរការល្អមួយអាចបណ្តាលមកពីរាជរដ្ឋាភិបាលកម្ពុជា និងថ្នាក់ដឹកនាំ ។[១៤៥]

សរុបមក អំពើពុករលួយដែលមានលក្ខណៈរីករាលដាល និងអាកប្បកិរិយាផ្ទុយរបស់រដ្ឋាភិបាលបូករួមទាំងកេរដំណែលពីសង្គ្រាមអស់ជាច្រើនទសវត្សរ៍ផង បានបន្សល់ទុកនូវប្រព័ន្ធច្បាប់ប្រេះស្រាំនៅកម្ពុជា ដែលសិទ្ធិប្រជាពលរដ្ឋមិនត្រូវបានការពារឲ្យបានត្រឹមត្រូវ ហើយមានដំណោះស្រាយផ្លូវច្បាប់តិចតួច ឬគ្មានទាល់តែសោះ សម្រាប់ដោះស្រាយចំពោះការរំលោភសិទ្ធិមនុស្ស ឬបទល្មើស ។ ជាជាក់ស្តែង អ្នកដែលត្រូវបានគេរំលោភសិទ្ធិ មិនត្រូវបានអនុញ្ញាតឲ្យទទួលវិធីដោះស្រាយផ្នែកយុត្តិធម៌ទេ ដោយសារតែកន្លះស្ថាប័នតុលាការដែលឯករាជ្យ មានប្រសិទ្ធិភាព និងអាចទុកចិត្តបាន ។

### ៤.៣.៣. ការលម្អៀង និងការយល់ឃើញ

បញ្ហានៅប្រព័ន្ធយុត្តិធម៌ទាំងមូល បានក្លាយជាឧបសគ្គនៃការទទួលបានយុត្តិធម៌សម្រាប់អ្នករួចរស់ជីវិតពីការរលាកអាស៊ីតដែលស្វែងរកដំណោះស្រាយ ។ លោក សាមមេន បានតាមដានពីបញ្ហាប្រឈមដែលអ្នករួចរស់ជីវិតពីការរលាកអាស៊ីតជួបប្រទះនៅពេលស្វែងរកយុត្តិធម៌ ទៅដល់បញ្ហាប្រឈមដូចគ្នាដែលជួបប្រទះដោយជនជាតិកម្ពុជាគ្រប់ៗគ្នានៅពេលពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌ ។[១៤៦]

ដូចគ្នាទៅនឹងប្រជាជនកម្ពុជាដទៃទៀតដែរ អ្នករស់រានមានជីវិតពីការរលាកទឹកអាស៊ីតជាច្រើនត្រូវពុះពារដើម្បីទទួលបានការជម្រះក្តី និងដើម្បីនាំយកជនដៃដល់ទៅកាត់ទោស ។ ជាឧទាហរណ៍ នាង គ.ស នៅឆ្នាំ២០០៤ បានទទួលរងការវាយប្រហារដោយប្រពន្ធរបស់គូស្នេហ៍នាងនៅពេលដែលគាត់មានផ្ទៃពោះជិត៩ខែ ។ ស្ត្រីជាប្រពន្ធនោះបានជំរុញឲ្យកូនប្រុសដែលនៅពេលនោះមានអាយុ១១ឆ្នាំជះទឹកអាស៊ីត ។ ការវាយប្រហារបានធ្វើឲ្យនាង គ.ស ទទួលរងនូវការរលាកនៅលើមុខ ទ្រូង និងខ្នង ។ ការវាយប្រហារបានធ្វើឲ្យនាងខ្វាក់ភ្នែកមួយចំហៀង ហើយបានធ្វើឲ្យក្មួយប្រុសអាយុ៨ឆ្នាំរបស់នាងទទួលរងនូវការរលាកលើផ្ទៃមុខ ដែលនាំឲ្យបង្ករោគឆ្លងដល់ភ្នែក និងធ្វើឲ្យភ្នែករបស់ក្មេងប្រុសនោះ

---

១៤៤ Di Certo, *មើលកំណត់ចំណាំលេខ ៨៩, ទំព័រ ២៥ ។*

១៤៥ Montesano, *មើលកំណត់ចំណាំលេខ ១៤៣, ទំព័រ ៩២ ។*

១៤៦ *ជនរងគ្រោះ បានប្រាប់ថាគាត់បានបាត់ចំណាប់អារម្មណ៍ក្នុងការដាក់បណ្តឹងតាមផ្លូវច្បាប់ ហើយសុំឲ្យបិទសំណុំរឿងរបស់គាត់ ។ សេចក្តីអង្កេតនេះមិនមែនជាការរិះគន់ពីការសម្រេចចិត្តនោះទេ ប៉ុន្តែអ្នកអានត្រូវតែដឹងថាមិនមែនគ្រប់រឿងក្តីពាក់ព័ន្ធនឹងអំពើហិង្សាដោយទឹកអាស៊ីតទាំងអស់សុទ្ធតែបញ្ចប់មុនពេលដែលតុលាការបានចេញសាលក្រមនោះទេ ដោយសារតែបញ្ហានៅក្នុងប្រព័ន្ធតុលាការ ឬដោយសារតែបញ្ហារបស់សមត្ថកិច្ច ។ ជួនកាល ការបញ្ចប់ដំណើរការតុលាការគឺជាជម្រើសស្ម័គ្រចិត្តរបស់ជនរងគ្រោះផ្ទាល់ ។*

ចុះខ្សោយ ។ ដោយសារបញ្ហាផ្ទាល់ខ្លួន នាង គ.ស ចាំរហូតដល់ឆ្នាំ២០១១ ទើបដាក់ពាក្យបណ្ដឹង ប៉ុន្ដែ រហូតដល់ចុងឆ្នាំ២០១២ ទើបចៅក្រមស៊ើបអង្កេតនៅខេត្តកំពតបើកការស៊ើបអង្កេត ។ អ្វីដែល បានរំពឹងទុកនោះគឺថា ការស៊ើបអង្កេតនឹងអាចបញ្ចប់ក្នុងរយៈពេលប៉ុន្មានខែក្រោយ ហើយការជំនុំជម្រះ ក្ដីអាចធ្វើឡើងក្នុងពេលណាមួយក្រោយខែមិថុនា ឆ្នាំ២០១៣ ។ រហូតដល់ពេលនេះ តុលាការនៅ ពុំទាន់ផ្ដល់ព័ត៌មានណាមួយអំពីស្ថានភាពរឿងក្ដីនេះនៅឡើយទេ ។

ប៉ុន្ដែ អ្នករួចរស់ជីវិតពីការរលាកទឹកអាស៊ីត ត្រូវប្រឈមនឹងបញ្ហាពាក់ព័ន្ធនឹងស្នាមរបួស របស់ខ្លួន ពោលគឺការយល់ឃើញពីអ្នកដទៃ ។ ដូចដែលបានបង្ហាញពីខាងលើ ពេលខ្លះសង្គមសម្ដីងមក ជនរងគ្រោះដោយទឹកអាស៊ីតក្នុងអកប្បកិរិយាអវិជ្ជមាន ហាក់បីដូចជាពួកគេបានប្រព្រឹត្តខុសឆ្គង ហើយសមនឹងទទួលវាសនាបែបនោះ ដូចជាក្នុងករណីដែលជនរងគ្រោះ ជាស្រីកំណាន់ចិត្តរបស់នរណា ម្នាក់ ។ ការយល់ឃើញបែបនេះមិនត្រឹមតែជាការយល់ឃើញធម្មតាដូចគ្នានៅក្នុងចំណោមប្រជាជន កម្ពុជាស៊ីវិលទេ សូម្បីតែចៅក្រម និងព្រះរាជអាជ្ញាក៏យល់ឃើញដូចគ្នាដែរ ។[១៤៧] ហេតុដូច្នេះហើយ ទើបព្រះរាជអាជ្ញា និងចៅក្រម អាចមានភាពស្ទាក់ស្ទើរក្នុងការព្យាយាមដោះស្រាយរឿងក្ដីនៃការវាយ ប្រហារដោយទឹកអាស៊ីត ហើយសម្រេចចិត្តបញ្ឈប់ការជំនុំជម្រះ ។ ជាសំខាន់ លោក សាមមេន បាន ចង្អុលបង្ហាញថា នៅពេលព្រះរាជអាជ្ញា និងចៅក្រម បានធ្វើទំនាក់ទំនងជាមួយអ្នករួចរស់ជីវិតពី ការរលាកទឹកអាស៊ីត ការយល់ឃើញអវិជ្ជមាននេះបានផ្លាស់ប្ដូរ ហើយពួកគេមានឆន្ទៈច្រើនជាងមុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជំនុំជម្រះរឿងក្ដីឲ្យបានសម្រេច ។[១៤៨]

## ៤.៤. ការយល់ឃើញរបស់អ្នករស់រានមានជីវិត

បញ្ហានិទណ្ឌភាពនៃអំពើហិង្សាដោយទឹកអាស៊ីត កើតឡើងមកពីបញ្ហាដែលកើតឡើងនៅគ្រប់ ដំណាក់កាលទាំងអស់នៃដំណើរការព្រហ្មទណ្ឌ ការខកខានមិនបានស៊ើបអង្កេត ការខកខានពុំបានកាត់ ទោស ឬជំនុំជម្រះក្ដី ការផ្ដល់ទោសស្រាល បើប្រៀបទៅនឹងបទល្មើស និងព្យសនកម្មកើតឡើង និង ការអនុវត្តទោសធូរស្រាលុង ។ ជាឧទាហរណ៍ រឿងក្ដីនៃអំពើហិង្សាដោយទឹកអាស៊ីតជាច្រើនដែលមិនបាន ឈានទៅដល់ដំណាក់កាលជំនុំជម្រះ ឬការជំនុំជម្រះត្រូវ“បញ្ឈប់”ត្រឹមចំណុចណាមួយ ដោយសារ អ្នករួចរស់ជីវិតសម្រេចចិត្តមិនចាប់ផ្ដើម ឬបន្តវិធានការច្បាប់ ឬដោយសារមូលហេតុដែលហួស ពីការគ្រប់គ្រងរបស់អ្នករួចរស់ជីវិត ។

---

[១៤៧] បទសម្ភាសន៍ជាមួយលោក ហ្សៀត សាមមេន ប្រធានគម្រោងនៅ CASC ។

[១៤៨] ដូចខាងលើ ។

### ៤.៤.១. ការភ័យខ្លាច និងការមិនទុកចិត្តចំពោះប្រព័ន្ធច្បាប់

មូលហេតុសំខាន់បំផុតដែលរារាំងការជំនុំជម្រះក្តីជនដៃដល់ គឺដោយសារតែអ្នករួចរស់ជីវិតផ្ទាល់ សម្រេចចិត្តមិនដាក់ពាក្យបណ្តឹងក្រោយពីទទួលរងការវាយប្រហារ ។[១៤៩] មូលហេតុរបស់អ្នករួចរស់ជីវិតដែលមិនដាក់ពាក្យបណ្តឹង គឺដោយសារតែខ្លាចមានការសងសឹកពីសំណាក់ជនដៃដល់, ខ្លាចត្រូវចំណាយប្រាក់នៅក្នុងដំណើរការតុលាការ និងជំនួយផ្នែកច្បាប់ កង្វះជំនឿទុកចិត្តលើប្រព័ន្ធច្បាប់ និងការមិនចង់ចំណាយពេលវេលា និងយល់ព្រមដោះស្រាយក្រៅតុលាការ ។[១៥០]

ឧទាហរណ៍ អ្នករួចរស់ជីវិត អ.ដ និង អ.ស ជាបងប្អូនស្រីបង្កើតដែលបានទទួលរងការវាយប្រហារក្នុងពេលតែមួយនៅឆ្នាំ២០០៩ បានអះអាងថា ពួកគាត់មិនបានដាក់ពាក្យបណ្តឹងទេក្រោយពីទទួលរងនូវការវាយប្រហារ ដោយសារតែពួកគាត់ត្រូវធ្វើការនៅហាងរបស់គាត់ និងពុំមានពេលទៅប្តឹងនគរបាល ឬចូលរួមក្នុងដំណើរការជំនុំជម្រះក្តី ។ អ្នករួចរស់ជីវិត ច.សរិទ្ធិ, ច.សដុន និងច.សផាត[១៥១] ដែលត្រូវទទួលរងការវាយប្រហារនៅឆ្នាំ២០១០[១៥២] ក៏បានផ្តល់មូលហេតុដូចគ្នាដែរ ។ ដោយសារអ្នករួចរស់ជីវិតទាំងនេះ ខ្លាចបាត់បង់ប្រាក់ចំណូល ប្រសិនបើពួកគេមិនបានធ្វើការក្នុងរយៈពេលប៉ុន្មានថ្ងៃ ពួកគាត់សម្រេចចិត្តមិនដាក់ពាក្យបណ្តឹង ហើយតាមរយៈនេះ បានរារាំងមិនឲ្យមានដំណើរការជំនុំជម្រះដែលអាចកើតមាននៅពេលខាងមុខ ។ លោក ឆាធើជី មានប្រសាសន៍ថា នៅស្ទើរតែគ្រប់ប្រទេសទាំងអស់ ការស្វែងរកដំណោះស្រាយផ្លូវច្បាប់ឲ្យជនរងគ្រោះនៃអំពើហិង្សាទឹកអាស៊ីតត្រូវចំណាយពេលវេលា និងថវិកាច្រើន ដែលជាបន្ទុកដ៏ធ្ងន់ធ្ងរដល់ជនរងគ្រោះ និងក្រុមគ្រួសារ ។[១៥៣] ដូច្នេះ កង្វះខាត

---

[១៤៩] CCHR, ដកស្រង់ចេញពីអត្ថបទ *Ending the Cycle of Impunity for Acid Crimes in Cambodia*, ទំព័រ ៩ (ខែឧសភា ឆ្នាំ២០០១២) ។

[១៥០] បទសម្ភាសន៍ជាមួយជនរងគ្រោះដោយមានការជ្រោមជ្រែងពី CASC, នៅខែ មីនា ឆ្នាំ ២០១៣ ។

[១៥១] នៅកម្ពុជា មានសមាជិកគ្រួសារជាច្រើនដែលមានឈ្មោះស្រដៀងគ្នា ។ ដូចជានៅក្នុងរឿងក្តីនេះដែរ ។ ហេតុដូច្នេះហើយ ទើបមានអក្សរកាត់ឈ្មោះដូចគ្នា ។ ដើម្បីចៀសវាងការភ័ន្តច្រឡំ ទើបថែមអក្សរមួយតួពីខាងក្រោយឈ្មោះអ្នកទាំងពីរ ។

[១៥២] នៅក្នុងករណីខ្លះ ជនរងគ្រោះសម្រេចចិត្តមិនប្រាប់រឿងរ៉ាវទាំងអស់ដែលបានកើតឡើងនៅអំឡុងពេលវាយប្រហារ ឬថាតើការវាយប្រហារបានកើតឡើងដោយរបៀបណានោះទេ ។ លើសពីនេះទៅទៀត មូលហេតុដែលបានផ្តល់ឲ្យដោយជនរងគ្រោះ ពុំមែនប្រាកដថាជាមូលហេតុដែលពួកគាត់មិនដាក់ពាក្យបណ្តឹងនោះទេ ។ ប៉ុន្តែ ព័ត៌មានទាំងនោះជាព័ត៌មានដែលពួកគាត់ជ្រើសរើសយកមកចែករំលែក ។

[១៥៣] Chatterjee, *មើលកំណត់ចំណាំលេខ ២៩*, ទំព័រ ៧ ។

មធ្យោបាយហិរញ្ញវត្ថុ គឺជាមូលហេតុចម្បងដែលនាំឲ្យជនរងគ្រោះសម្រេចចិត្តមិនធ្វើការប្តឹងផ្តល់ ។ នៅកម្ពុជា អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត មានក្រុមអ្នកច្បាប់ដើម្បីជួយជ្រោមជ្រែង

អ្នករួចរស់ជីវិតក្នុងដំណើរការជំនុំជម្រះក្តី និងជួយចេញប្រាក់ដែលត្រូវចំណាយក្នុងតុលាការ ប៉ុន្តែ អ្នករួចរស់ជីវិតនៅតែគិតថា ការរកដំណោះស្រាយតាមផ្លូវតុលាការនឹងត្រូវចំណាយប្រាក់ច្រើន ហើយក៏សម្រេចចិត្តមិនធ្វើការប្តឹងផ្តល់ ។

ការដែលថា អ្នករួចរស់ជីវិតមិនអាចស្វែងរកយុត្តិធម៌ ដោយសារអាចប៉ះពាល់ដល់ជីវភាព និងបញ្ហាហិរញ្ញវត្ថុផ្សេងៗ គឺជាការគួរឲ្យព្រួយបារម្ភ ដោយសារវាបានបង្ហាញឲ្យឃើញថា ឋានៈសេដ្ឋកិច្ច-សង្គមរបស់នរណាម្នាក់ ដើរតួនាទីយ៉ាងសំខាន់ក្នុងការទទួលបានយុត្តិធម៌ ។ លោកស្ម៊ីត និងខាសលមែន (Smith and Castleman) បានអះអាងថា ភាពក្រីក្រកាន់ តែធ្វើឲ្យបុគ្គលម្នាក់ងាយនឹងត្រូវបដិសេធសិទ្ធិជាមូលដ្ឋាន ។[154] អ្នកទាំងពីរបានលើកករណីអំពើហិង្សា ដោយទឹកអាស៊ីតមកលើស្ត្រីនៅប្រទេសបង់ក្លាដេសជាឧទាហរណ៍ ហើយក៏បានលើកឡើងដែរថា កម្រិតនៃភាពក្រីក្ររបស់ស្ត្រីរងគ្រោះរារាំងសមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតបទៅនឹងការរំលោភសិទ្ធិមនុស្ស ដោយសារពួកគាត់ពុំមានចំណេះដឹងស្តីពីនីតិវិធីច្បាប់ និងទទួលបានជំនួយផ្នែកច្បាប់ ។[155] តាមរបៀបនេះ ការទទួលបានដាក់ស្តែងនូវសេវាសាធារណៈ ត្រូវបានបដិសេធចំពោះអ្នកខ្វះខាតធនធាន និងចំណេះដឹង ។ ភាពក្រីក្រហាក់បីដូចជារនាំងរាំងអ្នករួចរស់ជីវិតពីការស្វែងរកយុត្តិធម៌ និងសំណងជួសជុល ។

កត្តាមួយទៀត ដែលបានដាក់កំហិតដល់ចំនួនជំនុំជម្រះទោសនៃការវាយប្រហារដោយទឹកអាស៊ីត អាចជាទំនាក់ទំនងរវាងជនរងគ្រោះ និងជនល្មើស ។ នៅពេលមានទំនាក់ទំនងគ្រួសារ ឧទាហរណ៍ ក្នុងករណីដែលស្វាមី ឬភរិយាជាជនល្មើស ជនរងគ្រោះអាចមានភាពស្ទាក់ស្ទើរក្នុងការដាក់ពាក្យបណ្តឹង ជាពិសេសប្រសិនបើជនរងគ្រោះត្រូវពឹងផ្អែកលើការទំនុកបម្រុង និងថែទាំងរបស់ជនដៃដល់ ។ ជាក់ស្តែង អ្នករួចរស់ជីវិតមួយចំនួន (សុទ្ធតែជាបុរស ត្រូវទទួលរងការវាយប្រហារដោយទឹកអាស៊ីតពីប្រពន្ធរបស់ខ្លួន ហើយបានពិការភ្នែក បន្ទាប់ពីទទួលរងការវាយប្រហារ) បានប្រាប់ក្នុងបទសម្ភាសន៍ថា ប្រសិនបើពួកគាត់មិនពឹងផ្អែកលើប្រពន្ធឲ្យមើលថែពួកគាត់ទេ ឬក៏មិនរៀបការម្តងទៀតទេ គាត់នឹងដាក់

---

[154] S. Smith & T. Castleman, *ដកស្រង់ចេញពីអត្ថបទ* *Ending Extreme Poverty*, LETRAS LIBRES ៧ (២០០៦), *អាចរកបាននៅគេហទំព័រ* http://papers.ssrn.com/sol3/papers.cfm?abstract_id=1570167 ។

[155] *ដូចខាងលើ*, ទំព័រ ៣-៤ ។

ពាក្យបណ្ដឹងដោះស្រាយតាមផ្លូវច្បាប់មិនខាន ។[១៥៦] ម្នាក់ក្នុងចំណោមនោះបានប្រាប់ថា គាត់មិនដាក់ពាក្យបណ្ដឹងដោយសារតែគាត់ពិការភ្នែក ដោយសារ *"ពុំមានអ្នកមើលថែរក្សាកូនរបស់គាត់"* ហើយប្រសិនបើប្រពន្ធរបស់គាត់ត្រូវបានកាត់ទោស និងចាប់ខ្លួន "តាមផ្លូវច្បាប់ វាជាការល្អ ប៉ុន្តែ មិនល្អសម្រាប់គ្រួសារទេ" ។[១៥៧] អ្នករួចរស់ជីវិតម្នាក់ទៀតបានផ្ដល់ចម្លើយបន្ថែមពាក់ព័ន្ធនឹងការមិនដាក់ពាក្យបណ្ដឹងថា៖ *"ខ្ញុំចង់ឲ្យប្រពន្ធខ្ញុំមើលថែខ្ញុំ ដូច្នេះបើសិនជានាងនៅជាប្រពន្ធខ្ញុំ ហើយបំពេញកាតព្វកិច្ច និងទំនួលខុសត្រូវជាប្រពន្ធ ខ្ញុំមិនដាក់ពាក្យបណ្ដឹងទេ ។ បើសិនជានាងមិនរស់នៅជាមួយខ្ញុំទេ ខ្ញុំនឹងដាក់ពាក្យបណ្ដឹង ។"*[១៥៨] ឧទាហរណ៍មួយចេញពីនាង គ.សាល[១៥៩] ដែលបានសម្រេចចិត្តមិនដាក់ពាក្យបណ្ដឹងនៅពេលដែលនាងបានដឹងថា ប្រពន្ធដើមរបស់គូស្នេហ៍នាងជាអ្នកផ្ដើមគំនិតក្នុងការវាយប្រហារមកលើរូបនាង ហើយនាងគ.សាលមានការភ័យខ្លាចមិនហ៊ានដាក់ពាក្យបណ្ដឹងលើស្ត្រីជាប្រពន្ធដើមនោះដោយសារតែខ្លាចគូស្នេហ៍នាងចុះចោល ។

ការភ័យខ្លាចការសងសឹកក៏ជាមូលហេតុមួយនៃការមិនដាក់ពាក្យបណ្ដឹងដែរ ។ ជនល្មើសតែងតែគំរាមកំហែងជនរងគ្រោះ នៅក្រោយពេល និងមុនពេលដែលជនរងគ្រោះដាក់ពាក្យបណ្ដឹងជាមួយនគរបាល ។ មានឧទាហរណ៍មួយចំនួនដែលជនរងគ្រោះបានទទួលទូរស័ព្ទគំរាមកំហែងពីមនុស្សប្រុសមិនស្គាល់អត្តសញ្ញាណ ។ បើសិនជាអ្នករួចរស់ជីវិតមានការភ័យខ្លាចការសងសឹកពីសំណាក់ជនល្មើស និងក្រុមគ្រួសាររបស់ជនល្មើស ពួកគេនឹងមានភាពស្ទាក់ស្ទើរក្នុងការដាក់ពាក្យបណ្ដឹង ។

មានករណីខ្លះដែលអ្នករួចរស់ជីវិត សុខចិត្តមិនដាក់ពាក្យបណ្ដឹង និងស្វែងរកយុត្តិធម៌ដោយសារតែពួកគាត់គិតថាគាត់សាកសមនឹងទទួលរងនូវអ្វីដែលបានកើតឡើង ។ មានពេលខ្លះ ជនរងគ្រោះគិតថាពួកគាត់ត្រូវទទួលរងការវាយប្រហារដោយសារពួកគាត់បានប្រព្រឹត្ត អំពើខុសឆ្គងពីជាតិនេះ ឬជាតិមុន ។ ការយល់ឃើញបែបនេះ បាននាំឲ្យជនរងគ្រោះទទួលយកនូវអ្វីដែលបានកើតឡើងមកលើពួកគាត់ និងជំនឿថាគាត់មិនត្រូវការ ឬមិនសមទទួលបានដំណោះស្រាយតាមផ្លូវច្បាប់ ។ លោក វែលស៍[១៦០]

---

[១៥៦] បទសម្ភាសន៍ជាមួយជនរងគ្រោះជាបុរស៥នាក់ នៅ ខែកុម្ភៈ ឆ្នាំ២០១៣ ។

[១៥៧] បទសម្ភាសន៍ជាមួយជនរងគ្រោះ រប ដែលត្រូវបានគេវាយប្រហារនៅឆ្នាំ២០០៩ ។

[១៥៨] បទសម្ភាសន៍ជាមួយជនរងគ្រោះ កក ដែលត្រូវបានគេវាយប្រហារនៅឆ្នាំ២០០៩ ។

[១៥៩] សូមផ្ដើកំណត់ចំណាំថា ធស ដែលបាននិយាយពីខាងលើ និងនាង គសាល ជាជនរងគ្រោះពីរនាក់ផ្សេងគ្នា ។

[១៦០] Welsh, *មើលកំណត់ចំណាំលេខ ៥*, ទំព័រ ៦០ ។

បុនរាយការណ៍នូវគំនិតមួយស្រដៀងនឹងគំនិតខាងលើ ។[១៦១] នាង តាត ម៉ារីណា ជាអ្នករស់ជីវិតពីអំពើហិង្សាដោយអាស៊ីតល្បីឈ្មោះម្នាក់ ជាឧទាហរណ៍បាននិយាយថា *"ខ្ញុំមិនដឹងថាខ្ញុំបានធ្វើអ្វីខុះពីជាតិមុនទេ [ទើបខ្ញុំទទួលបានលទ្ធផលបែបនេះ] ប៉ុន្តែ ខ្ញុំគិតថាខ្ញុំបានប្រព្រឹត្តអំពើអាក្រក់ខ្លះ ។"*[១៦២] ដើម្បីកែប្រែឥរិយាបថនេះ ការយល់ឃើញរបស់អ្នករួចជីវិតខ្លួនឯងត្រូវតែផ្លាស់ប្តូរ ហើយអ្នករួចរស់ជីវិតត្រូវតែទទួលបានការជួយជ្រោមជ្រែង ។ អ្នករួចរស់ជីវិតគួរតែទទួលបានការជួយ ដើម្បីឲ្យពួកគាត់យល់ដឹងថាអំពើហិង្សាអាស៊ីត មិនមានអ្វីអាចយកមកដោះសាបានទេ បើទោះបីជាមានហេតុផលណាមួយមកសម្អាងក៏ដោយ ។

ករណីដែលជនរងគ្រោះសម្រេចចិត្តមិនដាក់ពាក្យបណ្តឹង តែងតែកើតមានឡើងជាធម្មតា ។ នៅឆ្នាំ២០១២ មានការវាយប្រហារចំនួនពីរករណីដែលជនរងគ្រោះសម្រេចចិត្តមិនដាក់ពាក្យបណ្តឹង និងមិនប្តឹងតាមផ្លូវច្បាប់ ហើយនៅក្នុងករណីវាយប្រហារដំបូងបង្អស់នៃឆ្នាំ២០១៣ អ្នករួចរស់ជីវិតបានចង្អុលបង្ហាញថា គាត់គ្មានបំណងដាក់ពាក្យបណ្តឹង និងបន្តធ្វើការប្តឹងតាមផ្លូវច្បាប់នោះទេ ។ នេះបានបង្កជាបញ្ហាមួយយ៉ាងលំបាកនៅពេលព្យាយាមបង្កើនចំនួនជម្រះក្តី និងការផ្តន្ទាទោស ។ បើសិនជាជនរងគ្រោះផ្ទាល់មិនធ្វើការដាក់ពាក្យបណ្តឹងជាផ្លូវការទេ តាមការអនុវត្ត នគរបាលនឹងមិនធ្វើការស៊ើបអង្កេតលើរឿងក្តីនោះឡើយ ហើយព្រះរាជអាជ្ញាដែលទទួលខុសត្រូវលើរឿងក្តីនេះ ក៏មិនបន្តនីតិវិធីបណ្តឹងទៀតដែរ[១៦៣] នេះមានន័យថា បើសិនជាគ្មានពាក្យបណ្តឹងនោះទេ ព្រះរាជអាជ្ញានឹងមិនបើកការស៊ើបអង្កេត និងមិនរាយការណ៍ទៅតុលាការមានសមត្ថកិច្ច ចៅក្រមស៊ើបសួរនឹងមិនត្រួតពិនិត្យលើសំណុំរឿង ចំណែកឯសវនាការក៏នឹងមិនត្រូវបានបើកនោះដែរ ។

---

[១៦១] *តាត ម៉ារីណា ជាអ្នកចំរៀងខារ៉ាអូខេដ៏ល្បីម្នាក់នៅភ្នំពេញ ហើយនាងត្រូវបានគេវាយប្រហារនៅឆ្នាំ១៩៩៩ ពេលដែលនាងមានអាយុ ១៦ឆ្នាំ ។ ការវាយប្រហារបានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងពីសាធារណជន ដោយសារតែនាងជាស្រីកំណាន់ចិត្តរបស់មន្ត្រីជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាលម្នាក់ ។ ការវាយប្រហារនោះត្រូវបានធ្វើឡើងក្រោមការបញ្ជារបស់ប្រពន្ធមន្ត្រីនោះ ។ នៅឆ្នាំ២០០៩ ឯកសារភាពយន្តស្តីពីនាង តាត ម៉ារីណា ដែលមានចំណងជើងថា "រកមុខ" ត្រូវបានចេញផ្សាយ ។ បច្ចុប្បន្ន នាង តាត ម៉ារីណា រស់នៅសហរដ្ឋអាមេរិក ។ ដោយសារតែនាង បានបង្ហាញខ្លួនជាសាធារណៈជាច្រើនសាទើបឈ្មោះនាងត្រូវបានសរសេរពេញ ដោយមិនមែនជាអក្សរកាត់ ។*

[១៦២] Welsh, *មើលកំណត់ចំណាំលេខ ៥*, *ទំព័រ ៦០ ។*

[១៦៣] Asia Regional Cooperation to Prevent People Trafficking, *មើលកំណត់ចំណាំលេខ ៩៦*, *ទំព័រ ៤៤ ។*

យោងតាម កូហាន អ្នករស់រានមានជីវិតពីការវាយប្រហារដោយទឹកអាស៊ីតជាច្រើននាក់ មិនបានស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់នោះទេ ប៉ុន្តែ ពួកគាត់ព្រមទទួលសំណងជាលុយ ។[១៦៤] បើទោះបីជាដំណោះស្រាយក្រៅប្រព័ន្ធតុលាការមានគុណប្រយោជន៍ ដោយសារតែដំណើរការនៃការដោះស្រាយលឿនជាងនៅតុលាការ ហើយជនរងគ្រោះបានទទួលប្រាក់ភ្លាមៗក៏ដោយ ក៏ដំណោះស្រាយប្រភេទនេះមិនបានធ្វើឲ្យជនល្មើសទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្តនោះឡើយ ។ នៅកម្ពុជា ពេលខ្លះ អ្នករួចរស់ជីវិតយល់ព្រមធ្វើការដោះស្រាយក្រៅតុលាការ ។[១៦៥] ប៉ុន្តែ ពុំមានទិន្នន័យ និងកំណត់ត្រាដែលអាចយកមកប្រើប្រាស់សម្រាប់ធ្វើអំណះអំណាង ថាតើការដោះស្រាយប្រភេទនេះត្រូវបានធ្វើឡើងញឹកញាប់ប៉ុណ្ណា ឬតម្លៃនៃការព្រមព្រៀងគ្នា ។ អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត ក្នុងករណីខ្លះ បានរកឃើញថា ជនរងគ្រោះបានទទួលសំណងសរុបតែម្តង ឯក្នុងករណីខ្លះទៀត ជនល្មើសយល់ព្រមសងជនរងគ្រោះតាមខែ ។

ម៉ុនតេសាណូ (Montesano) បានអះអាងថា ជាទូទៅ ប្រជាជនកម្ពុជាគិតថា វាជារឿងល្អជាងក្នុងការជៀសវាងការប្រឈមមុខគ្នា និងព្យាយាមស្វែងរកការព្រមព្រៀងគ្នា ជាពិសេស មិនស្វែងរកយុត្តិធម៌ ឬទាមទារសំណងជួសជុលក្រោយការវាយប្រហារ និងបំភ្លេចរឿងចាស់ដែលបានកន្លងហួស ។ ម៉ុនតេសាណូ ក៏បានបញ្ជាក់ដែរថា នៅក្នុងសង្គមខ្មែរ ការផ្សះផ្សា គឺជាបទដ្ឋានដែលជំរុញដោយវប្បធម៌ ។[១៦៦] បើទោះបីជាចំណុចនេះអាចពិតផ្នែកខ្លះដូចដែល បានបង្ហាញពីខាងលើក៏ដោយ មានចំណុចចង្អុលបង្ហាញខ្លះដែលថា ប្រហែលជាដោយប្រវត្តិសាស្ត្រដ៏ហិង្សារបស់ប្រទេសកម្ពុជា បុគ្គលខ្លះមានចរិតហិង្សា ។ ដូច្នេះហើយ ពួកគាត់មិនបានខិតខំស្វែងរកការផ្សះផ្សាទេ ប៉ុន្តែ បែរជាចូលរួមយ៉ាងសកម្មក្នុងការប្រឈមមុខគ្នាទៅវិញ ។

ថែមពីលើនេះទៅទៀត យោងតាមបទសម្ភាសន៍ជាមួយអ្នករួចរស់ជីវិត វាទំនងថា ភាគច្រើនចង់បានយុត្តិធម៌ ប៉ុន្តែ ពួកគាត់គិតថាមិនមានសមត្ថភាពក្នុងការទទួលបានយុត្តិធម៌ ។ ជាក់ស្តែង នៅក្នុងការស្ទង់មតិមួយ ដែលអង្គការជួយជនរងគ្រោះកម្ពុជាដោយទឹកអាស៊ីត បានធ្វើឡើងជាមួយអ្នករួចរស់ជីវិតពីការរលាកទឹកអាស៊ីតមួយក្រុមចំនួន៤០នាក់ ៨៥ភាគរយនៃជនរងគ្រោះដែលត្រូវបាន

---

១៦៤ Cohan, *មើលកំណត់ចំណាំលេខ ៥៩*, ទំព័រ ២១៨ ។

១៦៥ ពាក់ព័ន្ធនឹងករណីដែល CASC ដោះស្រាយ មានជនរងគ្រោះពីរនាក់បានយល់ព្រមទទួលយកការដោះស្រាយក្រៅតុលាការចាប់ពីចុងឆ្នាំ២០១២ ។

១៦៦ សូមមើល Montesano, *មើលកំណត់ចំណាំលេខ១៤៣*, ទំព័រ ៧៥ ។

សាកសួរ បានបង្ហាញថា ពួកគាត់នឹងស្វែងរកយុត្តិធម៌ ដោយការដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ បើសិនជាពួកគាត់អាចទទួលបានយុត្តិធម៌ប្រសើរជាងនេះ ។ ករណីនោះបានគាំទ្រដល់សេចក្តីសន្និដ្ឋានថា អ្នករួចរស់ជីវិតខ្លះមិនស្វែងរកដំណោះស្រាយផ្លូវច្បាប់ ដោយសារតែពួកគាត់គិតថាពួកគាត់មិនមានធនធានគ្រប់គ្រាន់សម្រាប់ធ្វើបែបនេះ ។[១៦៧] បើទោះបីជា“ផ្នត់គំនិតរួមជាលក្ខណៈវប្បធម៌” អាចពន្យល់ពីមូលហេតុដែលអ្នករួចរស់ជីវិតពីការរំលោភអាសិុត ខិតខំស្វែងរកការផ្សះផ្សាជាជាងសម្រេចចិត្តក្នុងការស្វែងរកយុត្តិធម៌ក៏ដោយ តាមគំនិតខ្ញុំករណីនេះមិនមែនសំដៅទៅលើជនរងគ្រោះភាគច្រើននោះទេ ។

### ៤.៤.២. កង្វះការជម្រះក្តី

នៅពេលអ្នករួចរស់ជីវិតដាក់ពាក្យបណ្តឹង ដែលនេះជាភាគច្រើននៃសំណុំរឿង នេះមិនមែនមានន័យថា ការស៊ើបអង្កេត ឬការជំនុំជម្រះក្តី នឹងត្រូវធ្វើឡើងដោយស្វ័យប្រវត្តិ ឬបញ្ចប់នោះឡើយ ។ មូលហេតុចម្បងទី២ អំពីមូលហេតុដែលបណ្តាលឲ្យអំពើហិង្សាដោយទឹកអាសិុត មិនត្រូវបានជំនុំជម្រះជានិច្ចកាលនោះ មានពាក់ព័ន្ធទៅនឹងកត្តាដែលមិនទាក់ទងទៅនឹងការសម្រេចចិត្ត ឬឆន្ទៈរបស់អ្នករួចរស់ជីវិត ។

ទីមួយ រឿងក្តីអាចត្រូវ“បញ្ឈប់” ។ ករណីបែបនេះ បានកើតឡើងជាញឹកញាប់នៅពេលដែលដំណើរការច្បាប់ស្រាប់តែត្រូវបានបញ្ឈប់ភ្លាមៗ ហើយរឿងក្តីត្រូវបានបញ្ចប់ដោយមិនដូវការ ។ នេះមានន័យថា តុលាការ ឬព្រះរាជអាជ្ញា មិនបានទាក់ទងអ្នករួចរស់ជីវិតទៀតនោះទេ ហើយរឿងក្តីក៏មិនត្រូវបានឈានដល់ដំណាក់កាលជំនុំជម្រះដែរ ។ ជាឧទាហរណ៍ នាង ក.ស ត្រូវបានទទួលរងការវាយប្រហារនៅដើមឆ្នាំ២០១០ និងបានជួបជាមួយចៅក្រមស៊ើបអង្កេតនៅចុងឆ្នាំ២០១០ ប៉ុន្តែមិនត្រូវបានជូនដំណឹងរហូតដល់ខែកក្កដា ២០១២ ទើបតុលាការបានផ្តល់ដំណឹងថា ការជំនុំជម្រះក្តីរបស់នាងនឹងត្រូវចាប់ផ្តើមនៅពេល“ឆាប់ៗ” ។ ប៉ុន្តែ ចាប់តាំងពីពេលនោះមក នាងមិនបានទទួលបានដំណឹងអ្វីពីតុលាការទៀតទេ ។ ឧទាហរណ៍មួយទៀត គឺករណីរបស់ ព.ណ ដែលត្រូវបានវាយប្រហារនៅខែមីនា ឆ្នាំ២០១០ ហើយជនរងគ្រោះរូបនោះបានដាក់ពាក្យបណ្តឹងភ្លាមៗតែម្តង ។បើទោះបីជាមានការខិតខំជាច្រើនលើកច្រើនសាដើម្បីធ្វើទំនាក់ទំនងទៅតុលាការ និងព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចក៏ដោយ ក៏ពុំទាន់មានការចាត់វិធានការ ឬការរីកចម្រើនណាមួយឲ្យបានជាក់លាក់ដែរ ហើយអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាសិុតសន្មតថា រឿងក្តីនោះមិនមានសកម្មភាព ។ ជនរងគ្រោះ ច.ប ត្រូវបានទទួលរងការវាយប្រហារនៅឆ្នាំ១៩៩៧ និងបានបញ្ជាក់ថា គាត់បានដាក់

---

[១៦៧] ការសម្ភាសន៍មតិផ្នែកច្បាប់របស់ CASC នៅខែតុលា ឆ្នាំ២០១១ ។

ពាក្យបណ្ដឹង ប៉ុន្តែ ទាំងនគរបាល និងព្រះរាជអាជ្ញា មិនបានចាប់ផ្ដើមធ្វើការស៊ើបអង្កេតលើរឿងក្ដីទើបគាត់ "*បំភ្លេចរឿងក្ដីនោះចោល*" ។[១៦៨] ការនៅសម្ងំស្ងៀមមិនដោះស្រាយរឿងក្ដីពីសំណាក់តុលាការ និងព្រះរាជអាជ្ញា នេះបានផ្ញើសារយ៉ាងធ្ងន់មួយថា អំពើហិង្សាដោយទឹកអាស៊ីតអាចធ្វើឡើងដោយមាននិទណ្ឌភាព ។

ជាញឹកញាប់ ជនដៃដល់មិនត្រូវបានចាប់ខ្លួន ព្រោះជនល្មើសបានរត់គេចខ្លួនក្រោយពេលដែលប្រព្រឹត្តបទល្មើស និងលាក់ខ្លួន ឬអត្តសញ្ញាណរបស់ជនល្មើសមិនត្រូវបានគេស្គាល់នោះឡើយ ។ ព្រះរាជអាជ្ញា និងចៅក្រមស៊ើប ជួនកាល បានសម្រេចចិត្តមិនបន្តការស៊ើបអង្កេត និងការជំនុំជម្រះបើសិនជាមិនមានជនល្មើស និងជនសង្ស័យទេនោះ ។ បញ្ហាប្រភេទនេះបានកើតឡើងយ៉ាងតិចពាករណីហើយក្នុងអំឡុងពេល២ឆ្នាំចុងក្រោយនេះ ។

កត្តាសំខាន់មួយទៀតគឺ ឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា ។ នៅកម្ពុជា ព្រះរាជអាជ្ញាមានសិទ្ធិសម្រេចអំពីបទល្មើស ឬខប្បត្តិហេតុណាមួយ ដើម្បីស៊ើបអង្កេត និងជំនុំជម្រះ ។[១៦៩] តាមច្បាប់ព្រះរាជអាជ្ញាមិនតម្រូវឲ្យធ្វើការជំនុំជម្រះលើគ្រប់បទល្មើសទេ ហើយដោយសារតែអំពើពុករលួយ ឬការយល់ឃើញថាបុគ្គលដែលត្រូវបានវាយប្រហារ "សមនឹងទទួលផល" បែបនេះ វាមិនមែនជារឿងចម្លែកនោះទេ ដែលព្រះរាជអាជ្ញាសម្រេចចិត្តមិនជម្រះរឿងក្ដីអំពើហិង្សាដោយទឹកអាស៊ីតដោយសម្អាងលើអំណះអំណាងក្រៅលក្ខណៈគតិយុត្តិ ។[១៧០]

មានករណីខ្លះ សាក្សីបដិសេធមិនផ្ដល់សក្ខីកម្មទៅឲ្យចៅក្រមស៊ើបអង្កេត ឬទៅអង្គជំនុំជម្រះ ។ នេះអាចនាំទៅដល់ការស៊ើបអង្កេតមិនមានលក្ខណៈពេញលេញ នាំឲ្យចៅក្រមស៊ើបអង្កេតសម្រេចចិត្តមិនបន្តនីតិវិធីជម្រះក្ដីដោយសារពុំមានភ័ស្តុតាងគ្រប់គ្រាន់ ឬនាំឲ្យមានការដោះលែងតែម្ដង ។ នៅពេលសាក្សីបដិសេធមិនចេញមុខបំភ្លឺ ឬមិនព្រមបង្ហាញមុខក្នុងតុលាការ ធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំងនៅពេលជម្រះក្ដី ។ ការជំនុំជម្រះក្ដីជាច្រើននៅកម្ពុជាពឹងផ្អែកលើសក្ខីកម្មសាក្សីស្ទើរតែទាំងស្រុងហើយសក្ខីកម្មអាចជាភ័ស្តុតាងតែមួយគត់ ។[១៧១] ដោយផ្អែក នេះគឺ ដូចដែលបានពិភាក្សាខាងលើ

---

[១៦៨] បទសម្ភាសន៍ជាមួយជនរងគ្រោះនៃការវាយប្រហារដោយទឹកអាស៊ីត លោក ចប ។

[១៦៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា *មើលកំណត់ចំណាំលេខ ៨៨*, មាត្រា ៤០-៤១ ។

[១៧០] បទសម្ភាសន៍ជាមួយលោក ហៀត សាមមេន ប្រធានគម្រោងនៅ CASC ។

[១៧១] បទសម្ភាសន៍ជាមួយកញ្ញា ឆម ផលនារី, អ្នកគ្រប់គ្រងអង្គភាពច្បាប់នៅ CASC; Asia Regional Cooperation to Prevent People Trafficking, *មើលកំណត់ចំណាំលេខ ៩៦*, ទំព័រ ៤៧ ។

ដោយសារតែជំនាញ និងនីតិវិធីស៊ើបអង្កេតនៅមានពុំទាន់ជឿនលឿនដូចនៅប្រទេសដទៃ ។ លើសពីនេះទៅទៀត នៅក្នុងករណីអំពើហិង្សាដោយទឹកអាស៊ីត សារធាតុវាយប្រហារជាក់ស្តែងបានបាត់បង់ក្រោយការវាយប្រហារ ហេតុដូច្នេះហើយទើបសក្ខីកម្មរបស់សាក្សី មានសារៈសំខាន់យ៉ាងខ្លាំង ។

មូលហេតុមួយដែលនាំឲ្យសាក្សី និងអ្នករួចរស់ជីវិត ស្ទាក់ស្ទើរក្នុងការចូលរួមសហការគឺ ដោយសារតែនៅកម្ពុជាពុំទាន់បានបង្កើតប្រព័ន្ធការពារសាក្សីនៅឡើយ ។[១៧២] ជាក់ស្តែង កាសែត និងប្រភពព័ត៌មានដទៃទៀត ត្រូវគេដឹងថាបានចុះផ្សាយឈ្មោះពេញរបស់អ្នករួចរស់ជីវិត និងសាក្សី (ព្រមជាមួយនឹងជនល្មើសផងដែរ) ដែលនាំឲ្យមានការងាយស្រួលក្នុងការកំណត់អត្តសញ្ញាណ ។ ការភ័យខ្លាចការសងសឹក ក៏ជាកត្តាមួយដែលនាំឲ្យមិនព្រមផ្តល់កសិណផងដែរ ។ សាក្សីធ្លាប់បដិសេធមិនផ្តល់កសិណដោយមិនត្រឹមតែលើកឡើងពីការភ័យខ្លាចការសងសឹកប៉ុណ្ណោះទេ ថែមទាំងអះអាងពីកង្វះជំនឿចិត្តនិងសេចក្តីទុកចិត្តលើប្រព័ន្ធច្បាប់ ឬដូចជាអ្នករួចរស់ជីវិតខ្លះ តម្រូវការរបស់ពួកគាត់ ដែលត្រូវធ្វើការនៅក្នុងហាងរបស់គាត់ ។[១៧៣] ការផ្លាស់ប្តូរឥរិយាបថរបស់សាក្សីត្រូវធ្វើឡើងដើម្បីដោះស្រាយការបាត់បង់ជំនឿ និងការស្ទាក់ស្ទើរក្នុងការលះបង់ពេលវេលាធ្វើការដើម្បីចូលរួមការជំនុំជម្រះក្តី និងផ្តល់កសិណ ។ បើសូម្បីតែអ្នកដែលជិតស្និទ្ធរបស់អ្នករួចរស់ជីវិតពីការរលាកអាស៊ីតមិនធ្វើការផ្តួចផ្តើមក្នុងការផ្តល់សក្ខីកម្មផង ការទទួលបានយុត្តិធម៌នឹងជាការលំបាកជាខ្លាំង ដោយសារអវត្តមានភស្តុតាងសំខាន់ ។ ភស្តុតាងដែលរួមមានទាំងសក្ខីកម្មផង គឺមានសារៈសំខាន់ណាស់ដើម្បីសម្រេចបានការផ្តន្ទាទោស បើទោះបីជារឿងក្តីកើតឡើងក្នុងប្រព័ន្ធច្បាប់ដែលមានដំណើរការពេញលេញក៏ដោយ ។

## ៤.៤.៣. កម្រិតជម្រះក្តីទាប

បើទោះបីជានៅក្នុងរឿងក្តីមួយចំនួន ដែលជនជាប់ចោទត្រូវបាននាំទៅជម្រះក្តី លទ្ធផលគឺនៅតែជារឿងខកចិត្ត នៅពេលដែលជនដៃដល់ត្រូវបានឃើញថាមានទោស ប៉ុន្តែ បែរជាទទួលទោសស្រាលទៅវិញ ។ ការដែលបានរកឃើញថាបុគ្គលម្នាក់មានទោសដោយការប្រព្រឹត្ត អំពើហិង្សាដោយទឹកអាស៊ីតស្តែងឲ្យឃើញជាវិជ្ជមានអំពីការកើនឡើងនូវការមិនទទួលស្គាល់អំពើហិង្សាដោយទឹកអាស៊ីត ។ ផ្ទុយទៅវិញ ប្រសិនបើទោសមិនមានសមាមាត្រគ្នាទៅនឹងបទល្មើស និងផលវិបាកដែលជនរងគ្រោះត្រូវ

---

[១៧២] Asia Regional Cooperation to Prevent People Trafficking, *មើលកំណត់ចំណាំលេខ ៩៦, ទំព័រ ៤៦ ។*

[១៧៣] *ឧទាហរណ៍មុននេះបានកើតឡើងក្នុងករណីរបស់ជនរងគ្រោះ គ.ស ។ ក្រុមគ្រួសាររបស់នាងដែលបានឃើញការវាយប្រហារទាំងពីរលើកដោយផ្ទាល់ពុំបានបង្ហាញខ្លួនដើម្បីធ្វើបទសម្ភាសន៍ជាមួយចៅក្រមស៊ើបអង្កេតនៅខេត្តកំពតនោះទេ ដោយផ្អែកលើមូលហេតុថាពួកគាត់ត្រូវធ្វើការនៅហាងរបស់ខ្លួន ។ ចុងក្រោយ ទើបចៅក្រមចេញដីការកោះហៅសាក្សីបង្ហាញមុខ ហើយបុគ្គលិក* CASC *បាននាំសាក្សីមកតុលាការដោយផ្ទាល់ ។*

ទទួលរងអស់មួយជីវិត ការបោះដំហ៊ានទៅមុខដែលវិជ្ជមាននឹងត្រូវបានក្លាយជាអសារបង់ ។ លោក ហ្គោឡុកលី បានរាយការណ៍ថា ទោសសម្រាប់អំពើហិង្សាដោយទឹកអាស៊ីត ហាក់បីដូចជាមានរយៈពេលខ្លី ដោយជនល្មើសត្រូវបានកាត់ឲ្យជាប់ទោសត្រឹមពីរ ឬបីខែសម្រាប់ការវាយប្រហារមួយទៅត្រឹមពីរ ឬក៏បីឆ្នាំប៉ុណ្ណោះ ក្នុងករណីដែលជនរងគ្រោះស្លាប់ ។[១៧៤]

ឧទាហរណ៍ដែលគួរឲ្យកត់សម្គាល់នោះគឺករណីរបស់នាង ច.ត ដែលត្រូវបានវាយទទួលរងការវាយប្រហារដោយស្ត្រីម្នាក់នៅឆ្នាំ២០១០ ។ ទាំងនាង ច.ត និងកូនពីរនាក់ទៀតរបស់គាត់ (កុមារ ព.ស.រ ដែលមានអាយុទើបតែមួយខួបនៅពេលនោះ និងកុមារ ព.ម ដែលមានអាយុ៦ឆ្នាំនៅពេលនោះ) ទទួលរងរបួសពីការវាយប្រហារ ។ គួរឲ្យលើកទឹកចិត្ត ជនល្មើសត្រូវបានចាប់ខ្លួនភ្លាមៗ ហើយការជម្រះក្តីក៏ត្រូវបានធ្វើឡើងដែរ ប៉ុន្តែ លទ្ធផលដែលទទួលបានពុំសូវជាវិជ្ជមានប៉ុន្មានឡើយ ។ ចៅក្រមសម្រេចចេញសាលក្រម ព្យួរទោសដាក់ពន្ធនាគាររយៈពេល២ឆ្នាំ និង ព្យួរទោសដោយមានលក្ខខណ្ឌក្នុងរយៈពេល៣ឆ្នាំ ។ មូលហេតុពីក្រោយសេចក្តីសម្រេចនេះ គឺដោយសារតែស្ត្រីដែលជាជនល្មើសមានទារកក្នុងបន្ទុកត្រូវមើលថែទាំ ។[១៧៥] បើទោះបីវាជារឿងគួរឲ្យសរសើរដែលចៅក្រមបានពិចារណាពីស្ថានភាពផ្ទាល់ខ្លួនរបស់ជនល្មើសក៏ដោយ ក៏ការយល់ឃើញនេះបានស្តែងឲ្យឃើញពីកង្វះការយល់ដឹងពីភាពធ្ងន់ធ្ងរនៃបទល្មើស និងផលវិបាកដែលនាង ច.ត និងកូនពីរនាក់របស់នាងបានទទួលរង ។ ជនល្មើសត្រូវបានអនុញ្ញាតឲ្យដើរហើរដោយសេរី ដោយចៅក្រមមិនបានយល់ដឹងអំពីការរងទុក្ខ និងរបួសផ្លូវចិត្តដែលជនរងគ្រោះបានទទួលរងពីអំពើហិង្សាទឹកអាស៊ីត ។

ឧទាហរណ៍មួយទៀតចេញពីអ្នករស់រានជីវិតភេទប្រុសម្នាក់ ដែលបានឆ្លុះបញ្ចាំងទាំងវិសមាមាត្រនៃទោសស្រាល និងឥទ្ធិពលនៃអំពើពុករលួយរបស់មន្ត្រីតុលាការ ។ នៅឆ្នាំ២០០៥ លោក ដ.អ ត្រូវបានវាយប្រហារដោយប្រពន្ធទីមួយរបស់គាត់ដោយសារការប្រច័ណ្ឌ ។[១៧៦] គាត់បានបញ្ជាក់ថា គាត់បានដាក់ពាក្យបណ្តឹង ហើយប្រពន្ធគាត់ត្រូវបានចាប់ខ្លួន និងកាត់ទោសដាក់ពន្ធនាគារ ។ នេះហាក់បីដូចជាបានទទួលជោគជ័យហើយ ប៉ុន្តែ តុលាការខេត្តកំពង់ចាមបានបង្គាប់ឲ្យគាត់បង់ "ថ្លៃ" ចំនួន

[១៧៤] Gollogly et al., *មើលកំណត់ចំណាំលេខ៦៣, ទំព័រ ៣៣៣ ។*

[១៧៥] *តុលាការខេត្តកំពង់ចាម, ០៦,០៨,២០១១ ។*

[១៧៦] *ដ.អ និងប្រពន្ធដើមដែលជាជនល្មើសនៃការវាយប្រហារដោយទឹកអាស៊ីត បានលែងលះគ្នាក្រោយពីការវាយប្រហារ ។*

៣០,០០០រៀល(៧,៥ដុល្លារ)[១៧៧] ប៉ុន្តែ គាត់អាចបង់ប្រាក់ត្រឹមតែ៥០០០រៀល (១,២៥ដុល្លារ) ប៉ុណ្ណោះ ។ ក្រោយពីបង់ប្រាក់រួច ប្រពន្ធរបស់គាត់ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន៧ខែ ខណៈពេលដែល ដ.អ នៅសម្រាកព្យាបាលស្នាមរលាកធ្ងន់ធ្ងរនៅមន្ទីរពេទ្យនៅឡើយ ។ លោក ដ.អ គិតថា បើសិនជាគាត់អាចចំណាយប្រាក់ច្រើនជាងនេះ ប្រពន្ធមុនរបស់គាត់អាចទទួលទោសធ្ងន់ជាងនេះ ។[១៧៨] ការដែលតុលាការបង្គាប់ឲ្យលោក ដ.អ បង់ប្រាក់របៀបនេះគឺ ផ្ទុយទៅនឹងបទបញ្ញត្តិពាក់ព័ន្ធនឹងប្រាក់ប្រដាប់ក្តី ។ យោងតាមមាត្រា៣ នៃច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ប្រាក់ប្រដាប់ក្តីតម្រូវឲ្យបង់តែនៅក្នុងរឿងក្តីរដ្ឋប្បវេណី ពាណិជ្ជកម្ម ការងារ ឬជម្លោះរដ្ឋបាលតែប៉ុណ្ណោះ ។[១៧៩] ករណី លោក ដ.អ ជាករណីព្រហ្មទណ្ឌ ។ លើសពីនេះទៀត ប្រពន្ធគាត់ត្រូវបានរកឃើញថាមានទោស ដោយតាមច្បាប់ស្ត្រីជាប្រពន្ធត្រូវចេញប្រាក់ប្រដាក់ក្តី ។[១៨០] មាត្រា ២០ ក៏បានចែងដែរថា បើសិនជាបុគ្គលម្នាក់គ្មានធនធានគ្រប់គ្រាន់ដើម្បីបង់ប្រាក់ប្រដាប់ក្តីនោះទេ នោះតុលាការនឹងធ្វើការលើកលែងចំពោះការបង់ប្រាក់នេះ ។[១៨១] នៅក្នុងករណីណាក៏ដោយ បើទោះបីជាការស្នើសុំរបស់តុលាការពាក់ព័ន្ធនឹងការបង់ប្រាក់នេះមានមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ក៏ដោយ ក៏អសមត្ថភាពក្នុងការបង់ប្រាក់របស់ជនរងគ្រោះ មិនអាចយកមកប្រើប្រាស់ជាយុត្តិកម្ម សម្រាប់សម្អាងឲ្យការកាត់ទោសឲ្យជនល្មើសជាប់ទោសក្នុងរយៈពេលខ្លីនោះឡើយ ។ រឿងក្តីរបស់ជនរងគ្រោះ ដ.អ ជារឿងក្តីសំខាន់មួយ ដោយសារតែរឿងក្តីនេះ មិនត្រឹមតែឆ្លុះបញ្ចាំងពីការព្យាយាមរកប្រាក់ចំណូលបន្ថែមរបស់តុលាការនិងចៅក្រមដោយការបង្ខំឲ្យជនរងគ្រោះដោយទឹកអាស៊ីតបង់ប្រាក់ប៉ុណ្ណោះទេ រឿងក្តីលោក ដ.អ ថែមទាំងបានបង្ហាញថា តុលាការមិនបានការពារជនដែលខ្លួនមានកាតព្វកិច្ចត្រូវការពារ ប៉ុន្តែ ថែមទាំងបានស្តែងឲ្យឃើញនូវរបៀបដែលការដាក់ទោសធូរនេះ ចង្អុលបង្ហាញអំពីកង្វះការយល់ដឹងពីផលវិបាក និងការផលប៉ះពាល់នៃអំពើហិង្សាដោយទឹកអាស៊ីត ។

---

[១៧៧] ៤០០០ រៀលស្មើនឹងមួយដុល្លារ ។

[១៧៨] បទសម្ភាសន៍ជាមួយអ្នករស់រានមានជីវិត ដ.អ ។

[១៧៩] ក្រមនីតិវិធីព្រហ្មទណ្ឌ, *មើលកំណត់ចំណាំលេខ៨៨*,មាត្រា ៥៥៣; នៃក្រមស្តីពីប្រាក់ប្រដាប់ក្តី, មាត្រា ៣ (ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣) ។

[១៨០] ក្រមស្តីពីប្រាក់ប្រដាប់ក្តី, *មើលកំណត់ចំណាំលេខ ១៧៩*។

[១៨១] ដូចខាងលើ, មាត្រា ២០ ។

នៅពេលដែលអ្នកអាចធ្វើការវាយប្រហារបានពុថា ជនដៃដល់ទទួលបានការផ្តន្ទាទោសស្រាលចំពោះអំពើហិង្សាដោយទឹកអាស៊ីត គំនិតនេះអាចដើរតួរជាការជំរុញឲ្យប្រព្រឹត្តបទល្មើស ។ ស្ត្រីមួយចំនួនដែលវាយប្រហារប្តី បានប្រាប់ក្នុងបទសម្ភាសន៍ថា ពួកគាត់នឹងមិនធ្វើការវាយប្រហារឡើយបើសិនជាពួកគាត់ដឹងពីផលវិបាកដែលបន្សល់លើរូបរាងកាយ ក្រោយពីបានជះទឹកអាស៊ីត ។[១៨២] ជនល្មើសខ្លះទៀតអាចនឹងមិនប្រព្រឹត្តបទល្មើសនេះ បើសិនជាពួកគេបានដឹងថាពួកគេនឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារក្នុងរយៈពេលវែងព្រមទាំងត្រូវបង់ប្រាក់សំណងច្រើន ។

នៅក្នុងការស្ទង់មតិដោយ អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត ជាមួយអ្នករួចរស់ជីវិត អ្នកឆ្លើយតបចំនួន៧០ភាគរយ (២៨នាក់/៤០នាក់) បានប្រាប់ថា ជនល្មើសដែលនៅពីក្រោយខ្នងនៃការវាយប្រហារ ពុំត្រូវបានគេដាក់ទណ្ឌកម្មក្នុងទម្រង់ណាមួយទេ ។[១៨៣] ការស្ទង់មតិនេះក៏បានសួរពីការយល់ឃើញរបស់អ្នករួចរស់ជីវិតអំពីទណ្ឌកម្មដែលជនដៃដល់បានទទួលដែរ ។ ៧២.៥ភាគរយ (២៩នាក់/៤០នាក់) បានឆ្លើយថា ពួកគាត់គិតថា ការដាក់ទណ្ឌកម្មទៅលើជនល្មើសមានលក្ខណៈធូរស្រាលពេក ឬមិនយុត្តិធម៌ ។ អ្នករួចរស់ជីវិតតែ ២០ភាគរយ(៨/៤០)ប៉ុណ្ណោះ ដែលយល់ថាការដាក់ទណ្ឌកម្មទៅលើជនល្មើសមានលក្ខណៈត្រឹមត្រូវ ។ ក្នុងចំណោមអ្នកដែលបានសម្ភាសទាំងអស់ ពុំមានណាម្នាក់ដែលយល់ថា ការដាក់ទណ្ឌកម្មទៅលើជនដៃដល់មានលក្ខណៈធ្ងន់ធ្ងរពេកទេ ។[១៨៤] យោងតាមចម្លើយដែលទទួលបាន យើងអាចធ្វើការសន្និដ្ឋានថា ជនរងគ្រោះយល់ឃើញថា ការដាក់ទណ្ឌកម្មមិនទាន់ធ្ងន់ធ្ងរគ្រប់គ្រាន់ ដោយសារតែមិនមានទណ្ឌកម្មតែម្តង ឬព្រោះតែទណ្ឌកម្មមិនសមស្របទៅនឹងទម្ងន់នៃបទល្មើសនោះ ។[១៨៥]

នៅពេលសួរថាតើអាចទទួលយកបានទេ ចំពោះទោសជាប់ពន្ធនាគារពី២ ទៅ៥ឆ្នាំ សម្រាប់ជនដៃដល់ដែលមានចេតនាបង្កព្យសនកម្ម ដូចដែលមានចែងនៅក្នុងមាត្រា២០ វាក្យខណ្ឌ១នៃច្បាប់ស្តីពីអាស៊ីត អ្នកឆ្លើយតបទាំងអស់បានឆ្លើយថាមិនអាចទទួលយកបានទេ ។ ពួកគាត់គិតថា ការផ្តន្ទាទោសរបៀបនេះមិនបានបញ្ជាំងអំពីសារជាតិនៃបទល្មើស និងថា គួរតែមានការផ្តន្ទាទោសធ្ងន់ជាងនេះ ។

---

[១៨២] បទសម្ភាសន៍ជាមួយជនល្មើសនៃអំពើហិង្សាដោយទឹកអាស៊ីត៣នាក់ដែលជាស្ត្រី, ខែមីនា ឆ្នាំ២០១៣ ។

[១៨៣] ជនរងគ្រោះម្នាក់ដែលបានសម្ភាសធ្លាប់ជាអ្នកវាយប្រហារដែរ មិនព្រមផ្តល់ចម្លើយ ។

[១៨៤] អ្នកផ្តល់បទសម្ភាសន៍ចំនួន៣នាក់បដិសេធមិនផ្តល់ចម្លើយលើសំណួរនេះ ។

[១៨៥] អ្នកឆ្លើយតបចំនួន ៤៥ភាគរយ បានបង្ហាញថាជនល្មើសមិនត្រូវបានដាក់ទណ្ឌកម្ម ឬបានរត់គេចខ្លួន ។ អ្នកឆ្លើយតបចំនួន ២២.៥ភាគរយ បានបង្ហាញថាការដាក់ទណ្ឌកម្មមិនបានឆ្លុះបញ្ជាំងពីទម្ងន់ទោសនោះទេ ។

នៅពេលសួរថាតើការដាក់ទោសឲ្យជាប់ពន្ធនាគារពី ៥ ទៅ ១០ឆ្នាំ គឺជាទោសសមរម្យឬទេ នៅក្រោមច្បាប់ស្តីពីអាស៊ីតចំពោះការវាយប្រហារដែលបណ្តាលឲ្យពិការអស់មួយជីវិត អ្នកផ្តល់ចម្លើយទាំងអស់បានឆ្លើយថា មិនសមរម្យទេ ។ ភាគច្រើននៃជនរងគ្រោះ (៧២,៥ភាគរយ) បានចង្អុលបង្ហាញថា ការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត គឺជាទោសសមរម្យ ហើយអ្នកឆ្លើយតបខ្លះ បានលើកឡើងថា ការផ្តន្ទាទោសប្រហារជីវិត ឬក៏អនុញ្ញាតឲ្យជនរងគ្រោះជះទឹកអាស៊ីតទៅលើជនល្មើសវិញ អាចជាការដាក់ទណ្ឌកម្មសមស្របដែរ ។

ពាក់ព័ន្ធទៅនឹងសំណងក្រោយពីអំពើហិង្សាដោយទឹកអាស៊ីត ស្ទើរតែគ្រប់អ្នកឆ្លើយតបទាំងអស់នៅក្នុងការស្ទង់មតិខាងលើយល់ឃើញថា ជនរងគ្រោះគួរតែបានទទួលសំណង ។[១៨៦] ភាគរយខ្ពស់បំផុត ៤៤,៧៤ភាគរយ គិតថា ទឹកប្រាក់ចន្លោះពី ១០០០ ទៅ ៥០០០ដុល្លា គឺសមរម្យ ហើយ ២៨,៩៥ភាគរយ យល់ថា ប្រាក់សំណងចន្លោះពី ៥០០០ ទៅ១០០០០ដុល្លា គឺសមហេតុសមផល ។

### ៤.៤.៤. កង្វះការអនុវត្ត

បើទោះបីជាតុលាការបានកាត់ឲ្យជនល្មើសនៃអំពើហិង្សាដោយទឹកអាស៊ីតជាប់ពន្ធនាគារ និង ឬ ពិន័យជាប្រាក់ក៏ដោយ ក៏ជាទូទៅសេចក្តីប្រកាសទោសទាំងនេះមិនត្រូវបានអនុវត្តទេ ។ យោងតាមច្បាប់ ព្រះរាជអាជ្ញាជាអ្នកមានភារកិច្ចរ៉ាប់រងលើការអនុវត្តសេចក្តីប្រកាសទោស ។ ប៉ុន្តែ មានបញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធនឹងការអនុវត្តនូវសេចក្តីប្រកាសទោសនៅកម្ពុជា ។[១៨៧] ការមិនអនុវត្តសេចក្តីប្រកាសទោស បានចោទជាបញ្ហាដោយធ្វើឲ្យជនរងគ្រោះទទួលស្គាល់ជាផ្លូវការថា បទល្មើសត្រូវបានប្រព្រឹត្តមកលើគាត់ ប៉ុន្តែ មិនបានទទួល"ប្រយោជន៍"អ្វីមកវិញសោះ ។ ករណីនេះ អាចនឹងកើតឡើងទាំងពីរ បើសិនជាជនល្មើសមិនជាប់ពន្ធនាគារ និងនៅពេលសំណង (ប្រសិនបើតុលាការសម្រេច) មិនត្រូវបានសង ។

ទោសជាប់ពន្ធនាគារ ជាទូទៅ មិនត្រូវបានអនុវត្តទេ ដោយសារជនដៃដល់ជាច្រើនបានរត់គេចខ្លួន បន្ទាប់បានប្រព្រឹត្តទង្វើនោះ ។ បើសិនជាតុលាការមិនអាចរកឃើញ និង ចាប់ជនល្មើសបាន តុលាការនឹងកាត់ក្តីកំបាំងមុខ ។ ប្រសិនបើជនដៃដល់មិនទាន់អាចចាប់ខ្លួនបាន សាលក្រមនឹងមិនអាច

---

[១៨៦] អ្នកផ្តល់ចម្លើយចំនួន៣៨នាក់បានឆ្លើយយ៉ាងវិជ្ជមាន ។ អ្នកផ្តល់ចម្លើយម្នាក់ជាជនល្មើស ហើយបានបដិសេធមិនព្រមផ្តល់ចម្លើយ ។ ជនរងគ្រោះម្នាក់បានប្រាប់ថាគាត់មិនចង់បានលុយនោះទេ ប៉ុន្តែគាត់ចង់ឲ្យជនល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។ ការស្ទង់មតិរបស់ CASC (ខែតុលា ឆ្នាំ២០១១) ។

[១៨៧] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, *មើលកំណត់ចំណាំលេខ ៨៨*, មាត្រា ៤៩៦ ។

អនុវត្តបានទេ។ ជាលទ្ធផល ទោសជាប់ពន្ធនាគារមិនអាចយកមកអនុវត្តបានទេ ហើយគ្មានសំណង ជំងឺចិត្តដល់អ្នករួចរស់ជីវិតទេ។

នៅក្នុងចំណោមការវាយប្រហារចំនួន៣ករណី អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីត បានបញ្ជាក់ថា ជនដៃដល់ត្រូវបានរកឃើញថាមានទោសកំបាំងមុខ ប៉ុន្តែ ទោសពន្ធនាគារមិនត្រូវបាន អនុវត្តទេ ដោយសារទីកន្លែងរបស់ជនល្មើសមិនដឹងនៅទីណា។ ទិន្នន័យរបស់ អង្គការជួយជនរងគ្រោះ កម្ពុជាដោយសារអាស៊ីត បង្ហាញថា នៅចំណោមករណីចំនួន៨ដែលអង្គការនេះពាក់ព័ន្ធផ្នែកខ្លះ ហើយ សំណងជំងឺចិត្តត្រូវផ្តល់ឲ្យដោយតុលាការ មានតែមួយករណីប៉ុណ្ណោះ ដែលជនរងគ្រោះបានទទួល សំណងពីជនល្មើស ហើយទទួលបានតែបន្ទាប់ពីមានអន្តរាគមន៍ពីមន្ត្រីជាន់ខ្ពស់ប៉ុណ្ណោះ។ នេះជា ការរកឃើញមួយដ៏គួរឲ្យខកចិត្តជាខ្លាំង ដោយសារទោសត្រូវបានអនុវត្តឡើង លុះត្រាណាតែមាន អន្តរាគមន៍ពីមន្ត្រីជាន់ខ្ពស់នៅខាងជនរងគ្រោះ។ អ្នករួចរស់ជីវិត ម.ច ត្រូវគេវាយប្រហារ នៅឆ្នាំ១៩៩៥ ហើយសាលក្រមត្រូវបានប្រកាសនៅឆ្នាំ១៩៩៦។ ប៉ុន្តែ រហូតទាល់តែដល់ ឆ្នាំ២០១០ ទើបនាងបានទទួលប្រាក់សំណងចំនួន១៥០០ដុល្លាដែលតុលាការបានសម្រេច។ ការនេះ បានកើតឡើង តែបន្ទាប់ពីមានអន្តរាគមន៍ពីអគ្គព្រះរាជអាជ្ញានៅឆ្នាំ២០០៨ បន្ទាប់ពីពាក្យបណ្តឹងមួយ ទៅរដ្ឋសភានៅខែមករា ឆ្នាំ២០១០ និង ចុងបញ្ចប់ បន្ទាប់ពី លិខិតរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៅ ខែកុម្ភៈ ឆ្នាំ២០១០ ទៅកាន់តុលាការខេត្តកណ្តាល។ នាង ម.ច សំណាងណាស់ដែលខ្សែមាន អំណាចបែបនេះ។ ចំណែកអ្នករួចរស់ជីវិតដែលគ្មានទំនាក់ទំនងវិញ ទំនងជាមិនទទួលបានអ្វីទាំងអស់។

គួរឲ្យកត់សម្គាល់ថា នៅក្នុងករណីជាច្រើន ជនដៃដល់មានជីវភាពក្រីក្រ និងមិនមានសមត្ថភាព ចេញសំណងផ្នែកខ្លះ ឬសំណងទាំងមូលដែលបានផ្តល់ឲ្យដោយតុលាការឡើយ។ ប៉ុន្តែ ទោសជាប់ ពន្ធនាគារជំនួសឲ្យការមិនព្រមសងសំណង គឺអាចធ្វើទៅរួច ដោយពុំចាំបាច់មានដីកាពិសេសពីតុលាការ ឡើយ។[១៨៨]

## ៤.៥. ឥទ្ធិពលនៃច្បាប់ស្តីពីអាស៊ីតលើអ្នករួចរស់ជីវិត

ច្បាប់ស្តីពីអាស៊ីត និងអនុក្រឹត្យស្តីពីអាស៊ីតត្រូវបានអនុម័តឡើងក្នុងគោលបំណងបំពេញចន្លោះ ប្រហោងច្បាប់កម្ពុជា តាមរយៈការកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះ ជាពិសេស ការវាយប្រហារ ដោយទឹកអាស៊ីត និងដើម្បីរៀបចំគ្រប់គ្រងលើការលក់ ស្តុក និងទិញដូរអាស៊ីតខ្លាំងដោយសារថា ការងាយរកទឹកអាស៊ីតអាចជាកត្តានាំឲ្យមានទាំងការវាយប្រហារ និង ឧបទ្ទវហេតុដែលបង្កដោយទឹក

---

[១៨៨] ដូចខាងលើ។ មាត្រា ៥២៣-៥២៤។

អាស៊ីត ។ អង្គការក្រៅរដ្ឋាភិបាល បានខិតខំជំរុញឲ្យមានការបង្កើតច្បាប់ស្តីពីអាស៊ីតក្នុងគោលបំណង ជំរុញឲ្យមានការទទួលស្គាល់ចំពោះបញ្ហាដែលបង្កឡើងពីអំពើហិង្សាដោយទឹកអាស៊ីតនៅកម្ពុជា និង ដើម្បីជ្រោមជ្រែងជនរងគ្រោះក្នុងការស្វែងរកយុត្តិធម៌ដែលពួកគាត់គួរតែទទួលបាន ព្រមជាមួយនឹង ដើម្បីបញ្ចប់និទណ្ឌភាពដែលមានជាយូរមកហើយរបស់ជនដៃដល់ ។ គេសង្ឃឹមថា ការអនុវត្តច្បាប់ ទាំងនេះ នឹងអាចកាត់បន្ថយអំពើហិង្សាដោយទឹកអាស៊ីត ដោយសារតែការអនុវត្តបញ្ញត្តិច្បាប់ អាចធ្វើ ឲ្យមនុស្សមានភាពញញើត ។

វាទំនងថា រឿងនេះបានកើតមានឡើងនៅប្រទេសបង់ក្លាដេស ដែលកាលពីឆ្នាំ២០០២ ច្បាប់គ្រប់គ្រងអាស៊ីតរបស់ បានចូលជាធរមាន ។ បង់ក្លាដេសជាប្រទេសទីមួយដែលមានច្បាប់ដើម្បី ការពារ និងដាក់ទណ្ឌកម្មលើអំពើហិង្សាដោយទឹកអាស៊ីត ។[១៨៩] បន្ទាប់ពីអនុម័តច្បាប់ដើម្បីដាក់ទណ្ឌកម្ម លើអំពើហិង្សាដោយទឹកអាស៊ីត យើងបានសង្កេតឃើញថាការវាយប្រហារដោយទឹកអាស៊ីត មានការ ធ្លាក់ចុះជាខ្លាំង ពោលគឺពី ៥០០ ទៅ ៦០ករណីក្នុងមួយឆ្នាំ ។[១៩០] បទពិសោធន៍ពីប្រទេសបង់ក្លាដេស បង្ហាញថា ជំហានដំបូងក្នុងការប្រឆាំងនឹងអំពើហិង្សា គឺត្រូវមានច្បាប់ដោះស្រាយបញ្ហាអំពើហិង្សា ដោយអាស៊ីត ។ ស្រដៀងគ្នាដែរ បើទោះបីជានៅក្នុងសតវត្សរ៍ទី១៨ មានរបាយការណ៍ជាច្រើន អំពីអំពើហិង្សាទឹកអាស៊ីតនៅតំបន់អាមេរិកខាងជើង និងប៉េកអឺរ៉ុប អំពើហិង្សាប្រភេទនេះក៏បាត់ ទៅវិញយ៉ាងឆាប់រហ័ស បន្ទាប់ពីមានច្បាប់ ដាក់ឲ្យអនុវត្ត និងប្រតិបត្តិ ។[១៩១]

ចំណែកឯនៅប្រទេសប៉ាគីស្ថាន មានការរីកចម្រើនយ៉ាងវិជ្ជមានមួយបានស្តែងឡើងតាមរយៈ ការដាក់អនុម័តច្បាប់ដើម្បីដាក់ទណ្ឌកម្មលើអំពើហិង្សាដោយទឹកអាស៊ីតនៅឆ្នាំ២០១០ ។ បន្ទាប់ពីនោះ ចំនួនឧប្បត្តិហេតុដែលបានរាយការណ៍ក៏មានការកើនឡើងរហូតទៅដល់បីដង ។ ចំនួននៃការផ្តន្ទាទោស ក៏មានការកើនឡើងដែរ ពី ៧ភាគរយ នៅឆ្នាំ២០០៧ ទៅ ១៨ភាគរយ នៅឆ្នាំ២០១១ ។ លោក ហ្សេកខល (Shackle) បានបន្ថែមថា តួលេខនេះនៅទាបនៅឡើយ ដែលបណ្តាលមកពីការអនុវត្ត ច្បាប់ទន់ខ្សោយ អភិបាលកិច្ចជាទូទៅទន់ខ្សោយ ការពុំទទួលបានយុត្តិធម៌ និងអាកប្បកិរិយាមិនរាក់ទាក់ របស់មន្ត្រីនគរបាល និង ចៅក្រមចំពោះស្ត្រី ។[១៩២]

---

[១៨៩] Chatterjee, *មើលកំណត់ចំណាំលេខ ១៩, ទំព័រ ៧ ។*

[១៩០] Shackle, *មើលកំណត់ចំណាំលេខ ៥១ ។*

[១៩១] Welsh, *មើលកំណត់ចំណាំលេខ ៥, ទំព័រ ៣៩ ។*

[១៩២] *ដូចខាងលើ ។*

បទពិសោធន៍នៃប្រទេសប៉ាគីស្ថាន អាចជាមេរៀនសម្រាប់កម្ពុជា ។ បើទោះបីជាកម្ពុជាមានច្បាប់ហើយក៏ដោយ ក៏កម្ពុជាត្រូវចាត់វិធានការផ្សេងឲ្យហួសពីច្បាប់តែមួយមុខ ប្រយុទ្ធនឹងអំពើហិង្សាដោយអាស៊ីត និងដើម្បីធានាថាអ្នករួចរស់ជីវិតពីការរលាកអាស៊ីតទទួលបានយុត្តិធម៌ និងបញ្ចប់និទណ្ឌភាពនៃបទល្មើស ។ ចាប់តាំងពីច្បាប់ស្តីពីអាស៊ីត បានចូលជាធរមាននៅដើមឆ្នាំ២០១២មក ការវាយប្រហារដោយចេតនាចំនួន៩ករណី បានបង្កឲ្យមានអ្នកនៅរស់ជីវិតចំនួន៨នាក់រងរបួស និងចំនួន៣នាក់បាត់បង់ជីវិត ។[១៩៣] ក្នុងចំណោមការវាយប្រហារទាំងអស់ មានតែការវាយប្រហាររបស់ ប.ស ទៅលើ ណ.ស ប៉ុណ្ណោះ ដែលឈានដល់ការជំនុំជម្រះ ព្រមទាំងទទួលបានសេចក្តីសម្រេចក្រោមច្បាប់ស្តីពីអាស៊ីតពីតុលាការ ។ អ្វីដែលត្រូវការនៅពេលនេះ គឺការអនុវត្តច្បាប់ និង ការគ្រប់គ្រងដែលមានប្រសិទ្ធិភាព ដែលជាកិច្ចការសម្រាប់ប្រព័ន្ធតុលាការកម្ពុជាក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ។

ទោះយ៉ាងណាក៏ដោយ មានករណីអំពើហិង្សាដោយទឹកអាស៊ីតមួយទៀតដែលបានប្រើប្រាស់ច្បាប់ស្តីពីអាស៊ីតមកអនុវត្ត ។ ករណីនេះពាក់ព័ន្ធនឹងស្ត្រីម្នាក់ឈ្មោះ ក.ត ដែលត្រូវបានទទួលរងការវាយប្រហារនៅខែឧសភា ឆ្នាំ២០១១ ដោយសមាជិកគ្រួសារទំនាស់ម្នាក់ ។ ការវាយប្រហារបានធ្វើឲ្យគាត់ខូចមុខមាត់យ៉ាងធ្ងន់ធ្ងរ និងបាត់បង់ភ្នែកខាងឆ្វេង ។ ការជម្រះក្តីត្រូវបានធ្វើឡើងនៅខែមិថុនាឆ្នាំ២០១២ ហើយតុលាការបានចេញសាលក្រមឲ្យជនល្មើសជាប់ពន្ធនាគារចំនួន១០ឆ្នាំ ព្រមទាំងបង់ប្រាក់សំណងចំនួន៥០០០ដុល្លារ ។ តុលាការឧទ្ធរណ៍តម្កល់ទុក និងគាំទ្រសេចក្តីសម្រេចនេះ ។[១៩៤] ប៉ុន្តែ ចៅក្រមបានប្រើប្រាស់ច្បាប់ស្តីពីអាស៊ីតមកដោះស្រាយក្តី (មាត្រា២០ កថាខណ្ឌទី២ អំពី "អំពើហិង្សាដោយទឹកអាស៊ីតដោយចេតនាដែលនាំឲ្យពិការអស់មួយជីវិត") បើទោះបីជាការវាយប្រហារនោះ ត្រូវបានធ្វើឡើងនៅមុនពេលចូលជាធរមាននៃច្បាប់អាស៊ីតក៏ដោយ ។ នេះអាចត្រូវគេមើលឃើញថា ជាការបំពានលើគោលការណ៍ *គ្មានច្បាប់ចែង គ្មានទោស* ដែលហាមឃាត់មិនឲ្យដាក់

---

[១៩៣] ករណីមួយក្នុងចំណោមករណីទាំងនេះជាបទល្មើសព្រហ្មទណ្ឌ ។ ជនរងគ្រោះ ណ.ស បានធ្វើដំណើរតាមម៉ូតូដោយមានកាន់កន្ត្រកដែលមានផ្ទុកអាស៊ីតនៅពេលដែលគាត់ត្រូវបានគេវាយប្រហារពីក្រោយ ។ នៅពេលដែលកន្ត្រកបែក ទឹកអាស៊ីតក៏បានខ្ទាតទៅលើជនរងគ្រោះ ។ បុរសបង្កហេតុដែលនៅលើម៉ូតូបានរត់គេច ហើយប៉ូលីសមិនបានព្យាយាមតាមចាប់ជនដៃដល់នោះទេ ។

[១៩៤] លាង សារិទ្ធិ និងម៉ម គន្ធា, *ការកាត់ទោស១០ឆ្នាំក្នុងរឿងក្តីទឹកអាស៊ីត*, កាសែតភ្នំពេញប៉ុស្តិ៍, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣, អាចរកបាននៅគេហទំព័រ http://www.phnompenhpost.com/2013061266222/National/10-year-sentence-upheld-in-acid-case.html

ទណ្ឌកម្មលើបទល្មើសដែលទាន់មានច្បាប់ចែងពីរឿងនោះ ។[១៩៥] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានលើកឡើងថា សាលក្រមនេះបានបង្ហាញពី «ឆន្ទៈរបស់តុលាការក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាដោយទឹកអាស៊ីត» ។ ផ្ទុយទៅវិញទង្វើបែបនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក៏យល់ថា វា«ជាបញ្ហាដែលតុលាការសម្រេចចិត្តចេញសាលក្រមដោយផ្អែកលើច្បាប់ដែលមិនទាន់មានក្នុងសៀវភៅនៅឡើយ ហើយសេចក្តីសម្រេចនេះអាចយុត្តិសាស្ត្រមួយដ៏គ្រោះថ្នាក់ ។»[១៩៦] ខ្ញុំយល់ស្របជាមួយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ។ វាជាសញ្ញាវិជ្ជមានរបស់តុលាការដែលបានសម្រេចចិត្តអនុវត្តច្បាប់ស្តីពីអាស៊ីតក្នុងការប្រឆាំងជាមួយអំពើហិង្សាដោយទឹកអាស៊ីត ប៉ុន្តែ ធ្វើបែបនេះដោយ«បំពាន»លើច្បាប់ផ្សេងមិនមែនជាដំណោះស្រាយសមស្របទេ ។ ដើម្បីទទួលបានយុត្តិធម៌ពិតប្រាកដ តុលាការគួរតែអនុវត្តតាមបញ្ញត្តិគ្រប់នីតិវិធីយុត្តិធម៌ ។

ករណីរបស់ជនរងគ្រោះ ណ.ស វាជាសញ្ញាវិជ្ជមានមួយដោយការជំនុំជម្រះក្តីបានធ្វើឡើងឆាប់រហ័ស ហើយជនល្មើស ប.ស ត្រូវបានផ្តន្ទាទោស ។ លើសពីនេះទៅទៀត ជនល្មើស ប.ស ត្រូវបាន ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន៥ឆ្នាំ ដែលទណ្ឌកម្មនេះជាទណ្ឌកម្មធ្ងន់បំផុតសម្រាប់បទល្មើសដែលត្រូវចោទប្រកាន់ («អំពើហិង្សាដោយទឹកអាស៊ីតដោយចេតនា» មាត្រា២០) ។ តាមរយៈសាលក្រមនេះ ចៅក្រមទទួលស្គាល់ពីភាពឃោរឃៅព្រៃផ្សៃនៃបទល្មើសនេះ ហើយបានអនុវត្តតាមច្បាប់យ៉ាងត្រឹមត្រូវ ។ នេះគឺជារឿងគួរឲ្យលើកទឹកចិត្ត ។ លោក សាមមេន បានបញ្ជាក់នៅក្នុងបទសម្ភាសន៍ជាមួយទស្សនាវដ្តី Southeast Asian Globe ថា «នេះជាជំហានដំបូង ហើយវាជំហានតូចមួយ ប៉ុន្តែជាជំហានមួយដ៏សំខាន់ ។ ខ្ញុំគិតថា វាធ្វើឲ្យយើងមានសុទិដ្ឋិនិយម» ។[១៩៧]

ប៉ុន្តែ វាគួរឲ្យចោទឆ្ងល់ ប្រសិនបើជនល្មើស ប.ស ត្រូវបានចោទប្រកាន់ពីបទល្មើសនិងក្រោមមាត្រាត្រឹមត្រូវនៃច្បាប់ស្តីពីអាស៊ីត ។ តើទំហំព្យសនកម្មរបស់ជនរងគ្រោះ ណ.ស សមស្របជាមួយនឹងទម្ងន់បទចោទឬទេ? ករណីនេះផ្អែកទៅលើការប៉ាន់ប្រមាណមើលថាតើ«ពិការភាពអស់មួយជីវិត»របស់ជនរងគ្រោះ ណ.ស «ពិការមួយជីវិត»ដែរឬទេ ដែលយោងតាមមាត្រា២០ ជាលក្ខខណ្ឌទម្ងន់ទោស នាំទៅដល់ទោសអតិបរមាដែលខ្ពស់ជាងនេះ ។ បទចោទដែលយកមកប្រើ

---

[១៩៥] គោលការណ៍នេះបានកំណត់ថាបើសិនជាគ្មានច្បាប់បានចែងដើម្បីហាមឃាត់អំពើដែលប្រព្រឹត្តទេ នោះអំពើនោះមិនមែនជាបទល្មើសទេ ហើយការប្រព្រឹត្តអំពើនោះក៏មិនត្រូវបានដក់ទោសទណ្ឌដែរ ។

[១៩៦] បទសម្ភាសន៍ជាមួយបុគ្គលិក CCHR តាមរយៈសារអេឡិចត្រូនិច ។

[១៩៧] Otis, *មើលកំណត់ចំណាំលេខ ៣៥, ទំព័រ ៤៤-៤៥ ។*

គឺផ្អែកទៅលើកម្រិតនៃព្យសនកម្ម ហើយកម្រិតនៃព្យសនកម្ម ត្រូវតែកំណត់តាមរយៈ "ឯកទេសសុខាភិបាល" ដែលត្រូវតែធ្វើឡើងដោយវេជ្ជបណ្ឌិតដែលមានអាជ្ញាបណ្ណក្នុងការត្រួតពិនិត្យត្រឹមត្រូវ ។ យោងតាម មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ការថ្លឹងថ្លែងពីទំហំព្យសនកម្មអាចជាបញ្ហា ហើយខ្ញុំធ្លាប់ឃើញដោយផ្ទាល់នូវការត្រួតពិនិត្យដែលវេជ្ជបណ្ឌិតមិនប៉ះអ្នករួចរស់ជីវិត និងមិនបានធ្វើការត្រួតពិនិត្យពិតប្រាកដឡើយ ។ លោក សាមមេន បានបន្ថែមទៀតថា ក្រៅពីពិការអវយវៈខាងក្រៅ ផលវិបាកនៃព្យសនកម្មដែលនឹងកើតមានចំពោះឱកាសក្នុងការស្វែងរកការងាររបស់ជនរងគ្រោះ គួរតែជាកត្តាមួយសម្រាប់ការធ្វើសេចក្តីសម្រេចផងដែរ ។

ដោយសារតែច្បាប់ស្តីពីអាស៊ីតទើបយកមកអនុវត្តបាន២ករណី វាជាការលំបាកក្នុងការធ្វើសេចក្តីសន្និដ្ឋានលើអានុភាពនៃច្បាប់នេះ ។ ការដែលជនល្មើសនៅក្នុងរឿងក្តីទាំងពីរត្រូវរកឃើញថាមានទោស និងផ្តន្ទាទោសធ្ងន់បំផុតតាមបទចោទប្រកាន់ គឺជារឿងគួរឲ្យលើកទឹកចិត្ត ។ ថែមពីលើនេះទៀត ការសម្រេចចិត្តរបស់ចៅក្រមក្នុងការប្រើប្រាស់ច្បាប់ស្តីពីអាស៊ីតនៅក្នុងករណីរបស់ ក.គ បង្ហាញពីការប្តេជ្ញាចិត្តក្នុងការបោះជំហានឆ្ពោះទៅមុខ និងការដាក់ទោសទណ្ឌលើជនដែលជាប់ពិរុទ្ធក្នុងការប្រព្រឹត្តអំពើហិង្សាដោយទឹកអាស៊ីត ។ ករណីនេះគឺជាចំណុចវិជ្ជមាន ដែលព្រះរាជអាជ្ញា និងចៅក្រម បានយល់ដឹងអំពីបាតុភូតនៃអំពើហិង្សាដោយទឹកអាស៊ីត ព្រមទាំងប្តេជ្ញាចិត្តបំពេញកាតព្វកិច្ចប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព ។

បើទោះបីជាមានការបោះជំហានទៅមុខដោយមានច្បាប់ជាក់លាក់ និងបទបញ្ញត្តិដែលមានរបៀបរៀបរយដើម្បីដាក់ទណ្ឌកម្មលើអំពើហិង្សាដោយទឹកអាស៊ីត និងដាក់កម្រិតលើការលក់ដូរអាស៊ីត ការទុកដាក់ ការដឹកជញ្ជូន ដែលត្រូវបាននឹងកំពុងប្រើប្រាស់ក៏ដោយ ដើម្បីឲ្យមានប្រសិទ្ធភាពយូរអង្វែង និងអានុភាពពិតប្រាកដ ទាល់តែព្រះរាជអាជ្ញា និងចៅក្រមទាំងអស់យល់ដឹងពីបទបញ្ញត្តិរួមជាមួយនឹងរបៀបវិធីនៃការអនុវត្តច្បាប់ទាំងនោះ ។ ដោយសារតែមានការវាយប្រហារដោយទឹកអាស៊ីតមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានជំនុំជម្រះ ទើបយើងមិនទាន់អាចនិយាយបានទេថាច្បាប់ស្តីពីអាស៊ីតមានអានុភាពលើអំពើហិង្សាដោយទឹកអាស៊ីត ឬដំណោះស្រាយតាមផ្លូវច្បាប់សម្រាប់ជនរងគ្រោះនៃអំពើហិង្សាដោយទឹកអាស៊ីតនៅកម្ពុជា ។ ការស្រាវជ្រាវបន្តទៀតក្នុងរយៈពេលវែងជាងនេះ ជាតម្រូវការចាំបាច់ក្នុងការប៉ាន់ស្មានពីអានុភាពរបស់ច្បាប់ស្តីពីអាស៊ីត ។

សម្រាប់ពេលបច្ចុប្បន្ន ការអនុម័តច្បាប់ស្តីពីអាស៊ីត និងអនុក្រឹត្យពាក់ព័ន្ធ គឺជាជំហានទៅមុខក្នុងការទទួលបានយុត្តិធម៌ពេញលេញសម្រាប់ជនរងគ្រោះនៅកម្ពុជា ដែលក្នុងនោះ អ្នករួចរស់ជីវិតពីអំពើហិង្សាដោយអាស៊ីត មានសិទ្ធិទទួលបានយុត្តិធម៌យ៉ាងពេញលេញ ជនល្មើសត្រូវបានកាត់ទោស

និងដាក់ទណ្ឌកម្មយ៉ាងតឹងរ៉ឹង ហើយអំពើហិង្សាដោយទឹកអាស៊ីត នឹងលែងមានទាល់តែសោះនៅពេលខាងមុខ ។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ញឹកញាប់ពេកដែលជនរងគ្រោះដោយការវាយប្រហារដោយទឹកអាស៊ីត មិនបានទទួលសំណងសូម្បីតែបន្តិច ដោយគ្មានមធ្យោបាយទទួលបានដំណោះស្រាយ និង យុត្តិធម៌តាមផ្លូវច្បាប់ ។ បច្ចុប្បន្ននេះ ឋានៈសង្គម-សេដ្ឋកិច្ចរបស់ជនរងគ្រោះ និងប្រព័ន្ធច្បាប់ដែលមានចន្លោះប្រហោង មិនបានអនុញ្ញាតឲ្យជនរងគ្រោះ ទទួលបានយុត្តិធម៌ដោយសមស្រប និងមានប្រសិទ្ធិភាពនោះទេ ។ ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីតខ្លាំង ត្រូវបានអនុម័តឡើងក្នុងគោលបំណងមួយផ្នែក ដើម្បីដោះស្រាយបញ្ហាខាងលើ និងបញ្ចប់និទណ្ឌភាព ។

ប៉ុន្តែ យុត្តិធម៌អាចទទួលបានលុះត្រាណាតែមានប្រព័ន្ធច្បាប់ ដែលមានប្រសិទ្ធិភាព ដំណើរការពេញលេញ ឯករាជ្យ និងមិនលម្អៀង ដែលស្របតាមនីតិរដ្ឋ ។ ដោយសារប្រព័ន្ធច្បាប់នៅ កម្ពុជាមិនទាន់មានដំណើរការត្រឹមត្រូវ ច្បាប់ និងអនុក្រឹត្យស្តីពីអាស៊ីតតែឯង ពុំទាន់គ្រប់គ្រាន់ដើម្បីធានាថា អ្នករួចរស់ជីវិតពីអំពើហិង្សាដោយទឹកអាស៊ីតអាចទទួលបានយុត្តិធម៌ ដូចដែលពួកគេចង់បាននៅឡើយ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គួរតែខិតខំប្រឹងប្រែងឲ្យបានគ្រប់គ្រាន់ ដើម្បីធានាថា ការស៊ើបអង្កេតត្រឹមត្រូវលើការវាយប្រហារដោយអាស៊ីតត្រូវបានធ្វើឡើង អ្នករួចរស់ជីវិតទទួលបានការការពារពីការគំរាមកំហែង និងបំបាត់ការការយល់ឃើញមិនត្រឹមត្រូវ និងធានាថា ជនដៃដល់នៃអំពើហិង្សាដោយទឹកអាស៊ីត ត្រូវបានជំនុំជម្រះ និងដាក់ទណ្ឌកម្ម ។ ប៉ុន្តែ បញ្ហាចោទជាឧបសគ្គក្នុងការសម្រេចបានចំណុចខាងលើរួមមាន ការខ្វះឆន្ទៈនយោបាយ អំពើពុករលួយ និងកង្វះការអនុវត្តច្បាប់ដែលបណ្តាលមកពីកង្វះចំណេះដឹង និង ធនធាន ។

ខាងក្រោមជាអនុសាសន៍ដែលអាចនាំឲ្យឈានទៅរកយុត្តិធម៌ច្រើនជាងមុន ៖

- ប្រជាជនកម្ពុជាគួរតែយល់ដឹងពីសិទ្ធិដែលខ្លួនមាន និងជំរុញឲ្យយល់ថា ទទួលរងការវាយប្រហារដោយទឹកអាស៊ីត គឺមិនអាចយកហេតុផលណាមួយមកដោះសាបានទេ ។ ការយល់ដឹងនេះអាចជំរុញឲ្យពួកគាត់រកដំណោះស្រាយផ្លូវច្បាប់ ។
- សេវាកម្មគួរតែមានតម្លៃសមរម្យ ហើយអ្នករួចរស់ជីវិតពីការវាយប្រហារដោយទឹកអាស៊ីតមិនគួរត្រូវបានរារាំងពីការស្វែងរកជំនួយផ្នែកច្បាប់ ដោយសារតែការព្រួយបារម្ភពីបញ្ហាហិរញ្ញវត្ថុនោះទេ ។ ស្ថានភាពសេដ្ឋកិច្ចរបស់បុគ្គលម្នាក់មិនគួរជាកត្តារារាំងពីការទទួលបានយុត្តិធម៌ឡើយ ។

- ប្រព័ន្ធការពារជនរងគ្រោះ និងសាក្សី គួរតែត្រូវបង្កើតឡើង ដើម្បីការពារកុំឲ្យសាក្សីបដិសេធការផ្តល់កសិណដោយការភ័យខ្លាចការសងសឹក ។ លើសពីនេះទៅទៀត សាក្សីគួរតែត្រូវបានលើកទឹកចិត្តឲ្យផ្តល់កសិណ ។
- ព្រះរាជអាជ្ញា និងចៅក្រម អាចមានការយល់ឃើញអវិជ្ជមានលើអ្នករួចរស់ជីវិត ដោយយល់ថា ពួកគាត់សមនឹងទទួលនូវអ្វីដែលបានកើតឡើង ។ ការយល់ឃើញនេះគឺផ្អែកលើការទទួលបានព័ត៌មានអំពី និងការយល់ដឹងអំពីបញ្ហានេះ ។ ការអនុម័តច្បាប់ស្តីពីអាស៊ីតគួរតែជាកត្តាជំរុញឲ្យមន្ត្រីតុលាការបានយល់ដឹងពីអំពើហិង្សាដោយទឹកអាស៊ីតបានច្រើនជាងមុន និងជាការជំរុញបន្ថែមលើការជំនុំជម្រះអំពើហិង្សាដោយទឹកអាស៊ីតយ៉ាងសកម្ម ។
- បើសិនជាមានឧទាហរណ៍នៃការជំនុំជម្រះដែលទទួលបានជោគជ័យកាន់តែច្រើន ជំនឿចិត្តលើប្រព័ន្ធច្បាប់ក៏នឹងមានកាន់តែច្រើន ។ ការបានដឹងបានឮពីរឿងវិជ្ជមានពីអ្នករួចរស់ជីវិតពីការវាយប្រហារលោកអាស៊ីតដូចគ្នា អាចធ្វើឲ្យជនរងគ្រោះមានជំនឿទុកចិត្តកាន់តែខ្លាំង ក្នុងការស្វែងរកយុត្តិធម៌ ។
- ការយល់ដឹងថា ការដាក់ទណ្ឌកម្មលើអំពើហិង្សាដោយអាស៊ីត នឹងមិនទំនងជាកើតឡើងជាមូលហេតុធ្វើឲ្យមានអំពើហិង្សាដោយទឹកអាស៊ីតទៅថ្ងៃមុខ ។ ដូច្នេះ ការអនុវត្តច្បាប់ស្តីពីអាស៊ីត អាចធ្វើឲ្យរារែកចំពោះអ្នកដែលមានបំណងប្រព្រឹត្តបទល្មើសនេះ ។
- អ្នកច្បាប់ គួរតែទទួលបានការហ្វឹកហ្វឺនគ្រប់គ្រាន់ មានជំនាញពេញលេញ និងមានចំណេះដឹងគ្រប់គ្រាន់ ដើម្បីក្លាយជាសមាជិករបស់ប្រព័ន្ធតុលាការ ។

ប្រសិទ្ធិភាពនៃច្បាប់ស្តីពីអាស៊ីត និងអនុក្រឹត្យ ត្រូវផ្អែកលើប្រព័ន្ធតុលាការ និងរាជរដ្ឋាភិបាល ។ ប្រសិនបើការអនុវត្តច្បាប់បានត្រឹមត្រូវ វានឹងធានាថា ជនដៃដល់នៃអំពើហិង្សាអាស៊ីតលែងទទួលបាននិទណ្ឌភាពចំពោះបទល្មើសដែលបានប្រព្រឹត្ត ។ ប៉ុន្តែ ចំណុចនេះអាចសម្រេចទៅបានលុះត្រាណាតែប្រព័ន្ធយុត្តិធម៌មានដំណើរការត្រឹមត្រូវ ។ ដើម្បីឲ្យកើតឡើង វាចាំបាច់តម្រូវឲ្យមានការស៊ើបអង្កេត ការជំនុំជម្រះ និងការវិនិច្ឆ័យទោសត្រឹមត្រូវ ។ គោលបំណងទាំងនេះអាចសម្រេចបាន ប្រសិនបើអ្នកដើរតួក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងរដ្ឋាភិបាល បានចូលរួមសហការគ្នា ។